ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរ**
**នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"**
**សាធារណៈ**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩**
**សវនាការលើកទី៦២**

**ចៅក្រមសាលាដំបូង៖**
លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**
លោកស្រី សែ កុលវុឌ្ឍី
លោក ឌុច ផារី
កញ្ញា ណាតាចា វ៉ិចស៊ែល រីស៊ី
*(Ms. Natacha Wexels-Riser)*
លោក ម៉ាត្ត គ្រីស្តារ *(Mr. Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**
លោក សេង ប៊ុនឃាង
លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent DE WILDE D'ESTMAEL)*

លោក ប៉ាក់ ចន្ទលីណូ

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារេស

*(Marie-Paule CANIZARES)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គីម ម៉េងឃី

កញ្ញា ទី ស្រ៊ីនណា

លោក ហុង គីមសួន

លោកស្រី ស៊ីលឃី ស្ទូតហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស

*(Ms. Fabienne Trusse-NAPROUS)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# ឧបសម្ព័ន្ធ

## ដើមបណ្តឹងរដ្ឋប្បវេណី

### លោក ជុំ ស៊ីរ៉ាត់

ស្តួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........ទំព័រ ៣
សួរដោយ លោកស្រី ស៊ីលឃីស្ទូត ហ្សុីនស្គី ផ្តើមពី ........ទំព័រ ២៥
សួរដោយ លោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល ផ្តើមពី........ទំព័រ ២៨

### លោកស្រី ជុំ នៅ

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........ទំព័រ ៣៥

### លោក អ៊ុំ សាវរិត

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........ទំព័រ ៤១
សួរដោយ លោក ហុង គីមសួន ផ្តើមពី........ទំព័រ ៥៩
សួរដោយ លោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល ផ្តើមពី........ទំព័រ ៦២

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោកស្រី ម៉ារីប៉ូល កានីហ្សារេស | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោកស្រី ជុំ នៅ | ខ្មែរ |
| លោក ជុំ ស៊ីវ៉ាត់ | ខ្មែរ-បារាំង |
| លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ | បារាំង |
| លោក អ៊ូ សាវរិត | បារាំង |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស | បារាំង |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលមកកាន់បន្ទប់សវនាការ)*

[០៩:០៥:៥០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ នៅថ្ងៃនេះ តាមកាលវិភាគបានគ្រោងទុក គឺយើងបន្តស្ដាប់សេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះ និងចំនួនបីនាក់ ហើយម្នាក់យើងនឹងធ្វើការស្ដាប់សេចក្ដីថ្លែងការណ៍ពីចម្ងាយ ។

ក្រឡាបញ្ជីសវនាការឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលត្រូវអញ្ជើញចូលរួមក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរនីតិវីសវនាការនៅក្នុងថ្ងៃនេះ មានវត្តមានគ្រប់ចំនួន ។ ចំណែកឯដើមណ្ដឹងរដ្ឋប្បវេណីដែលត្រូវមកផ្ដល់សក្ខីកម្មនៅក្នុងថ្ងៃនេះ លោកស្រី ឈិន ណាវី, លោក ជុំ ស៊ីរ៉ាត់, លោកស្រី ជុំ នៅ មានវត្តមានរង់ចាំការកោះហៅពីអង្គជំនុំជម្រះ ។ ខ្ញុំបានត្រួតពិនិត្យអត្តសញ្ញាណរបស់ដើមណ្ដឹងរដ្ឋប្បវេណីរួចរាល់ហើយ ។ ចំណែកឯ ដើមណ្ដឹងរដ្ឋប្បវេណីលោកស្រី អ៊ំ សាវរិត បានត្រៀមខ្លួនរួចហើយ ដើម្បីមកផ្ដល់ចម្លើយតាមរយៈការចូលរួមពីចម្ងាយពីប្រទេសបារាំងនៅរសៀលនេះ ។

[០៩:០៧:២៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីអាឡាំង វ៉ែនណឺ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណ អរុណសួស្ដីលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំទទួលបានអ៊ីម៉ែលពីកន្លះម៉ោងមុនជម្រាប់ខ្ញុំថា កូនក្ដី Feffrey James E2/86 គាត់មិនអាចធ្វើដំណើរមកតាមកាលកំណត់នោះទេ ។ គាត់ពន្យល់ថា ម្ដាយរបស់គាត់ឈឺ ដូច្នេះហើយគឺគាត់មិនអាចធ្វើដំណើរមកនោះទេ ។ ប្រសិនបើនេះ ខ្ញុំបានជម្រាបនោះ វីដេអូ ខនហ្វើរិន គឺយើងមិនអាចធ្វើទៅបាននោះទេ ។ ខ្ញុំជឿថាសេចក្ដីថ្លែងការណ៍របស់គាត់នោះ គឺអាចផ្ដល់ជាសេចក្ដីថ្លែងការណ៍ថ្មី ប៉ុន្តែយ៉ាងណាក៏ដោយគឺ

យើងមិនអាចស្តាប់គាត់បានទេ ។ គឺយើងសូម-- ខ្ញុំសូមជម្រាបជូនអំពីដើមណ្តឹងរដ្ឋប្បវេណី គឺ E2/86 ដែលគាត់មិនអាចមកតាមកាលកំណត់ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ស្នូតហ្សីនស្គី ។

**លោកស្រី ស៊ីលឃីស្នូត ហ្សីនស្គី៖**

សូមគោរពលោក លោកស្រីចៅក្រម លោកប្រធានជាទីគោរព! ជាបឋមខ្ញុំសូមដាក់សំណើដូចខាងក្រោម៖

ទាក់ទងទៅនឹងលំដាប់លំដោយនៃការបង្ហាញខ្លួនដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃនេះ ។ ខ្ញុំសូមស្នើចាប់ផ្តើមពីលោក ជុំ ស៊ីវ៉ាត់ ហើយលោកស្រី ឈិន ណារី គឺគាត់មានវត្តមាន ប៉ុន្តែគាត់មិនមានអាម្មរណ៍មិនសូវស្រួលនៅព្រឹកនេះ ។ គាត់នៅបន្ទប់ខាងក្រោម នៅបន្ទប់ដើមបណ្តឹងរដ្ឋប្បវេណីជនរងគ្រោះ ហើយគឺគាត់មិនមានអាម្មរណ៍ស្រួលខ្លួន ដូច្នេះគាត់មិនអាចផ្តល់សេចក្តីថ្លែងការណ៍នៅព្រឹកនេះទេ ហើយគាត់សង្ឃឹមថា គាត់អាចមកផ្តល់សេចក្តីថ្លែងការណ៍បន្ទាប់ពីអាហារថ្ងៃត្រង់ ។

នៅពេលនេះ គឺលោកស្រី ឈិន ណារី គឺគាត់កំពុងតែសម្រាកនៅឡើយ ។ ដូច្នេះ ខ្ញុំស្នើសុំអង្គសវនាការធ្វើការប្តូរលំដាប់លំដោយ ហើយសូមឲ្យចាប់ផ្តើមលោក ជុំ ស៊ីវ៉ាត់ នៅពេលព្រឹក ហើយនិងយើងពិនិត្យមើលនៅពេលក្រោយ ថាតើលោកស្រី ឈិន ណារី គាត់មានស្ថានភាពសុខភាពយ៉ាងម៉េច នៅពេលនោះយើងនឹងពិចារណា នឹងគិតទៅតាមក្រោយ ។ សូមអរគុណ ។

[០៩:១០:២៥]

**ប្រធានអង្គជំនុំ៖**

អរគុណចំពោះមេធាវីទាំងពីរដែលបានផ្តល់ព័ត៌មានពីការមិនអាចចូលរួមបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី E2/86 ហើយនិងមានបំណងក្នុងការរៀបចំនូវការចូលរួមសាជាថ្មី នេះជាឱកាសក្នុងការដែលនាំឲ្យអង្គជំនុំជម្រះ មានការគិតគូរពិចារណា និងរៀបចំរបៀបនៅក្នុងការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីនេះសាជាថ្មី ។ ដោយឡែក សំណើសុំរបស់មេធាវី ស្នូតហ្សីនស្គី អង្គជំនុំជម្រះយល់ព្រមតាមសំណើនេះ ។

មន្ត្រីតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី ជុំ ស៊ីវ៉ាត់ មកកាន់កៅអីដែលបានរៀបចំទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះ ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលមកកាន់បន្ទប់សវនាការ)*

[០៩:១២:៥៥]

**ការតាំងសំណួរដោយចៅក្រម៖**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ដើមបណ្ដឹងរដ្ឋប្បវេណី តើលោកឈ្មោះ ជុំ ស៊ីរ៉ាត់ អ៊ីចឹងពិតមែនដែរឬទេ?

**ឆ៖** អ៊ីចឹងពិតមែនលោកប្រធាន ។

**ស៖** លោក ជុំ ស៊ីរ៉ាត់ មើលរៀបចំនៅការសួរមុននឹងឆ្លើយ ចាំមើលភ្លើងនេះ បើក្រហមអាហ្នឹងជាសញ្ញាដែលអាចលោកឆ្លើយបាន ពីព្រោះដើម្បីឱ្យប្រព័ន្ធសំឡេងរបស់លោកផ្សាព្វផ្សាយនៅប្រព័ន្ធនៅក្នុងសាលនេះផង ហើយនិងប្រតិចារឹកកត់ត្រានូវសម្ដីរបស់លោកដែលបាននិយាយនៅចំពោះមុខអង្គជំនុំជម្រះ ។

តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំអាយុ ៦៨ឆ្នាំ ។

**ស៖** លោកមានទីកន្លែងកំណើតនៅឯណាដែរ?

**ឆ៖** ខ្ញុំកើតនៅឃុំល្វា ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

**ស៖** ទីកន្លែងលំនៅសព្វថ្ងៃតើលោកនៅទីកន្លែងណា ហើយលោកប្រកបមុខរបស់រកស៊ីធ្វើអ្វីដែរ?

**ឆ៖** សព្វថ្ងៃខ្ញុំនៅជ្រោយចង្វា ខ្ញុំជាប្រធានក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មាន នៅប្រទេសខ្មែរតាំងពីឆ្នាំ២០០៣ ។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអ្វី ហើយសព្វថ្ងៃនេះតើគាត់នៅរស់ឬក៏គាត់ទទួលមរណភាពហើយ?

**ឆ៖** ឪពុកខ្ញុំឈ្មោះ ជុំ ឌឹម សព្វថ្ងៃស្លាប់ ។

[០៩:១៤:៥៤]

**ស៖** ចុះម្ដាយបង្កើតរបស់លោកតើគាត់ឈ្មោះអ្វី? ហើយសព្វថ្ងៃនេះគាត់នៅរស់ ឬក៏ទទួលមរណភាពហើយ?

**ឆ៖** ម្ដាយខ្ញុំឈ្មោះ គឹម តាត សព្វថ្ងៃទទួលមរណភាពហើយ ។

**ស៖** លោក ជុំ ស៊ីវ៉ាត់ តើលោកមានបងប្អូនបង្កើតប៉ុន្មាននាក់?

**ឆ៖** ជម្រាបលោកប្រធានបងប្អូនខ្ញុំប្រាំបីនាក់ ប្រុសបួន ស្រីបួន ។

**ស៖** ចូរលោករៀបរាប់នូវឈ្មោះរបស់បងប្អូនបង្កើតរបស់លោកតាមលំដាប់ពីបងគេបង្អស់ ហើយជាបន្តបន្ទាប់រហូតដល់ពៅគេ ។ តើមានឈ្មោះអ្វីខ្លះ?

**ឆ៖** បងបង្អស់ឈ្មោះ ជុំ សារុន ។ បន្ទាប់មកបងស្រីឈ្មោះ ជុំ សារិន ។ បន្ទាប់មកបងស្រី ឈ្មោះ ជុំ ស៊ីម៉ាលី ។ បន្ទាប់មកបងស្រីទៀត ឈ្មោះ ជុំ ស៊ីម៉ាឡៃ ។ បន្ទាប់មកខ្លួនខ្ញុំ ជុំ ស៊ីវ៉ាត់ ។ បន្ទាប់ពីខ្ញុំមាន ជុំ ណារិត ។ បន្ទាប់ពីជុំ ណារិត មាន ជុំ ស៊ីណារី ជាស្រី ហើយបន្ទាប់ពី ស៊ីណារី ប្អូនពៅគឺ ជុំ ស៊ីណារ៉េត ។

[០៩:១៦៣០]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះផ្តល់ឱកាសទៅមេធាវី ស្នូតហ្សីនស្គី ដែលជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ ដើម្បីឡើងធ្វើសេចក្តីថ្លែងការណ៍បង្ហាញអំពីអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហេតុដែលនាំដើមបណ្តឹងរដ្ឋប្បវេណីសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទំនាក់ទំនងនៃការប្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ទៅនឹងបទឧក្រិដ្ឋដែលបានចោទប្រកាន់ចំពោះជនជាប់ចោទពាក់ព័ន្ធទៅនឹងអង្គហេតុនៃមន្ទីរសន្តិសុខស-២១ នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ ព្រមទាំងភស្តុតាងនានាដែលមានដើម្បីគាំទ្រដល់ការប្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ស៊ីវ៉ាត់។

សូមអញ្ជើញ ។

[០៩:១៧:២៥]

**លោកស្រី ស៊ីលឃីស្នូត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំនឹងនិយាយដោយសង្ខេបអត្តសញ្ញាណរបស់ ជុំ ស៊ីវ៉ាត់ គឺបញ្ជាក់ដោយអត្តសញ្ញាណប័ណ្ណរបស់គាត់នៅក្នុងសំណុំរឿង ហើយពាក់ព័ន្ធទៅនឹងរឿងក្តី គឺដូចខាងក្រោម៖

គឺគាត់បានបាត់បង់ប្អូនប្រុសរបស់លោកពីររូប គឺ ជុំ ណារិត និង ជុំ ស៊ីណារ៉េត នៅមន្ទីរទួលស្លែង ហើយក៏បាត់បង់ប្អូនស្រីថ្លៃ-- ប្អូនថ្លៃស្រី គឹម សុវណ្ណារី ហើយនិងកូនដែលពុំទាន់ចាប់កំណើតផងដែរ ។ ឯកសារបន្ទាប់បន្សំគាំទ្រទៅលើរឿងនេះ គឺដូចខាងក្រោម៖

គឺរូបថតមួយដែលជារូបថតរបស់ ជុំ ស៊ីណារិត មាននៅក្នុងសំណុំរឿង មានលេខ ERN 00194502 ។ ហើយ ជុំ ណារ៉េត វិញគឺក៏ជាប់នៅទួលស្លែងផងដែរ ។ ហើយចូលនៅក្នុងទួលស្លែងនៅថ្ងៃទី២៩ តុលា ឆ្នាំ១៩៧៦ ហើយត្រូវបានសម្លាប់ចោលនៅថ្ងៃ១ មករា ១៩៧៧ ។ នេះគឺបង្ហាញតាមរយៈភស្តុតាងដែលកូនក្តីរបស់ខ្ញុំបានទទួលបានពីមន្ទីរទួលស្លែងនៅពេលដែលគាត់ទៅទស្សនកិច្ចនៅទីនោះ ។ ហើយចំពោះសំណងវិញ កូនក្តីរបស់ខ្ញុំទុកសិទ្ធិឲ្យមេធាវីជាអ្នកទាមទារ ដូច្នេះខ្ញុំសូមជម្រាបអង្គសវនាការថា យើងខ្ញុំនឹងរៀបចំនីតិវិធីរបស់យើងខ្ញុំដូចតទៅ៖

[០៩:១៩:១៤]

ជាបឋមលោក ជុំ ស៊ីវ៉ាត់ នឹងផ្តល់នូវសេចក្តីថ្លែងការណ៍លោក បន្ទាប់មកខ្ញុំនឹងតាំងសំណួរមួយចំនួនតូចទៅកាន់លោក ។ ហើយនៅពេលនេះ គឺខ្ញុំសូមអនុញ្ញាតថា ឲ្យលោក ជុំ ស៊ីណារ៉េត (*ស៊ិក)* គាត់ធ្វើការ-- គាត់ទទួលវេទិកា ។ ជុំ ស៊ីវ៉ាត់ (សូមអភ័យទោស) គឺគាត់សូមធ្វើសេចក្តីថ្លែងការណ៍ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ជុំ ស៊ីវ៉ាត់ អង្គជំនុំជម្រះផ្តល់ឱកាសដល់លោក ដើម្បីធ្វើសេចក្តីថ្លែងការណ៍រៀបរាប់ប្រាប់ដល់អង្គសវនាការអំពីទំនាក់ទំនង អំពីហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានធ្វើចោទប្រកាន់ទៅជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលមានការប៉ះពាក់ចំពោះរូបលោកក្នុងអំឡុងពេលបង្កើតនិងប្រតិបត្តិការនៃមន្ទីរសន្តិសុខស-២១ ចាប់ពីថ្ងៃទី១៥ ខែមេសា ៧៥ រហូតដល់ថ្ងៃទី ០៦ ខែមករា ឆ្នាំ៧៩ ដែលនាំឲ្យលោកសម្រេចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណង និងថ្លែងការណ៍អំពីស្ថានភាពព្យសនកម្មដែលមានចំពោះរូបលោកជាអាទិ៍ គឺការខូចខាតផ្នែកខាងរាងកាយ សម្ភារៈ ឬក៏ផ្លូវចិត្ត និងជាផលវិបាកផ្ទាល់ពីបទឧក្រិដ្ឋចំពោះរូបលោក ។ ហើយផលវិបាកនោះ គឺមានកើតមានពិប្រាកដ ។ សូមអញ្ជើញ ។

**លោក ជុំ ស៊ីវ៉ាត់៖**

សូមជម្រាបលោកប្រធាន មុននឹងនិយាយដល់បងប្អូនខ្ញុំ ដែលជារងគ្រោះនៅទួលស្លែង ។ ខ្ញុំសូមអនុញ្ញាតលោកប្រធានជម្រាបអំពីកិច្ចការដែលខ្ញុំបានធ្វើនៅប្រទេសកម្ពុជាដោយសង្ខេប ដើម្បីឲ្យជួយជាពន្លឺដល់ពាក្យសម្តីដែលខ្ញុំនិយាយនៅក្រោយទៀត ។

ខ្ញុំធ្លាប់ធ្វើការនៅប្រទេសកម្ពុជាពីឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៤ ក្នុងឋានៈជាគណនាយកក្រសួងក្រសួងប្រៃណីយ៍និងទូរគមនាគមន៍ ។ ពីឆ្នាំ៧៤ ទៅឆ្នាំ៧៥ ខ្ញុំបានតែងតាំងជាអ្នកតំណាងប្រទេស

កម្ពុជានៅអង្គការជំនាញនៃអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ ។ ពេលដែលភ្នំពេញធ្លាក់ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ គឺខ្ញុំនៅក្រៅប្រទេស ។ ក្រោយមកខ្ញុំបានមករស់នៅប្រទេសបារាំង ហើយខ្ញុំបាន ទទួលសញ្ជាតិបារាំង ។ ដូច្នេះហើយ សព្វថ្ងៃនេះខ្ញុំមានសញ្ជាតិពីរ សញ្ជាតិខ្មែរ ហើយនិងសញ្ជាតិ បារាំង ។ ខ្ញុំរស់ធ្វើការនៅស្រុកបារាំងតាំងពីឆ្នាំ១៩៧៥ មក នៅក្នុងក្រុមហ៊ុនផលិតឧបករណ៍ខាងទូរ-គមនាគមន៍ ហើយនៅក្នុងឋានៈនោះ ខ្ញុំបានទៅរស់នៅនៅស្រុកចិន ចំនួនប្រាំមួយឆ្នាំក្នុងឋានៈជាប្រធាន ក្រុមបារាំងនោះ នៅប្រទេសចិន ហើយក្រោយមកបានមករស់នៅស្រុកខ្មែរយើងវិញពីឆ្នាំ១៩៩៩ ក្នុង ឋានៈជាប្រធានក្រុមហ៊ុននេះ ទទួលបន្ទុកខាងអាស៊ីអាគ្នេយ៍ ។ ដូចខ្ញុំជម្រាបលោកប្រធានអម្បាញ់មិញ នេះ តាំងពីឆ្នាំ២០០៣មក ខ្ញុំបាននិវត្តន៍មកក្រុមបារាំង ហើយបានបង្កើតក្រុមហ៊ុនខ្លួនឯង ហៅថា ព័ត៌មានវិទ្យា ។

ដូចខ្ញុំជម្រាបលោកប្រធានអម្បាញ់មិញ ឪពុកម្ដាយខ្ញុំមានកូនប្រាំបីនាក់ ខ្សត់ខ្សោយទ្រព្យសម្បត្តិ ណាស់ លុយកាក់មិនសូវមាននឹងគេទេ ក៏ប៉ុន្តែមានប្រដៅកូនតែមួយ គឺឲ្យខំរៀន ។ ព្រោះរៀននឹងដូចជា ជណ្ដើរឡើងនៅក្នុងសង្គម ។ ដូចជា មេធាវីរបស់ខ្ញុំបានមានប្រសាសន៍អំមិញ អារឿងដែលជាប់នឹង អង្គហេតុ០០១ នេះ គឺខ្ញុំមានប្អូនពីរនាក់ ប្អូនប្រុសពីរនាក់ ជុំ ស៊ីណារ៉េត អាយុ២៨ឆ្នាំ នៅឆ្នាំ១៩៧៦ ។ ហើយនិង ជុំ ណារិត អាយុ៣៣ឆ្នាំ នៅឆ្នាំ១៩៧៦ ។ គឹម សុវណ្ណារី ហៅ ដន ដែលជាប្រពន្ធ ជុំ ណារិត ដែលខ្ញុំមិនដែលបានស្គាល់ទេ ហើយនិងទារកមួយនៅជាប់នៅស-២១ ។ បើលោកប្រធានអនុញ្ញាត ខ្ញុំ និយាយពីម្នាក់ៗ ។

[០៩:២៤:៤០]

ណារិត, ជុំ ណារិត ដូចខ្ញុំបានជម្រាបលោកប្រធានអំមិញហើយ គ្រួសារយើងក្រីក្រ ខ្ញុំបាន ទទួលអាហារូបករណ៍ទៅរៀនប្រទេសបារាំងនៅឆ្នាំ១៩៦០ដល់ឆ្នាំ១៩៦៨ បានបានមកប្រទេសខ្មែរយើង វិញ ។ កាលជំនាន់នោះ តែពេលណាយើងទៅរៀននៅស្រុកក្រៅអ៊ីចឹងហើយ គឺមិនដែលមកលេងស្រុក អីវិញបានដូចឥឡូវនេះទេ តែទៅហើយទាល់រៀនចប់បានមកវិញ ។ ខ្ញុំទៅនឹងប្រាំបីឆ្នាំ ក្នុងពេលប្រាំបីឆ្នាំ ដែលខ្ញុំនៅក្រៅស្រុកហ្នឹង ជុំ ណារិត ជាបង្គោលគ្រួសាររបស់ខ្ញុំ ។ ជុំ ណារិត ជាសិស្សពូកែ រៀននៅ វិទ្យាល័យយុគន្ធរ ។ កាលនុ៎ង *លីសេដេកាត* វិទ្យាល័យ *ដេកាត* និយាយបារាំង មាននយោបាយហៅយក អ្នកណាដែលរៀនពូកែឲ្យមករៀននៅ*លីសេដេកាត* ឲ្យអាហារូបករណ៍ ។ ដូច្នេះហើយបាន ជុំ ណារិត ហ្នឹងបានអាហារូបករណ៍មករៀនថ្នាក់ទីបញ្ចប់ មុននឹងបាក់ឌុបនឹងនៅ *លីសេដេកាត* ហើយមានលទ្ធ-

ភាពនឹងទៅស្រុកបារាំងបន្តទៅទៀត ក៏ប៉ុន្តែដោយសារខ្ញុំនៅស្រុកបារាំង ។ ដោយសារភាពខ្សត់ខ្សោយរបស់ឪពុកម្តាយខ្ញុំ ជុំ ណារិត ធ្វើពលីកម្មមិនយកអាហារូបករណ៍ទៅស្រុកបារាំង ចេញមកបាក់ឌុបចូលមកសាលាគរុកោសល្យវិទ្យាស្ថានជាតិគរុកោសល្យ ។ ចេញធ្វើជាគ្រូបឋមសិក្សាបឋមភូមិក្នុងឆ្នាំ ១៩៦៥ ឆ្នាំជាមួយគ្នានឹងជនជាប់ចោទ ។

ជុំ ណារិត នឹងក្នុងឋានៈជាចេញធ្វើការមុនគេ បងគ្រួសារយើងអ៊ីចឹង ត្រូវជួយផ្គត់ផ្គង់ដល់ឪពុកម្តាយខ្ញុំ ដល់ប្អូនខ្ញុំពីរនាក់ មួយស្រីមួយប្រុស មួយឈ្មោះ ជុំ ណារី ហើយរៀនទាល់ជាប់បាក់ឌុប ហើយឲ្យចេញធ្វើសាស្ត្របឋមភូមិដូចខ្លួនដែរ ។ ឧបត្ថម្ភដល់ប្អូនខ្ញុំពៅ ឈ្មោះ ជុំ ស៊ីណារ៉េត ឲ្យរៀនដល់បាក់ឌុប ហើយឲ្យចូលសាលាពេទ្យឆ្នាំ១៩៦៨ ។ ហើយពីឆ្នាំ១៩៦០ មកដល់ ៦៨ ខ្ញុំនៅស្រុកបារាំង ហើយឆ្នាំ១៩៦៤ ឪពុកខ្ញុំស្លាប់ ហើយកាលនោះខ្ញុំជម្រាបលោកប្រធានអំមិញ តែទៅហើយអត់មកវិញ តពេលស្លាប់ហ្នឹងក៏អត់បានមកធ្វើបុណ្យសពដែរ ។

[០៩:២៨:១១]

ដូច្នេះហើយ៦៨ ខ្ញុំមកវិញនៅម្តាយខ្ញុំ ជួបជុំម្តាយខ្ញុំ ហើយនិងបងប្អូន ខ្ញុំសប្បាយអស្ចារ្យ ។ ប្រហែលជាបានបីខែ បានបីខែ ស្រាប់តែប៉ូលិសនយោបាយពេលនោះ ឈ្មោះ *ប៉េ.អេស* (PS), *ប៉េ.អេស* គឺថា *ប៉ូលិសស្ពេសស្យាល់* ប៉ូលិសពិសេស ប៉ុន្តែគេហៅ ប៉ូលិសពិសេសផង គេហៅថា ប៉ូលិសនយោបាយផង ។ ក្រោមការដឹកនាំនៃរដ្ឋលេខាធិការពីរ មួយឈ្មោះ *សូស្តែនហ្វៃណង់ដេស* ខាងនគរបាលជាតិ មួយទៀតឈ្មោះ អ៊ុំ ម៉ាន់ណារិន ខាងហៅថា ការពារផ្ទៃប្រទេស មិនមែនការពារប្រទេសទេ ការពារលើផ្ទៃប្រទេស *ដេហ្វង់អង់សៀរហ្វាស* ។ ហើយ ប៉េ.អេស ហ្នឹងនៅក្រោមហ្នឹង ។ ឆ្នាំ១៩៦៨ ខ្ញុំមកដល់ភ្លាមនឹង គេចាប់ ណារិត ចោទថាខ្មែរក្រហម ។ ណារិត នឹងពេលហ្នឹងធ្វើជាគ្រូបង្រៀននៅអនុវិទ្យាបល្ល័ង្ក ខេត្តកំពង់ធំ ។ ហើយថ្ងៃមុននឹងខ្ញុំស្តាប់ ង៉ែ ម៉ម ណៃ, ម៉ម ណៃ និយាយថា គាត់នឹងក៏ធ្លាប់ធ្វើគ្រូនៅបល្ល័ង្កហ្នឹងដែរ ។ ចាប់នៅអនុវិទ្យាល័យបល្ល័ង្កហ្នឹងយកទៅដាក់នៅ ប៉េ.អេស ហើយខ្ញុំមកពីស្រុកបារាំងវិញនុ៎ង ។ ហើយម្តាយខ្ញុំ ម្តាយខ្ញុំនឹងគាត់មានជំងឺរ៉ាំរ៉ៃ ក្នុងខ្លួនហ្នឹងឈឺបេះដូង គាត់ភ័យស្លន់ ។ អត់មានឪពុកខ្ញុំមកជួយ គាត់ភ័យស្លន់ ប្រាប់ថាកូនត្រូវជួយប្អូនឲ្យរួច ។ កាលនុ៎ងបើគេចាប់ទៅ ប៉េ.អេស ហើយ គេតែងតែវាយសួរចម្លើយ ខុសត្រូវមិនដឹងទេគេវ៉ៃសិន ។ ហើយមានពាក្យចចាមអារ៉ាមហ្នឹងខ្ញុំនឹងច្បាស់មិនច្បាស់ទេ ឮថា មានអាខ្លះហ្នឹង គេទៅទម្លាក់ពីភ្នំពេញនៅជួរភ្នំទៀត ។ ហើយគាត់ភ័យសម្បើមណាស់ ហើយខ្ញុំក៏រត់រកគ្នីគ្នា ប្រកួកហៅពួកម៉ាក បងប្អូន រួចកាលនោះ លោក វណ្ណ

មូលីវណ្ណ ជារដ្ឋមន្ត្រីក្រសួងអប់រំ គាត់ជារដ្ឋមន្ត្រីក្រសួងលើក្រសួងអប់រំ ហើយបើគេចាប់គ្រួសារសម តែគាត់ នែ៎ជួយខ្ញុំ ទៅសុំជួបគាត់ ។ នឹកថាខ្លួនឯងមកពីស្រុកបារាំងថ្មីថ្មោង វិស្វករផង ច្បាស់ជាគេឲ្យជួបហើយ គ្រាន់តែសុំធ្វើម៉េចកុំវ៉ៃបានហើយ ។

វណ្ណ មូលវណ្ណ អត់ឲ្យជួប គាត់យកលេសសព្វគ្រប់ថាអ៊ីចេះអ៊ីចុះអីទៅ ។ រួចដល់រកណាស់ រកឡើងទៅ វាឃើញម្នាក់ឈ្មោះ សំ អន, សំ អន នឹងជាប៉ូលិស ។ ប៉ូលិសអ្នកសួរចម្លើយនៅកន្លែង ប៉េ.អេស ហ្នឹងតែម្ដង ។ រួច សំ អន ហ្នឹងវាធ្លាប់រៀននៅសាលាកុមារដ្ឋានដូចខ្ញុំនៅសំពងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។ រួចដោយសារ សំ អន ហ្នឹងគេជួយកែសម្រួលពាក្យចម្លើយអីទៅ ក៏អត់បានទទួលទារុណកម្មអីដែរ ហើយក្រោយមកប្រហែលជាមួយក្រោយមកចេញពី ប៉េ.អេស មក ហើយក៏គេបានឲ្យចូលទៅក្នុងក្រសួងសិក្សាធិការវិញ ហើយបានផ្លាស់ពីបល្ល័ង្គ មកនៅកន្លែងយើងចោមចៅនេះ នៅជិតកន្លែងមន្ទីរសវនាការនេះ ។ នេះនិយាយអំពី ជុំ ណារិត ។

[០៩:៣១:៥៨]

ហើយឆ្នាំ១៩៦៨ ពេលនោះភិតភ័យណាស់ លោកសាស្ត្រាចារ្យមហាបរិញ្ញា ភឹង គុន ក៏គេចាប់ពេលនុ៎ងដែរ ។ លោកសាស្ត្រាចារ្យ កេង វ៉ាន់សាក់ ក៏គេចាប់ពេលនុ៎ងដែរ ចៅ សៅ ប្រធានធនាគារក៏ចាប់ពេលនុ៎ងដែរ ។ ព្រាប អ៊ិន១ ដែលគេហៅថា អ្នកប្រឆាំងខាងស្ដាំ គេយកទៅ ពាក្យកាលនុ៎ងគេប្រើអ៊ីចឹង សូមទោសលោកប្រធាន គេហៅ យកបាញ់ចោល បាញ់ចោលជាសាធារណៈ ។ ហើយគេថតរូបយកទៅបញ្ចាំងនៅក្នុងកុនទៀត ហើយមនុស្សទៅមើលកុនហ្នឹងមិនបាច់ទេ ចេញមកវិញដេកលេងលក់បណ្ដោយ ។

ហើយពេលនោះ ហើយដែលគេចែកខ្មែរជាខ្មែរ មានខ្មែរក្រហម មានខ្មែរស មានខ្មែរខៀវ ។ ក្រោយមកដែលកម្ពុជាប្រជាធិបតេយ្យ ចែកមនុស្សថា កាហ្វេបេ, សេអ៊ីអា ឬមួយក៏វៀតណាមនិយម បើមិនអ៊ីចឹងទេ គេចែកថាប្រជាជនចាស់ ប្រជាជនថ្មី គឺយើងមានទម្លាប់ចែកគ្នាអ៊ីចឹងតាំងពីនុ៎ងមក អត់មានអីប្ដូរផ្លាស់ប៉ុន្មានទេ ។ រួចកាលដែលគេចាប់ ណារិត, ណារិត ដូចបញ្ញវន្តពេលនុ៎ងច្រើនគ្នាណាស់ តែងតែមាននិន្នាការខាងឆ្វេង ឬមួយគេហៅថា ជឿនលឿននិយម រួចមិនមែនតែនៅស្រុកយើងទេ ខ្ញុំកាលនោះនៅស្រុកបារាំង មានព្រឹត្តការណ៍គេហៅថា ឧសភា ៦៨ នៅបារាំងថា *មេ ស្វ៉ាសង់វីត* មានអ៊ីចឹងកាលនុ៎ង គឺម៉ូត ដូចថា ម៉ូត ក៏បាន ម៉ូតដូចថាយើងពាក់ខោអាវ ។ ថ្ងៃម៉ូតនេះដូចថ្ងៃមុន ម៉ូតកាលនុ៎ង គឺថានៅខាងឆ្វេងអ៊ីចឹងតែម្ដង ។ មានមិនមែនគ្រាន់តែឆ្វេងទេ ម៉ៅនិយមទៀតនៅស្រុកបារាំង មាន

ម៉ៅនិយមទៀត ហើយនៅស្រុកខ្មែរយើងក៏តែរបៀបគ្នាអ៊ីចឹងដែរ ។ គឺបញ្ហាច្រើនតែខាងឆ្វេង ហើយខាងឆ្វេងហ្នឹងបានសេចក្ដីថាម៉េច? បានសេចក្ដីថា ទីមួយប្រឆាំងនឹងសង្គ្រាមវៀតណាម អ៎! ប្រឆាំងនឹងសង្គ្រាមអាមេរិក វៀតណាម ដែលថាគេគាំទ្រវៀតណាម ។

ទីពីរ គឺថាប្រឆាំងអយុត្តិធម៌សង្គម ចង់ធ្វើម៉េចឲ្យមានយុត្តិធម៌សង្គម ។ ហើយក្នុងឋានៈជាសាស្ត្រាចារ្យហ្នឹង ណារិត គឺគិតណាស់អំពីអនាគតរបស់យុវជន ។ ចេញមកគ្មានការធ្វើ ហើយខ្លួនឯងនឹងមិនសូវប៉ានៅហ៊ឺហាអីទេ គិតតែពីរៀនសូត្រ ពីព្រោះការរៀនសូត្រហ្នឹងដូចជាឪពុកម្ដាយយើងបានប្រដៅមក ។ ការរៀនសូត្រហ្នឹងហើយ ដែលរុញឲ្យយើងឡើងនៅក្នុងសង្គម ។ ពួកឆ្វេងខាងនោះតែងតែទិតៀនបក្សពួកនិយម មានបក្សពួកនិយម ទិតៀនបក្សពួកនិយមអ៊ីចឹង ។ ហើយដូច្នេះហើយបាន ណារិត ហ្នឹង ក៏ដូចគេដូចឯងអ៊ីចឹងទៅ ។

ប៉ុន្តែ ការចាប់ចងដោយអយុត្តិធម៌នៃនគរបាលនយោបាយពេលនោះ ប៉ូលិស*ប៉ូលីទីក* (Politic) ពេលនោះ បានរុញ ណារិត រឹតតែចូលទៅស៊ប់ក្នុងចលនាប្រឆាំងរបបពេលនោះ ដែលសម្ដេចសីហនុហៅថាចលនាខ្មែរក្រហម ។ អ៊ីចឹងបានជាប់ពាក្យខ្មែរក្រហមពីពេលនោះមក ហើយចលនាខ្មែរក្រហមនេះហើយ ដែលបានឈ្នះនៅក្នុងឆ្នាំ១៩៧៥ ។ ដូចខ្ញុំនិយាយអំមិញហ្នឹង ក្រោយចេញពីផ្ទះគុករបស់*សុហ្វស្ដែម* មក ណារិត បានមកធ្វើការនៅចោមចៅ ។

[០៩:៣៦:៤៧]

ឥឡូវនិយាយអំពីប្អូនខ្ញុំ ជុំ ស៊ីណារ៉េត ម្ដង ។ ជុំ ស៊ីណារ៉េត កើតឆ្នាំ១៩៤៨ ពេលដែលគេចាប់យកទៅក្នុងឆ្នាំ១៩៧៦ គឺអាយុ២៨ឆ្នាំ ។ ស៊ីណារ៉េត រៀនថ្នាក់ទីពីរពេលនោះ នៅមហាវិទ្យាល័យពេទ្យនៅទីក្រុងភ្នំពេញ ដល់ឆ្នាំ១៩៧០ ព្រឹត្តិការណ៍១៨ មីនា សម្ដេចសីហនុ ត្រូវធ្លាក់ពីតំណែង សង្គ្រាមក៏បានកើតឡើង ។ ម្ដាយយើងខ្ញុំនៅស្គន់ ដោយសារមានអសន្តិសុខខ្លាំងពេក ក៏បានមកនៅភ្នំពេញ នៅជាមួយខ្ញុំ ហើយបាន ស៊ីណារ៉េត ហើយជាអ្នកបម្រើគាត់ ។ ម្ដាយខ្ញុំឈឺជំងឺបេះដូងរ៉ាំរ៉ៃម្ភៃឆ្នាំ មុននឹងស្លាប់ ។ ស៊ីណារ៉េត ជាអ្នកបម្រើ ហើយគេធ្វើពេទ្យ គេមានមិត្តភក្ដិអីចេះជួយបម្រើគាត់ ។ ចេញពីរៀនមិនដែលដើរលេងណាទេ មកមើលម្ដាយសិន ។

ហើយមួយទៀត ចេះនិយាយកំប្លែងអី ឲ្យម្ដាយខ្ញុំធូរចិត្តនៅពេលណា គាត់ពិបាកគាត់អី ។ រួចណារិត និង ស៊ីណារ៉េត ហ្នឹងត្រូវរ៉ូវគ្នាណាស់ ដូចពួកម៉ាកអ៊ីចឹងមិនមែនគ្រាន់តែជាបងប្អូនទេ ដូចពួកម៉ាកអ៊ីចឹង ។ អាមួយកំប្លែង អាមួយសើច ។ ទោះជាកំប្លែងហ្នឹងមិនគួរឲ្យសើចក៏ដោយ មានអ្នកចាំ

សើចឲ្យ ។ ហើយ ណារិត ហ្នឹងជាអ្នកផ្គត់ផ្គង់ ទោះជាខ្ញុំមកវិញ មានការងារធ្វើ មានឋានន្តរស័ក្តិអីក៏ដោយ ក៏ ណារិត ហ្នឹងនៅតែជួយផ្គត់ផ្គង់ម្តាយយើងខ្ញុំអីចឹងដែរ ។ យើងរស់នៅបានសុខសប្បាយអីចឹង ប៉ុន្តែសង្គ្រាមកាន់តែរីកខ្លាំងឡើងៗ ។

ចំនួនប្រជាជនពេលនោះ កាលពីដើមមានប្រហែលជាសាមសិបម៉ឺននាក់ទេ បីរយពាន់-- សាមសិបម៉ឺន ក្រោយមកមានប្រហែលជាមួយលាន ។ ជីវភាពពិបាកដុនដាប ពិបាកឡើងៗ មានរ៉ុក្កែតធ្លាក់សឹងតែរាល់ថ្ងៃ ។ មុនដំបូងធ្លាក់មួយៗទេ ក្រោយមកធ្លាក់សឹងតែរាល់ថ្ងៃ សាំងម៉ូតូ សាំងរថយន្តអីជួនមាន ជួនគ្មាន អគ្គិសនី ព្រោះចាតឡូវថា ដាច់យើង នៃទិតៀនថា អគ្គិសនីសព្វថ្ងៃដាច់ ។

សូមជម្រាបថា អគ្គិសនីកាលឆ្នាំ១៩៧៥ហ្នឹង គឺថាដាច់សឹងតែរាល់ម៉ោង អឺ! ៧១, ៧២ ហ្នឹងដាច់សឹងតែរាល់ម៉ោង ។ ធ្ងន់ជាងមុនទៅទៀត ហើយគ្រួសារយើងហ្នឹង គឺថានៅរស់ជុំគ្នា ខិតខំជួយថែរក្សាគ្នាទៅវិញទៅមក ទាំងយប់ ទាំងថ្ងៃ ម្តងនាំគ្នាទៅដេកកន្លែងនោះ ម្តងនាំគ្នាទៅដេកកន្លែងនោះ ក្រែងលោវាមានរ៉ុក្កែតធ្លាក់ពីលើ ។

ហើយក្នុងគ្រួសារមួយ និយាយឲ្យអស់ទៅចួនកាលមាននិន្នាការខុសគ្នា បងខ្ញុំហ្នឹងគាត់ បងសារុន--ជុំ សារុន ហ្នឹង គាត់ខាងសាធារណរដ្ឋទៅ ។ ណារិត ហើយនិង ស៊ីណារ៉េត គឺថារណសិរ្សរួបរួមជាតិ គេហៅត្រង់នុំង "រណសិរ្សរួបរួមជាតិកម្ពុជា" ហ្នឹង គឺបានន័យថា សម្ព័ន្ធភាពរបស់សម្តេចសីហនុ ហើយនិងខ្មែរក្រហម ។ ឬមួយគេហៅថា "ពួករំដោះ" កាលនុំងទៅ ។ ក៏ប៉ុន្តែមិនមែនខុសត្រូវគ្នាប៉ុន្មានដែរ យើងខ្ញុំក៏មិនមែនជាអ្នកនយោបាយអីធំដុំ មានឈ្មោះល្បីឈ្មោះអីទេ ។ បន់ឲ្យតែចប់សង្គ្រាមៗនឹងន្ទាលនាំគ្នាធ្វើការរកស៊ីទៅវិញ ។ ក៏ប៉ុន្តែ សង្គ្រាមរីតតែខ្លាំងទៅៗ ។

រួចនៅឆ្នាំនៃ ខែកុម្ភៈ ឆ្នាំ១៩៧៣ ក្រោយពីបានឈឺរ៉ាំរ៉ៃមានរោគបេះដូងចំនួនម្ភៃឆ្នាំ ម្តាយខ្ញុំបានទទួលមរណភាព ។ គាត់ដួលនៅក្នុងបន្ទប់ទឹក ហើយដកដង្ហើមលែងកើត ហើយ ណារិត ហ្នឹងគាត់មិនទាន់អស់សង្ឃឹមទេ គាត់រត់ឆ្កេឆ្ការរកពេទ្យនេះពេទ្យនោះឲ្យគេមកជួយ មួយយប់ គាត់ស្លាប់ទៅ ។ នេះដាច់ខែកុម្ភៈ ១៩៧៣ ហើយឆ្នាំ១៩៧៣ហ្នឹង មានព្រឹត្តិការណ៍ធំ នៅវិទ្យាស្ថានគរុកោសល្យ គេហៅ "វិទ្យាស្ថានគរុកោសល្យខាងត្បូង" នៅជិតខាងវិមានឯករាជ្យយើងនេះ ។ មានការបាតុកម្ម កូដកម្ម បះបោរនៃគ្រូបង្រៀន សាស្ត្រាចារ្យ ទាមទារប្រាក់បៀវត្សរ៍ ។ រួចប្អូនខ្ញុំ មានប៉ូលិស-- មកដល់នេះខាងសាធារណរដ្ឋ នគរបាលខាងសាធារណរដ្ឋ ចោទថា ជាមេដឹកនាំបាតុកម្ម រកចាប់ ។

[០៩:៤៣:០៩]

ថ្ងៃ១៧ មីនា, ថ្ងៃ១៧ មីនា អ៊ីចឹង ម្តាយខ្ញុំស្លាប់ដាច់ខែកុម្ភៈ ដល់ថ្ងៃ១៧មីនា មានយន្តហោះមួយមាន ពេជ លឹមឃួន ១ ជាអ្នកបើកបរយន្តហោះនៅខាងទ័ពសាធារណរដ្ឋហ្នឹង បើកយន្តហោះទៅទម្លាក់គ្រាប់បែកនៅវិមានរដ្ឋនៃសេនាប្រមុខ នៃលោកសេនាប្រមុខ លន់ នល់ ។ រួចហើយថ្ងៃហ្នឹង វាចលាចល់គ្រប់គ្នា ប៉ូលិសរកចាប់ប្អូនខ្ញុំមែនទែន ។ ហើយប្អូនខ្ញុំក៏រត់ចូលទៅក្នុង កាលហ្នឹងគេហៅ បើដូចស្រុកគេហៅរត់ចូលព្រៃម៉ាគី រួចកាលហ្នឹង បើសិននៅខាងព្រៃ គេហៅថា អាហ្នឹងចូលមករំដោះ ចូលមកតំបន់រំដោះ ។ រត់ចូលព្រៃទៅ ហើយបើតាមខ្ញុំស្រាវជ្រាវមក ខ្ញុំនឹងជម្រាប ម៉េចបានខ្ញុំស្រាវជ្រាវទៅឃើញអ៊ីចឹង គឺរត់ទៅ ចូលទៅកាលនុ៎ង ចូលទៅជាមួយសាស្ត្រាចារ្យមួយទៀត ឈ្មោះ នួន ខឿន ល្បីឈ្មោះដែរ។ ចូលទៅនៅជាមួយ ហ៊ូ នឹម តាមខ្ញុំស្រាវជ្រាវមើលទៅ ។ ហ៊ូ នឹម ហ្នឹងគាត់ទទួលបន្ទុកកាលហ្នឹងមិនទាន់ថា ឃោសនាការទេ គ្រាន់តែជាព័ត៌មានឃោសនាការអ៊ីចឹងចុះ ។ ហើយប្អូនខ្ញុំទៅនៅជាមួយ ហ៊ូ នឹម ហ្នឹង ទទួលបន្ទុកឃោសនាការ, ជាមួយ ហ៊ូ នឹម ដែលទទួលបន្ទុកឃោសនាការ ។ នៅក្នុងម៉ាគីអ៊ីចឹងចុះ កុំថាតំបន់រំដោះអី ។

[០៩:៤៤:៤៦]

តាំងពីខែមីនា ឆ្នាំ១៩៧៣ រត់ចូលទៅព្រៃអ៊ីចឹងទៅ តាមខ្ញុំមើលទៅ ប៉ុននេ៎-- ខ្ញុំៗមិនដឹងច្បាស់ទេ គ្រាន់តែប្រហែលជានៅតែមានការទាក់ទងជាមួយគ្នា ជាមួយ ជុំ ស៊ីណារ៉េត អ៊ីចឹង ព្រោះកាលហ្នឹងសុទ្ធតែលាក់ការណ៍ទាំងអស់គ្នា មិននិយាយទេ ប្រហែលជានៅតែមានអ្នកជួបទាក់ទងគ្នាអ៊ីចឹង ។ ហើយពេលហ្នឹងដាច់ឆ្នាំ៧៣ បងខ្ញុំឈ្មោះ ជុំ សារុន ហ្នឹងស្លាប់ ហើយពេលនោះ ខ្ញុំបានទទួលសំបុត្រមួយចេញពីម៉ាគី មករបស់ ជុំ ណារិត ហ្នឹង បាននិយាយពីទុក្ខសោករបស់ខ្លួន ដែលមិនបានមកចូលរួមក្នុងពិធីធ្វើបុណ្យបងខ្ញុំនោះ ។ ហើយបើតាមខ្ញុំមើលទៅនៅតាមសម្តីសំដៅនៅក្នុងសំបុត្រនោះ ខ្ញុំអាចនឹងឃើញថា មិននិយាយទេ ប៉ុន្តែខ្ញុំអាចនឹងឃើញថា មិនមែនជាស្រួលប៉ុន្មានទេនៅក្នុងតំបន់រំដោះនោះ មិនសូវជាស្រួលប៉ុន្មានទេ ។

ឆ្នាំ៧៤ ខ្ញុំនឹងនិយាយខ្លីៗ កុំឲ្យលោកប្រធាន លោក លោកស្រីអស់ចៅក្រមធុញពេក ។ ឆ្នាំ៧៤ មានព្រឹត្តិការណ៍មួយគួរឲ្យជាសោកនាដកម្មមួយ ប្អូនខ្ញុំ ជុំ ស៊ីណារ៉េត ហ្នឹងមានសង្សារ កាលហ្នឹងគេហៅ "សង្សារ" មិត្តនារីម្នាក់នៅកំពង់ចាម ហើយសង្សារពេលនុ៎ង មិនមែនដូចពេលឥឡូវទេ សង្សារពេលនុ៎ង គឺថាស្រឡាញ់គ្នាតែចិត្តទេ ។ ពាក្យបារាំងហៅថា *អាម៉ួរផ្លាតូនិច* (សូមទោសអ្នកបកប្រែ)

*អាម៉ូរវ្គាតូនិច(និយាយភាសាបារាំង)* នៅកំពង់ចាម ហើយទៅមករកគ្នាអ៊ីចឹង ។ ប៉ុន្តែ ដល់ពេលមានសង្គ្រាមទៅ អាផ្លូវហ្នឹងវាដាច់ ដូច្នេះហើយលែងទៅមករកគ្នាបាន ។

ស្រាប់តែថ្ងៃមួយរ៉ុក្កែត ធ្លាក់នៅទីរួមខេត្តកំពង់ចាម នាងហ្នឹងត្រូវប៉ះជើង រួចដល់ជង្គង់ ហើយគ្រូពេទ្យពេលហ្នឹងថា ត្រូវតែកាត់ បើមិនកាត់ទេ វាអាចឡើងជំងឺ *ហ្គង់គ្រែន* ឡើងមកដល់បេះដូងបាន ។ រួច ជុំ ស៊ីណារ៉េត ហ្នឹង នៅភ្នំពេញហ្នឹងឆ្ពោទៀតហើយ តេឡេហ្វូនចុះឡើង ប៉ុន្តែពេលនោះយើងមិនអាចបន្ទោសវេជ្ជបណ្ឌិតបានទេ វាគ្នាថ្នាំសង្កូវទេ រួចជាដឹងជាអាថ្នាំដាក់ស្ពឹកហ្នឹង មិនដឹងមាន ដឹងគ្មានផងហ្នឹង ហើយពេលដែលកាត់ហ្នឹង ក៏នាងស្លាប់ទៅ។ នេះគឺជាសោកនាដកម្មមួយធំរបស់ ស៊ីណារ៉េត។

ដាច់ឆ្នាំ១៩៧៤ ខ្ញុំបានទទួលតំណែងធ្វើជាតំណាងកម្ពុជានៅហ្សឺណែវ ទទួលបន្ទុកក្នុងអង្គការជំនាញបី មានអង្គការសាកលខាងប្រៃសណីយ៍ បារាំងហៅថា *អ៊ុយញ៉ុង ប៉ូស្តាល់ អ៊ុយនីវែរសែល* (Union Postal Universal) មានអង្គការអន្តរជាតិ ខាងទូរគមនាគមន៍ បារាំងហៅថា *អ៊ុយញ៉ុង អាំងទែរណាស្យូណាល់ ដេតេឡេកុំម៉ុយនីកាស្យុង* (Union International Des telecommunication) ហើយនិងអង្គការថាមពល *បរម៉ាណូ* ហៅកាត់ថា I.A.E.A (Agent international de l‘ energy Atomic) *(និយាយភាសាបារាំង)* ។ ខ្ញុំទៅក្នុងខែវិច្ឆិកា ខែ១១ ឆ្នាំ១៩៧៤ ហើយនឹកថា បីបួនខែទៀតនឹងនាំ ស៊ីណារ៉េត ទៅ ចាំឲ្យទៅដល់ហ្នឹង មានផ្ទះ មានសម្ភៀងស្រួលបួល រៀបចំអីឲ្យស្រួលបួល ខ្ញុំនាំប្រពន្ធ ហើយនិងកូនខ្ញុំទៅមុន ។ រៀបចំឲ្យស្រួលបួលយក ស៊ីណារ៉េត ទៅ ។ ប្រាប់ថាឲ្យរៀបចំអីសព្វគ្រប់ ធ្វើ*ប៉ាស្ព័រ* ធ្វើអី ។

ដល់មេសា ៧៥ វាសនាបានសម្រេចផ្ទុយពីសេចក្តីសង្ឃឹមនេះ ។ អានេះជាវិប្បដិសារីមួយជីវិតរបស់ខ្ញុំ ។ ខ្ញុំពេលនោះមិនមានឈ្លាសវៃ មិនមានសុបិនិច្ឆ័យថា ប្រទេសយើងអាចនឹងធ្លាក់ក្នុងពេលបីបួនខែក្រោយ ប្រាំ-ប្រាំមួយខែដែលខ្ញុំចុះ ។ ខ្ញុំនឹកថានៅមានពេល អាហ្នឹងជាវិប្បដិសារី មួយជីវិតរបស់ខ្ញុំ ។

ក្រោយមកនេះ ខ្ញុំសុំជម្រាបអង្គជំនុំជម្រះតែពីលទ្ធផលនៃការស្រាវជ្រាវរបស់ខ្ញុំ។ ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តាមខ្ញុំស្រាវជ្រាវ ណារិត បានចូលមកភ្នំពេញជាមួយក្រុម ហ៊ូ នឹម ធ្វើការនៅក្រសួងឃោសនាការ ។ ថ្ងៃ៣០ មេសា ឆ្នាំ១៩៧៥ អង្គជំនុំជម្រះច្បាស់ជាដឹងហើយពេលនោះមានសោកនា-ដកម្មធំណាស់ នៅក្នុងបរិវេណនៃស្ថានទូតបារាំងប្រចាំប្រទេសកម្ពុជា ។ ខ្មែរ ទាំងខ្មែរ ទាំងបារាំង ទាំងបារាំងជាពិសេស ហើយខ្មែរដែលមានប្រពន្ធ ឬកូនជាបារាំង ហើយនិងឥស្សរជនធំៗខ្លះ បានរត់ទៅចូលសុំជ្រកកោននៅក្នុងបរិវេណនៃស្ថានទូតបារាំង ក្រោមការសម្ពាធពីអ្នកដែលកាន់អំណាចពេលនោះ គឺ

ពួកខ្មែរក្រហម លោកកុងស៊ុលបារាំងពេលនោះឈ្មោះលោក ឌៀរ៉ាក់, ហ្សង់ ឌៀរ៉ាក់ ខ្ញុំមិនហ៊ានថាពាក្យនិយាយថា ពាក្យបណ្ដេញទេ គាត់បង្ខំចិត្តបណ្ដេញអ្នកណាដែលមិនមែនបារាំង មិនមែនសញ្ជាតិបារាំងចេញពីបរិវេណនៃស្ថានទូតរបស់គាត់ បើមិនដូច្នោះទេគេបង្អត់បាយអ្នកដែលនៅក្នុងហ្នឹង ។

អ៎! ថ្ងៃក្រោយយើងអាចជជែកគ្នាទៅថា អ៎ យើងម៉េចក៏មិនប្រឆាំងឲ្យលើសពីហ្នឹងបន្តិចទៀតទៅ! អានេះជាភារកិច្ចរបស់អ្នកប្រវត្តិសាស្ត្រហើយ ឲ្យរកចុះ តើការសម្រេចនៅពេលនោះ មិនមែនលោក ឌៀរ៉ាក់ គាត់សម្រេចម្នាក់ឯងទេ គឺថាសម្រេចសុទ្ធតែមានមកពីក្រសួងការបរទេសនៃប្រទេសបារាំង ។ តើការសម្រេចរបស់នោះវាត្រូវតាមក្រមសិទ្ធិជ្រកកោនទេ? តាមក្រមកិត្តិយសទេ? អានេះជាភារកិច្ចរបស់អ្នកប្រវត្តិសាស្ត្រ ។

ក៏ប៉ុន្តែនៅពេលដែលចេញទៅនោះ ចេញទៅតាមផ្លូវទៅបាត់ដំបង មានសោកនាដកម្មធំណាស់នៅបាត់ដំបងក៏មានទៀត ។ ខ្ញុំមិនសូវមានពេល ប៉ុនកុំនិយាយច្រើនពេក ។ មានសោកនាដកម្មធំណាស់បានចេញទៅបាត់ដំបង ហើយចេញទៅដល់នែ៎ ប៉ារីសហើយខ្ញុំបានជួបមិត្តភក្ដិដែលធ្លាប់ស្គាល់នៅប្រទេសខ្មែរនេះ បារាំងដែលនៅធ្លាប់ស្គាល់ប្រទេសខ្មែរ គាត់បាននិយាយប្រាប់ខ្ញុំថា មិនបាច់គិតចង់ទៅស្រុកខ្មែរវិញទេ គេចាប់ពី *សឺទីហ្វិកាតដេអូត* គេហៅថានែ៎ សញ្ញាបត្របឋមភូមិទៅ គឺថាអ្នកឯងហ្នឹងជា មានកម្ពែលរបស់នែ៎បស្ចិមប្រទេសហើយ ហើយកម្លាំងតែអ្នកឯង ។ ហើយនែ៎ពេលនោះ នែ៎ៗប្អូនខ្ញុំ ប្អូន ជុំ ស៊ីណារ៉េត ហ្នឹងបានផ្ញើសំបុត្រមួយមកឲ្យខ្ញុំ ក្នុងហ្នឹងនិយាយខ្លីថា ខ្លួន ជុំ ស៊ីណារ៉េត ហ្នឹងដើរទៅមកបាននៅក្នុងភ្នំពេញ ក៏ប៉ុន្តែបងប្អូនទាំងអស់គេជម្លៀសអស់ទៅហើយ ។ មកដល់កន្លែងនេះខ្ញុំមានតែការប្រហែលទេ មិនដឹងច្បាស់ទេ ខ្ញុំប្រហែលថា ពេលនោះ ស៊ី ណារ៉េត ហើយ ណារិតបានជួបគ្នា ។ ហើយបើទោះតែជួបក៏ជួបគ្នាសប្បាយរីករាយ ហើយបើទោះជាសប្បាយរីករាយក៏តិចដែរ ពីព្រោះចូលមកឆ្នាំ៧៥ មេសា ៧៥ ដល់ថ្ងៃ២៩ តុលា ៧៦ ណារិត ត្រូវគេចាប់ ។ ហើយតាមខ្ញុំមើលទៅចាប់ទាំងនែ៎ ស៊ី ណារ៉េត ហ្នឹង ចាប់ទាំង ដន សុវណ្ណារី ហៅ ដន ហ្នឹងផង ។

[០៩:៥៥:១៦]

ហើយនែ៎មូលហេតុនៃការចាប់ខ្លួននេះ គឺយើងអាចឃើញនៅក្នុងសេចក្ដីសារភាពរបស់ ហ៊ូ នឹម ។ ហ៊ូ នឹម បានសរសេរថា សូមលោកប្រធានអនុញ្ញាត ខ្ញុំមើលខ្លីទេ ព្រុំ សំអារ, យិត គឹមសេង, យិត គឹមសេង ជាប្អូនថ្លៃ ហ៊ូ យន់ ។ ជុំ ណារិត, ត្រាន់ វេង បង្កើតក្រុមមួយដែលប្រឆាំងនឹងសម្ព័ហភាវនិយម ។ ក្នុងការប្រជុំសាធារណ ព្រុំ សំអារ មិនហ៊ាននិយាយទេ ទុកឲ្យ ជុំ ណារិត និយាយ ។

"ជុំ ណារិត ជាមនុស្សក្លាហាន គាត់បានចោទថាវិទ្យុយើង វិទ្យុកម្ពុជាប្រជាធិបតេយ្យ ភូតភរប្រជាជន ក្នុងកិច្ចជំនុំទូទៅមួយនៃក្រសួងឃោសនាការ ជុំ ណារិត ហៅ ណាក់ បានវាយប្រហារយ៉ាងខ្លាំងដល់សម្ហូហភាវនិយម ហើយនិងបណ្តាញសម្ហូហកសិដ្ឋាន ដោយអះអាងថា នេះជាមូលហេតុនៃការកង្វះថ្នាំព្យាបាល ខ្វះចំណីរអាហារ មិនអាចដាំបន្លែ រកត្រី ឬចិញ្ចឹមសត្វតាមឯកជនបាន ។ ជំហរប្រឆាំងនឹងសម្ហូហភាវនិយមនេះ ត្រូវបានទទួលការគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់មហាជនទូទៅ ។ ហើយ ហ៊ូ នឹម ក៏បាននិយាយថា ដោយសារអ៊ីចឹងហើយក៏គាត់បានសុំឱ្យអង្គការដក ជុំ ណារិត ទៅ ។ ក្រោយមកឃើញថា ដកហ្នឹង គឺថ្ងៃ២៩ ខែតុលា ឆ្នាំ១៩៧៦ ។

ខ្ញុំសូមរំឭកអង្គជំនុំជម្រះថា ពីថ្ងៃ២១ កក្កដា ៧៦ ទៅថ្ងៃ០៥ សីហា ១៩៧៦ ប៉ុល ពត បានធ្វើសុន្ទរកថាមួយស្តីពីផែនការប្រាំឆ្នាំ សម្ហូហភាវនិយម ។ ក្រោយមកបីខែ ប្អូនខ្ញុំត្រូវគេ ហ៊ូ នឹម វាថាដកត្រូវគេចាប់ ហើយ ហ៊ូ នឹម ខ្លួនឯងហ្នឹង ប្រាំមួយខែក្រោយដែលគេអាច គេៗឱ្យគេចាប់ប្អូនខ្ញុំ គឺនៅថ្ងៃ០៤ ខែមេសា ឆ្នាំ១៩៧៧ ក៏គាត់ គាត់និយាយថា គេចាប់ទេ គាត់និយាយក្នុងសារភាពគឺថា ខ្ញុំបានប្រគល់ខ្លួនខ្ញុំឱ្យទៅអង្គការ ។ ប្រគល់ខ្លួនឱ្យទៅអង្គការ បានសេចក្តីថា ឱ្យគេចាប់ ។ ប្រាំមួយខែក្រោយដែលគេឱ្យចាប់ប្អូនខ្ញុំ ។

លោកប្រធាន លោកស្រី អស់លោកចៅក្រម អាចនឹងសួរថាតើអាចជឿបានទេ អាហ្នឹងជាសក្ខីកម្មរបស់មនុស្សម្នាក់ ហ៊ូ នឹម ដែលនៅក្នុងនោះ មិត្ត ប៊ុន របស់ជនជាប់ចោទហ្នឹង បានរៃប្រាំដងហើយតាមដែល ប៊ុន គាត់សរសេរនៅលើចំណារគាត់ហ្នឹង រៃប្រាំដង ដូច្នេះហើយ ឆ្លើយសរសេរមក *អូខេ* គេយកបានហើយ យកជាការបានហើយសាធារណ ។ តើយើងហ្នឹងអាចជឿបានប៉ុន្មាន? ខ្ញុំគិតយូរទៅខ្ញុំថាអាចជឿបាន ពីព្រោះថា អារឿងមូលហេតុនៃការចាប់ហ្នឹង គេដឹងគេញគ្រប់គ្នាជាសាធារណៈ ព្រោះប្រជុំនៅឃោសនា រួចនិយាយនែ៎ប្រឆាំងនយោបាយរបស់ ប៉ុល ពត ប៉ូលិសរបស់លោក សុន សេនរបស់លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ច្បាស់ជាដឹងហើយ ។ ដូច្នេះហើយ ហ៊ូ នឹម មិនអាចនឹងមានវិចារណញ្ញាណអី នឹងទៅភរក្នុងរឿងហ្នឹង ។

[០៩:៥៩:១៩]

អានេះគឺថាជាការ ខ្ញុំមិនដឹងនិយាយថា នែ៎ៗពួកអ្នកបកបារាំង គេថា *អាំងទីនកុងវិចស្យុង* គឺថាការជឿជាក់នៅក្នុងចិត្តរបស់ខ្ញុំថាអ៊ីចឹង ។ ហើយមួយទៀត ហើយវាវាសមទីពីរ គឺថាសមហ្នឹង ចរិតរបស់ ណារិត ផង គឺដូចខ្ញុំអ៊ីចឹង មិនតែចង់និយាយអីនិយាយហើយ អត់ខ្លាចនរណាទេ ។ អ៊ីចឹងបានខ្ញុំ

ជឿអ៊ីចឹងបាន ។

លោកប្រធាន ជុំ ណារិត នៅឆ្នាំ១៩៩៣ ក្រោយពីបានរកដំណឹងសព្វទិសទី ខ្ញុំបានមកស្រុកខ្មែរវិញក្រោយពីបានបែកពីស្រុកយើង ១៩ឆ្នាំ ។ ខ្ញុំរកព័ត៌មានទាំងអស់សុទ្ធតែស្រពិចស្រពិលទាំងអស់ សុទ្ធតែមិនប្រាកដប្រជាទាំងអស់ ។

ខែតុលា ១៩៩៣ ខ្ញុំបានទៅគុកទួលស្លែង នៅក្នុងនោះ ខ្ញុំឃើញក្នុងបញ្ជីមួយ បញ្ជីរាយនាមមួយដាក់ថា "ក្នុងលេខ៣៩ ជុំ ណារិត ហៅ ណាក់ ការងារឃោសនាការ ចូលថ្ងៃ២៩ ខែ១០ ៧៦ ស្លាប់ថ្ងៃទី០១ ខែ០១ ៧៧ ក្រោយពីបាននៅក្នុងគុកនោះ ៦៥ថ្ងៃ ខ្ញុំរាប់ទៅឃើញ ៦៥ថ្ងៃទទួលទារុណកម្មព្រៃផ្សៃបន្ថោកបន្ទាបវិស័យមនុស្ស" ។ ហើយខ្ញុំមិនយល់អត់បានការអី ម៉េចបានចាំធ្វើអ៊ីចឹង បើចង់បើថានយោបាយថាឲ្យស្លាប់ ក៏សម្លាប់ទៅ! ម៉េចក៏ចាំបាច់ វ៉ៃដំច្រំធាក់ធ្វើអី? អ៊ំ អាចហ្នឹងថា អ្ហែ! វ៉ៃហ្នឹងដើម្បីឲ្យឆ្លើយដើម្បីរកព័ត៌មានឲ្យច្បាស់ មិនអ៊ីចឹងអី ជនជាប់ចោទនិយាយថាអ៊ីចឹង ។ រួចជនជាប់ចោទខ្លួនឯងហ្នឹង យល់ឃើញថាអាព័ត៌មានហ្នឹង អត់ពិតទេ ដែលចេញពីអាសារភាពក្រោយទារុណកម្មនេះ ។ ហើយអ៊ីចឹងវ៉ៃធ្វើអី ម៉េចក៏មិនសម្លាប់ទៅ?

ក្នុងបញ្ជីដដែលហ្នឹង ខ្ញុំឃើញប្អូនខ្ញុំ ជុំ ស៊ីណារ៉េត មុខងារពេទ្យគ្មានថ្ងៃចូល គ្មានថ្ងៃចេញទេមិនដឹងជាថ្ងៃស្លាប់ណាទេ មានឈ្មោះ គឹម សុវណ្ណារី ហៅ ដន ប្រពន្ធ ជុំ ណារិត ហើយវាសរសេរថា "អា" ទៀត មិនមែន ជុំ ណារិត ទេ វាសរសេរ "អា" នៅមុខហ្នឹងទៀត ។ ឃោសនាការ ហើយមិនបាច់និយាយទេ ពីទារក ខ្ញុំបានមើលរូបលោក វ៉ាន់ ណាត ។ លោកប្រធានអង្គជំនុំជម្រះអាចមើលឃើញហើយ រូបមួយដែលគេទៅទាញកូនខ្ចីពីម្ដាយ ពួកខ្មែរក្រហមឆ្មាំគុកហ្នឹង ទាញកូនស្រីពីម្ដាយ ហើយមានពួកម្ខាងទៀតហ្នឹង វ៉ៃម្ដាយដើម្បីកុំឲ្យទៅដណ្ដើមកូនពីនោះ ។ ក្មួយខ្ញុំច្បាស់ជាអ៊ីចឹងហើយ មិនដឹងជាវាយកទៅវ៉ៃនៅនឹងគល់ឈើ គល់ដើមឈើនៅជើងឯក ឬមួយវាទម្លាក់ចោលពីថ្នាក់ទីប៉ុន្មានទេ ។

[១០:០៣:៤៣]

លោកប្រធាន! តាំងពីថ្ងៃច័ន្ទ ដល់ខែនេះ ខ្ញុំជាមោទនភាពក្នុងជាតិខ្មែរ អង្គតុលាការយើងនេះបានឲ្យលទ្ធភាពមកជនរងគ្រោះដើម្បីនឹងនិយាយពីទុក្ខរបស់ខ្លួន ។ ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបាននិយាយមុនខ្ញុំ ដូចជា លោក ហាមីល ដូចជាលោកស្រី មាទីន លើហ្វឺរ ដូចជានាងកញ្ញា អ៊ុក នារី លោកស្រីជូឡុង សូម៉េរា លោកស្រី អ៊ឹម សុន្ទី ភឹង តុន លោកស្រី ស៊ុនថារីហ្គុត បានរាប់រៀបពីដំណើរពីផ្លូវដ៏យូរអង្វែង ដើម្បីស្វែងរកការពិតលើវាសនានៃអ្នកដែលជាទីស្នេហារបស់ខ្លួនម្នាក់ៗ ។ រឿងនីមួយៗ

សុទ្ធតែខុសពីគ្នា ក៏ប៉ុន្តែរឿងដែលដូចគ្នា ហើយដែលដូចរឿងខ្ញុំដែរ គឺមនោសញ្ចេតនាអស់សង្ឃឹម មនោសញ្ចេតនាមិនយល់ មនោសញ្ចេតនាទុក្ខវេទនាគ្មានព្រំដែន រយៈសាមសិបឆ្នាំហើយ ជាងសាមសិបឆ្នាំហើយ ។

[១០:០៥:០០]

ខ្ញុំតស៊ូជាអចិន្ត្រៃយ៍រាល់ថ្ងៃរាល់យប់ កុំឲ្យភ្លេចនូវទុក្ខវេទនារបស់បងប្អូនខ្ញុំ ពីព្រោះនេះគឺជាកាតព្វកិច្ចរបស់ខ្ញុំចំពោះអ្នកដែលស្លាប់ទៅ ។ ក៏ប៉ុន្តែទន្ទឹមគ្នានោះ ខ្ញុំតស៊ូចង់បំភ្លេចៗ ពីព្រោះថាជាកាតព្វកិច្ចដែលរស់នៅជាមួយខ្ញុំមិនមែនស្រួល រស់នៅជាមួយអ្នកដែលមានទុក្ខដូចខ្ញុំនេះ ហើយរវាងអាកប្បកិរិយាទាំងពីរនេះសាមសិបបួនឆ្នាំហើយ ដែលខ្ញុំមិនដឹងថាខ្ញុំយកអាកប្បកិរិយាណាមួយ ហើយសង្ឃឹមថា នៅមុខតុលាការយើងនេះ ខ្ញុំនឹងទទួលយុត្តិធម៌ ។ ក្នុងតុលាការយើង រហូតមកដល់ថ្ងៃនេះ ខ្ញុំសូមមានសរសេរសំបុត្រទៅលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ឲ្យព័ត៌មានពីរឿងប្អូនខ្ញុំ គាត់ថា "អត់ អ្ហ គាត់អត់ទេៗ" ។

[១០:០៦:១៤]

ហើយខ្ញុំសូមជម្រាបថា លោកប្រធាន! កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះ រៀនជាមួយប្អូនខ្ញុំនៅសាលាគរុកោសល្យ ។ កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះ ម្សិលមិញថា "ការប៉ះបោរនៅស៊ីសុវត្ថិជាមួយ ជុំ ណារិត ដែរ" ។ កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះ បានជួប ជុំ ណារិត នៅតំបន់រំដោះនៅម៉ាគី ។ ចំពោះ ស៊ីណារ៉េត វិញ កាលនៅស្គន់ ជនជាប់ចោទធ្វើជាសាស្ត្រាចារ្យនៅស្គុន ជុំ ស៊ីណារ៉េត មិនមែនកូនសិស្សរបស់គាត់ទេ ឪពុកម្ដាយរបស់ខ្ញុំនៅស្គន់ ចុះឡើង ជុំ ស៊ីណារ៉េត ហ្នឹង ដោយសារស្រឡាញ់បញ្ញវន្តស្អាតស្អំ មានឧត្តមគតិ ឡើងចុះផ្ទះរាល់តែ-- មិនមែនរាល់តែថ្ងៃទេ ញយញឹកញយ ។ ដូច្នេះ គាត់ស្គាល់ច្បាស់ណាស់ រួចហើយដល់ថ្ងៃដែលចូលក្នុងស-២១ គាត់ថា "គាត់អត់ដឹងទេ ។ គាត់រវល់ធ្វើចំណារលើសេចក្ដីសារភាពរាល់តែថ្ងៃហ្នឹង គ្មានពេលទេៗ ។ អត់ដឹងទេ បើដឹងខ្ញុំប្រាប់ហើយ" ដូចនិយាយម្សិលមិញ "បើដឹងថា បង ភឹង តុន នៅគាត់ឲ្យបាយហើយ ។ គាត់អត់ដឹងទេ ។" អានេះ ខ្ញុំមិនជឿជាដាច់ខាត ។

ខ្ញុំសូមនិយាយមួយរឿងមួយទៀត ជនជាប់ចោទ ហៅ ឌុច ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច តែងតែនិយាយថាគាត់ហ្នឹងជាកូនចៅគេទេ មិនមែនជាអ្នកដឹកនាំធំដុំទេ ហើយគាត់ធ្វើតាមតែបញ្ជាគេទេ ។ រួចខ្ញុំចេះគិតថា បើសិនជាគាត់ធ្វើតែតាមបញ្ជាគេទេ រឿងអីក៏យើងទៅថា គាត់អ្នកទទួលខុស

ត្រូវរឿងបងប្អូនយើងនេះ ។ ខ្ញុំយកឧទាហរណ៍ទៅចុះថា ដូចយើងថា មេគុកអ៊ីចឹង មេគុក រួចតុលាការគេបញ្ជូនទៅទេ បើកាល ឌុច ពួកគណៈ-- ពួកកុម្មុយនីស្ត-- ពួកគណបក្សកុម្មុយនីស្តខ្មែរហ្នឹង បញ្ជូនទៅទេ ។ គាត់ជាមេគុកទេ ហើយបើគុកតាមនយោបាយគុកទៅសម្លាប់ រឿងអីបានថាគាត់ៗជាអ្នកទទួលខុសត្រូវក្នុងរឿងប្អូនខ្ញុំទាំងពីរនាក់ ហើយប្អូនថ្លៃខ្ញុំម្នាក់ ហើយនិងក្មួយខ្ញុំហ្នឹង ។ អានេះ ជាបញ្ហាចម្បង បញ្ហាទ្រូង បញ្ហាកណ្តាល នៃតុលាការយើងនេះ ។

[១០:០៩:២៧]

ខ្ញុំសូមឆ្លើយ។ ទីមួយ ខ្ញុំដូចខ្ញុំនិយាយអំមិញហ្នឹង រឿងអីបើថា នយោបាយថាសម្លាប់ ហើយយកទៅសម្លាប់ទៅ ម៉េចចាំបាច់ធ្វើទារុណកម្មធ្វើអី? ហើយថាសួរចម្លើយយកចម្លើយ ក៏ប៉ុន្តែចម្លើយយើងអត់ជឿដែរ ធ្វើៗអី? អាហ្នឹងទីមួយ ។

ទីពីរ ដេវីដ ឆេនដ័ល័រ គាត់បានធ្វើសក្ខីកម្មនៅកន្លែងនេះស្រាប់ គាត់និយាយថា ឌុច ហ្នឹង តាមដែលគាត់មើលសេចក្តីចំណាររបស់គាត់ហ្នឹង គាត់អត់មានដែលដូចថា ដេកមិនលក់បក់មិនល្ហើយទេក្នុងប៉ុន្មានឆ្នាំដែលធ្វើជាមេគុកទួលស្លែង មិនអ៊ីចឹងអេ្ហ? ដូចថាយើងមើលទៅថា អាកិច្ចការហ្នឹងយើងមិនចូលចិត្តទេ សម្លាប់គេវាច្រើនពេកទៅវិញដេកមិនលក់ ស៊ីបាយមិនចូល ។ អត់ទេ គាត់មានការសប្បាយចិត្តនឹងធ្វើការហ្នឹង រហូតមកដល់ដែល វន វ៉េត ចូល ចុងឆ្នាំ៧៨ អាហ្នឹងទីពីរ ។

ទីបី ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ហ្នឹង បានប្រដូចខ្លួនឯង ទៅជានឹងឆ្កែចចក នៅក្នុងកំណាព្យរបស់លោក អាល់ ហ្វែតឌឺហ្វីញី ឈ្មោះថា “មរណភាពនៃឆ្កែចចក” ។ ខ្ញុំសូមរំឭកថា លោក អាល់ ហ្វែតឌឺហ្វីញី ហ្នឹង ជាកវីបារាំងមួយនៅជំនាន់សតវត្សរ៍ទី១៩ គាត់ជាទាហាន ហើយគាត់កាលហ្នឹងមានចម្បាំងរបស់អធិរាជ ណាប៉ូឡេអុង ច្រើនណាស់ ។ ដូច្នេះហើយ អ្នកដែលធ្វើទាហានហ្នឹង វាមានសប្បាយ វាមានពិបាក ។ គាត់សរសេរច្រើនណាស់ ពីរឿងសប្បាយ ហើយនិងពិបាករបស់ទាហានហ្នឹង ហើយគាត់បានសរសេរពីកំណាព្យ “មរណភាពនៃឆ្កែចចក”នេះ ។ ហើយ “មរណភាពនៃឆ្កែចចក” នេះ គាត់និយាយថា មានអ្នកបរបាញ់មួយក្រុម នាំឆ្កែស្រុកៗអ្នករកបាញ់យ៉ាងតិចក៏ដប់ម្ភៃដែរ ។ ហើយទៅលបស្ទាក់ឆ្កែចចក ។ ឆ្កែចចកហ្នឹងវាមានគ្នាបួននាក់ មានឈ្មោលមួយ មានញីមួយ ហើយនិងមានកូនពីរនាក់ កូនពីរ ។ រួចហើយដឹងដល់គេមកលបស្កាត់អ៊ីចឹងហើយ រត់ទៅណាមិនរួច ហើយក៏ខំតស៊ូឆ្កែស្រុកហ្នឹងចូលទៅខាំ ខាំហ្នឹងឆ្កែចចកខាំតបទៅវិញ ដើម្បីការពារឆ្កែចចកញី ហើយនិងកូនឆ្កែចចក ពីរហ្នឹង ។ រួចហើយដល់គេមានប្រៀបខាងចំនួនហ្នឹងច្រើនពេកទៅ ឆ្កែចចកហ្នឹងមិនដឹងធ្វើ

ម៉ែចក៏សុខចិត្តស្លាប់ ក៏ត្រូវស្លាប់ទៅ ហើយពេលដែលស្លាប់ហ្នឹង មីញ៉ីសរសេរថា ស្លាប់ដោយអត់មានស្រែកមួយម៉ាត់ ។ សូមទោសអ្នកបកប្រែ *មឺរសង់ហ្សឺតែអង់គ្រី* ។ ហើយមេរៀនដែលលោក អាល់ហ្វ៉ែតឌឺហ្វីញី បានទាញមកពីរឿង "មរណភាពនៃឆ្កែចចក" នេះនៅចុងក្រោយកំណាព្យ ដែលលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច បានសូត្រនៅថ្ងៃ៣១ បើខ្ញុំមិនភ្លេចទេ ថ្ងៃ៣១ ខែមីនា ២០០៩ ។ ហើយគាត់សូត្រហ្នឹង ប្រហែលជាម៉ោងបួនកន្លះថ្ងៃរសៀលពេលដែលយើងជិតចប់សវនាការ ។ ក្រោមការសួររបស់លោក ហ្វ្រង់ស្វ័រ រូ ។ ស្អាយថ្ងៃហ្នឹង គាត់មិនមក ។

[១០:១៣:៤២]

ហើយលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ហ្នឹង សូត្រកំណាព្យ *(សូត្រជាភាសាបារាំង) "ហ្វែមៀរភ្លឺវេ ព្រីយេសេទីហ្កាល់ម៉ង់ឡាស ហ្វេអេហ្សាកាម៉ង់តាលុង អេល្លូក ដឺប៉ាស់ ដង់ឡាវ៉ែ អូឡឺស័រ អាវ៉ូលុយ តាប់ពើលេ អេ អាប្រែ កុំម័រ សូហ្វឺអេមឺសង់ប៉ាក្លេ"* ប្រែថា *"ហើយលោកត្រូវតែរងកម្មហើយនិងស្លាប់ ដោយគ្មាននិយាយមួយម៉ាត់ ។"*

ខ្ញុំស្មានតែលោកប្រធាននិយាយជាមួយខ្ញុំ ។ ពាក្យជាខ្មែរថា ថ្ងូរ យំ អង្វរ សុទ្ធតែជាកំសាកទាំងអស់ ។ គិតតែធ្វើការខ្លួនយើងទៅ តាមតែព្រហ្មលិខិតយើងហុចឲ្យមក ហើយដល់ពេលស្លាប់ធ្វើដូចខ្ញុំឆ្កែចចកនែ៎ស្លាប់អត់និយាយមួយម៉ាត់ ។ ហើយដូចខ្ញុំនិយាយអំមិញថា គាត់សូត្រកំណាព្យនេះ ម៉ោងបួនកន្លះក្រោមការសួរសាករបស់លោក ហ្វ្រង់ស្វ័រ រូ ។ ហើយដល់ គាត់សូត្រកំណាព្យហ្នឹងចប់ លោក ហ្វ្រង់ស្វ័រ រូ ទុកពេលប្រហែលជាពីរទៅបីវិនាទី ស្ងាត់ឈឹង នៅក្នុងអង្គសវនាការយើងនេះ ប្រសិនបើមានមូសហើរយើងច្បាស់ជាឮ ។ នែ៎អាពីរបីវិនាទីនេះ រួចហើយ បានលោក ហ្វ្រង់ស្វ័រ រូ និយាយថា ខ្ញុំអស់សំណួរហើយលោកប្រធាន *សឺណោព្រីឡឺគែសស្យុង មឹស្មើឡឺប្រេស៊ីដង់* ។ នែ៎ អាបីវិនាទីនេះ បង្កើតជាបរិយាកាសស្រងូតស្រងាត់ បើសិនជាយើងមិនប្រុងប្រយ័ត្នទេហ្នឹង គឺអាណិតជនជាប់ចោទ ។ ហើយខ្ញុំសូមផ្តាំទៅលោក ហ្វ្រង់ស្វ័រ រូ ផង ថាអាបីវិនាទីរបស់គាត់ហ្នឹង គឺល្អណាស់ សូមសរសើរ ។ គាត់អាចយកទៅលេងនៅល្ខោនដ៏ល្បីមួយនៅទីក្រុងបារីសឈ្មោះ *កុងមីឌីហ្វ្រង់សេស* បាន ។ ប៉ុន្តែខ្ញុំយល់ឃើញថា កាលដែលជនជាប់ចោទប្រដូចខ្លួនឯងជាឆ្កែចចក ក្នុងរឿង "មរណភាពនៃឆ្កែចចក" នេះគឺជាបោកបញ្ឆោតបោកបន្លំ ពាក្យបារាំងថា *សែទឹនណាំប៉ូស្មៀរ* បោកបន្លំ បោកបញ្ឆោត ។ ហើយជាការវាយដណ្តើមយកគុណសម្បត្តិ ជាវីរបុរស ជាមនុស្សក្លាហាន *ស្តូអ៊ិច* ពាក្យ *ស្តូអ៊ិច* ហ្នឹង គឺ អាល់ហ្វ៉ែតឌឺហ្វីញី គាត់និយាយពីអ្នកដែលខំធ្វើការ ហើយមិនគិតអំពីការនឿយពិបាកផ្ទាល់ខ្លួន មិនគិតអំពី

ទុក្ខវេទនារបស់ខ្លួន ដូចទាហានបារាំង ដែលគេឲ្យទៅច្បាំងអ៊ីចឹង ។ ដូច្នេះ ហើយចំពោះខ្ញុំថា ជា *ណាំប៉ូស្មៀរ* បោកបញ្ឆោត ការរ៉ៃដណ្ដើមយកគុណសម្បត្តិដែលខ្លួនមិនមាន *អ៊ុយសៀវប៉ាស្សុង ដឺកាលីតេ ដឺអេរ្សូអ៊ិច* ពីព្រោះថា ក្លាហានអី បើអ្នកគ្រូ ឌឹម សារឿន អ៊ីចឹងអី? អ្នកគ្រូ ឌឹម សារឿន គ្រូរបស់គាត់ផ្ទាល់ហ្នឹង ចូលមកស-២១ គាត់ដឹងទៀត ថាប្អូនខ្ញុំណា គាត់ថាគាត់មិនដឹង ។ គាត់ដឹង គេយកធ្វើទារុណកម្ម ហើយបញ្ចុះបន្ទាបស្ត្រីភាពរបស់គាត់ ។

ដឹងស្រាប់ហើយ គាត់អត់ទាំងលើកកូនដៃជួយផង ។ តើក្លាហានអី? បើសិនជាអ្នកដែលធ្លាប់ប្រយុទ្ធជាមួយគ្នា ដល់មកចូលមកកណ្ដាប់ដៃខ្លួន ឯងអត់ទាំងមានលើកកូនដៃមួយដើម្បីការពារផង ។ ហ៊ឹម ហ៊ុយ នែ៎ ហ៊ឹម ហ៊ុយ អស់លោកចៅក្រមដឹងហើយ ហ៊ឹម ហ៊ុយ ជួយគេបាន ជួយ សោម ម៉េត បាន ។ នឹកឃើញហើយ សោម ម៉េត មានប្អូនមួយឈ្មោះ សោម ហ៊ុយ ចូលមកក្នុងស-២១ ហើយបានផ្ដោយមាត់ ប្រាប់គេថាហ្នឹង បង ។ ហ៊ឹម ហ៊ុយ ប្រាប់ថា កុំនិយាយអ៊ីចឹង តែនិយាយអ៊ីចឹងគេយកទៅដែរឥឡូវ ។ នែ៎ សោម ម៉េត ជួយបណ្ដោះ-- សុំទោស ហ៊ឹម ហ៊ុយ ជួយ បណ្ដោះ សោម ម៉េត ទៅៗ--

[១០:១៨:៥០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារ ចង់មានយោបល់អី?

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

សូមអរគុណលោកប្រធានដែលផ្ដល់វេទិកាឲ្យខ្ញុំ ។ ខ្ញុំជឿថា ដើម្បីរក្សានូវសេចក្ដីថ្លៃថ្នូរនៃសវនាការរបស់យើង សូមឲ្យលោកប្រធានធ្វើការរំឭកដើមបណ្ដឹងដើមបណ្ដឹងរដ្ឋប្បវេណី ដែលគាត់ថ្លែងការណ៍នៅពេលនេះ សូមឲ្យគាត់ផ្ដោតទៅលើសេចក្ដីថ្លែងការណ៍របស់គាត់ ។ យើងខ្ញុំយល់អំពីការនិយាយអំពីទុក្ខសោករបស់គ្រួសារគាត់ ។ ប៉ុន្តែ យ៉ាងក៏ដោយសូមឲ្យ កុំឲ្យលោកដើមបណ្ដឹងរដ្ឋប្បវេណីគាត់ធ្វើការ ធ្វើឲ្យមានប្រតិកម្មទៅដល់ជនរងគ្រោះផ្សេងៗ ឬក៏ជនជាប់ចោទ ដែលគាត់មិនពាក់ព័ន្ធទៅក្នុងរឿងក្ដីនេះ ហើយក៏មិនជាប់ពាក់ព័ន្ធទៅនឹងសម្ព័ន្ធភាព និងចំណងលោហិតអីផ្សេងៗ ។

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ស្ទួតហ្សីនស្គី ។

[១០:២០:០៩]

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ខ្ញុំចង់ធ្វើការឆ្លើយតបដោយខ្លីៗទៅលើការជំទាស់ គឺសូមលើកឡើងឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្ដី ។ ជាការពិតណាស់ កូនក្ដីរបស់ខ្ញុំបានធ្វើការថ្លែងអំពីដំណើរការដែលគាត់ធ្វើយ៉ាងណាតស៊ូជម្នះទៅលើការទុក្ខសោករបស់គាត់ ហើយនិងរឿងរ៉ាវដែលគាត់ចង់ប្រាប់តុលាការ។ ដូច្នេះហើយ គឺខ្ញុំសុំស្នើសុំលោកប្រធានកុំទទួលយកសំណើរបស់មេធាវីការពារក្ដី។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មតិជំទាស់របស់មេធាវីការពារក្ដីក៏មានលក្ខណៈសមរម្យមួយចំណែក ។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមរំឭកដល់ដើមបណ្ដឹងរដ្ឋប្បវេណីសូមសម្របសម្រួលអារម្មណ៍ដើម្បីធ្វើការថ្លែងឲ្យចូលទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះបានផ្ដល់ឱកាសជូនលោក ដើម្បីឲ្យលោកធ្វើសេចក្ដីថ្លែងការណ៍ដូចអ្វីដែលយើងបានជម្រាប ហ្នឹងបញ្ហាទីមួយ ។

ទីពីរអង្គជំនុំជម្រះក៏ មានការយោគយល់ដែរនូវទឹកចិត្តដែលវាមានបញ្ហាទុក្ខព្រួយក្នុងអារម្មណ៍ក្នុងដួងចិត្តជាច្រើនឆ្នាំនោះ ។ ហេតុដូច្នេះ គឺអង្គជំនុំជម្រះក៏មានការបន្ធូរបន្ថយដើម្បីមិនព្យាយាម មិនកាត់លោក ដែលជាដើមបណ្ដឹងរដ្ឋ ប្បវេណីក្នុងការនិយាយនោះទេ នេះជាការខិតខំមួយ ។ ប៉ុន្តែ គប្បីធ្វើយ៉ាងណាឲ្យបានថ្លៃថ្នូរ ឲ្យបានសមរម្យ ពីព្រោះថា នៅទីនេះយើងរកយុត្តិធម៌ ហើយយើងមិនមែនយកវេទិកានេះជាការសងសឹក ហើយក៏មិនឆ្លៀតយកវេទិកានេះ ដើម្បីបង្អាប់បន្ទោស ឬក៏ប្រមាថម៉ាក់ងាយ ចំពោះបុគ្គលណាមួយឡើយ គិតទាំងជនជាប់ចោទផង ពីព្រោះយើងដំណើរការក្ដីនេះប្រព្រឹត្តទៅតាមច្បាប់ដោយគោរពនូវគោលការណ៍ នូវវិធាននានា នៅក្នុងនោះ គឺសន្ធិសញ្ញាស្ដីអំពីសិទ្ធិមនុស្ស យើងតម្កល់ជាធំនៅក្នុងគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីរបស់យើង ។

ម្យ៉ាងទៀតពេលវេលាយើងចំណាយពេលវេលាពីរម៉ោង ឥឡូវហ្នឹងពេលវេលាច្រើនដែរហើយ ។ អ៊ីចឹងសុំដើមបណ្ដឹងរដ្ឋប្បវេណីសម្រួលនូវអារម្មណ៍ឲ្យបានល្អ ហើយសូមបន្តនូវសេចក្ដីថ្លែងការណ៍របស់ខ្លួន ហើយសូមនិយាយឲ្យត្រូវនឹងគោលដៅនៃបំណងនៃការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ។

អង្គជំនុំជម្រះរំឭកថា ដើមបណ្ដឹងរដ្ឋប្បវេណីរៀបរាប់ជូនអង្គសវនាការអំពីហេតុ អំពីទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់ ចំពោះជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលឲ្យប៉ះពាល់ដល់លោកក្នុងអំឡុងពេលនៃការបង្កើតនិងប្រតិបត្តិការនៃមន្ទីរស-២១ ក្នុងអំឡុងពេលកម្ពុជា

ប្រជាធិបតេយ្យចាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ ៦ មករា១៩៧៩ ដែលនាំឲ្យលោកសម្រេចចិត្តតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណង និងនិយាយរៀបរាប់អំពី ស្ថានភាពព្យសនកម្មចំពោះលោក ដែលមានជាអាទិ៍ ការខូចខាតរាងកាយ សម្ភារៈ ផ្លូវចិត្ត ផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ និងវាកើតមានពិតប្រាកដចំពោះរូបលោក ។

អ៊ីចឹង គឺលោកបានថ្លែងក៏មិនខុសទេ ប៉ុន្តែវាអាចកន្លែងខ្លះ គឺវាមានការលៀនចេញឆ្ងាយពីបំណង និងគោលដៅនៃដំណើរការសម្រាប់ក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណី ។ អ៊ីចឹង គ្រាន់តែរំឭក និងបង្វែរអារម្មណ៍លោក ដើម្បីឲ្យលោកហ្នឹងធ្វើការថ្លែងការណ៍រលូនពាក់ព័ន្ធទៅនឹងអ្វីដែលជាចំណុចទាំងឡាយដែលយើងបានកំណត់ជូនដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ មិនមែនតែលោកទេ គឺគ្រប់ទាំងអស់ដែលយើងដកស្រង់នេះគឺដកស្រង់ខ្លឹម សារដែលមានចែងនៅក្នុងវិធានច្បាប់តែម្តង ។

សូមអញ្ជើញបាទ ។

**លោក ជុំ ស៊ីរ៉ាត់៖**

លោកប្រធានៗ ដឹកនាំសវនាការនេះតាមកម្រិតអន្តរជាតិ ខ្ញុំក៏យល់ច្បាស់អ៊ីចឹងដែរ គឺជនជាប់ចោទមិនត្រូវ ទុកជាអ្នកទោសទេ ល្គឹកណាដែលតុលាការមិនទាន់បានសម្រេច ។ ក៏ប៉ុន្តែ យើងខ្ញុំជាជនរងគ្រោះមិនអាចទទួលយកបានទេ កាលដែលជនជាប់ចោទនៅក្នុងបរិវេណយើងនេះនិយាយថា ថ្ងូរ យំ អង្វរ សុទ្ធតែជាការកំសាក ។ មនុស្សម៉ឺនប្រាំមួយពាន់នាក់គេស្លាប់នៅទួលស្លែង ច្បាស់ជាបានយំ ច្បាស់ជា បានថ្ងូរ ច្បាស់ជាបានអង្វរ ។ តើយើងថាអ្នកនោះកំសាកបានទេ?

ដូច្នេះការដែលនិយាយថា កំសាកនៅក្នុងបរិវេណនេះ គឺថាជេរត្មះតិះដៀល *អាំងស៊ុលឌឺប៉ុស្ទីម* ទៅលើអ្នកដែលរងគ្រោះទាំងអស់នោះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តី ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

លោកប្រធានសូមអនុញ្ញាត និងលើកលែងឲ្យខ្ញុំនៅពេលដែលខ្ញុំស្កាត់នៅពេលនេះ ។ ខ្ញុំគិតថា នៅពេលណាក៏ដោយ យើងកត់សម្គាល់ឃើញថា ជនជាប់ចោទមិនបានប្រើពាក្យថា "កំសាក"នោះទេ។ ខ្ញុំដឹងថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការនិយាយថ្លែងទុក្ខរបស់គាត់ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីគាត់មិនអាចនិយាយនូវអ្វីដែលពាក្យរបស់ជនជាប់ចោទគាត់មិនបាននិយាយនោះទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវយើងតម្រង់ទិសវិញ ។ ដើមបណ្តឹងរដ្ឋប្បវេណីយើងបានរំឭកអំមិញហើយថាអ្វីដែលលោកបានថ្លែងហ្នឹង គឺយើងព្យាយាមមិនកាត់ទេ ដោយសារការយល់អំពីទឹកចិត្តទុក្ខសោករបស់ដើម បណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលមាន ប៉ុន្តែក៏យើងក៏មិនត្រូវធ្វើអ្វីឲ្យហួសហេតុដែរ ។ អ៊ីចឹង សូមលោកបង្វែរនៅក្នុងការថ្លែងការណ៍របស់លោកឲ្យមានការពាក់ព័ន្ធទៅនឹងអង្គហេតុ ហើយត្រង់ថាលោកកត់សម្គាល់ថាជឿ ឬក៏មិនជឿយ៉ាងណានៃសម្តី អាកប្បកិរិយារបស់ជនជាប់ចោទនោះ គឺជាសិទ្ធិរបស់លោកក្នុងការកត់សម្គាល់ចុងក្រោយ ។ ហើយអង្គជំនុំជម្រះធ្វើការសវនាការច្រើនខែក្នុងគោលដៅដើម្បីចង់បានព័ត៌មាន ចង់យកបញ្ហាទាំងអស់នេះទៅវិភាគពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយគ្រប់សព្វទាំងអស់ ដើម្បីចេញសេចក្តីសម្រេចមួយដែលឲ្យមានភាពយុត្តិធម៌ ដែលភាគីទាំងអស់ទទួលយកបាន ទាំងភាគីដើមបណ្តឹងរដ្ឋប្បវេណី ទាំងភាគីខាងជនជាប់ចោទ ។ បានន័យថា ឲ្យត្រឹមត្រូវបំផុត ។ នេះជាគោលបំណងដែលយើងធ្វើការដេញដោល ធ្វើការគ្រប់សព្វទាំងអស់ ហើយមានចំណាយពេលវេលាច្រើននៅក្នុងគោលបំណងនេះ ។

ហើយដូចជាយើងបានរំឭកអំមិញហើយថា ពេលវេលាក៏កាន់តែខ្លី អ៊ីចឹងសូមលោកបង្វែរការថ្លែងការណ៍របស់លោកទៅចំនឹងចំណុចអ្វីដែលយើងបានជម្រាបរំឭកប្រាប់ឡើងវិញអំពីបញ្ហានានាដែលគប្បីដើមបណ្តឹងរដ្ឋប្បវេណីនិយាយឲ្យដល់ពាក់ព័ន្ធនឹងបញ្ហានេះ ។ សូមអញ្ជើញ ។

**លោក ជុំ ស៊ីវ៉ាត់៖**

ខ្ញុំនឹងបញ្ចប់ ។ មុននឹងបញ្ចប់ហ្នឹងខ្ញុំចង់និយាយអំពីការដែលលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច បានប្តូរសាសនាទៅកាន់សាសនាគ្រិស្ត ។ នៅក្នុងសាសនាគ្រិស្ត ឃាតកទីមួយនៅក្នុងមនុស្សជាតិគឺឈ្មោះ “កាអាំង” ។ កាអាំង ហ្នឹងជាកូនអាដាំ ហើយនិង អែវ ។ ហើយនៅក្នុងសាសនាអ៊ីស្លាម នៅក្នុងសាសនាហ្សីុស ក៏មានរឿងដូចៗគ្នាហ្នឹងដែរ ។ ហើយកាអាំង ហ្នឹងបានសម្លាប់ប្អូនរបស់លោកឈ្មោះ អាប៊ែល។ សម្លាប់ហើយភ្នែករបស់ប្អូនហ្នឹងរត់តាមមើល កាអាំង ហ្នឹង ទៅកន្លែងណាក៏ភ្នែករត់តាមមើល ទៅក្នុងព្រៃចូលក្នុង ឡើងលើភ្នំទៅក្នុងសមុទ្រ ភ្នែកដែលមនុស្សដែលស្លាប់ហើយហ្នឹង រត់ទៅតាមមើល កាអាំង។

រហូតដល់ កាអាំង ហ្នឹងឲ្យគេដេកមិនលក់មិនកើត សុខចិត្តឲ្យគេជីករណ្តៅមួយ ហើយដាក់ខ្លួននៅក្នុងរណ្តៅនោះ ហើយឲ្យគេលុបរណ្តៅនោះវាទៅជាផ្នូរហើយ ។ ហើយ វិចទ័រហ៊ីហ្គោ ដែលជាអ្នកប្រាជ្ញបារាំង កំណាព្យបារាំងបានសរសេរកំណាព្យមួយមានចំណងជើងថា ឡាកុងស្យង់ “មនសិការ”

ហើយគាត់សរសេរថា *កង់ទុងនី សៀសង់ត្រង់ ហ្វែមេឡឺស្យ៊ូទែរាំង ឡឺអេតេដង់ឡាតុបបឺ អេរីកាតដេការអាំង (និយាយភាសាបារាំង)* "ពេលដែលផ្នូរគ្របដណ្ដប់លើគាត់ ខ្ញុំនៅក្នុងផ្នូរហើយមើលទៅគាត់" សុំទោសណា ភ្នែកនោះ ពេលណាដែលគេកប់គាត់ទៅក្នុងផ្នូរទៅហើយនោះ ។ ហើយគេថា ភ្នែករបស់ប្អូនរបស់គាត់ហ្នឹង នៅតែតាមមើលគាត់តទៅទៀត ។ ត្រូវបកអ៊ីចេះ "ពេលណាដែលគេកប់គាត់ទៅក្នុងដីហើយ ភ្នែកនោះតាមចូលទៅក្នុងដីតាមមើលគាត់ទៀត"។

ខ្ញុំសូមសួរជនជាប់ចោទ មនុស្សមួយម៉ឺនប្រាំមួយពាន់នាក់ ភ្នែកបីម៉ឺនពីរពាន់ ក្នុងភ្នែកនីមួយៗយើងមើលឃើញទុក្ខវេទនា សប្បាយក៏យើងឃើញ វេទនាក៏យើងឃើញ ។ មុននឹងអ្នកនឹងយកទៅសម្លាប់គេអាចឃើញទុក្ខវេទនានៅក្នុងភ្នែកអស់នោះ ។ គេអាចឃើញសេចក្ដីអស់សង្ឃឹម គេអាចឃើញសេចក្ដីមិនយល់ ហើយលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលបានប្ដូរសាសនាទៅសាសនាគ្រិស្ដ ដែលក្នុងសាសនាគ្រិស្ដហ្នឹង គេអាចនឹងអត់ឱនទោសឲ្យបាន ប៉ុន្តែ ក្នុងសាសនាព្រះពុទ្ធយើងវិញ យើងមានកម្មផល អ្នកឯងធ្វើល្អបានល្អ អ្នកឯងធ្វើអាក្រក់បានអាក្រក់ ។ ដល់សាសនាគ្រិស្ដគេអាចអត់ ឱនទោសឲ្យបាន ។ ឧបមាថា សាសនាគ្រិស្ដហ្នឹងអត់អោនទោសឲ្យបានចុះ តើភ្នែកបីម៉ឺនពីរពាន់ លោករត់រួចទេពីភ្នែកនុ៎ង? ការអាំង ភ្នែកតែមួយរត់មិនរួចផង ។

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាកអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទីសូមអញ្ជើញចូលវិញដើម្បីបន្តដំណើរការសវនាការរបស់យើង ។

ដើមបណ្ដឹងរដ្ឋប្បវេណីអាចរកកន្លែងសម្រាកសមរម្យនៅទីនោះ ហើយនិងអាចអញ្ជើញត្រឡប់មកកន្លែង នេះវិញមុនពេលអង្គជំនុំជម្រះចូលកាន់បន្ទប់សវនាការ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[អង្គសវនាការសម្រាកពីម៉ោង ១០:៣៣នាទី ដល់ម៉ោង ១០:៥៧នាទី]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាកិច្ចបន្តនេះអង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវី ស្ទូតហ្សីនស្គី ដែលជាមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្ប-

វេណើរូបនេះ ដើម្បីមានឱកាសក្នុងតាំងសំណួរបញ្ជាក់បន្ថែម ។ សូមអញ្ជើញ ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

សូមអរគុណលោកប្រធានដែលផ្តល់ឱកាសឲ្យខ្ញុំសួរកូនក្តីរបស់ខ្ញុំ ជុំ ស៊ីវ៉ាត់ ។ ប៉ុន្តែ មុនពេលដែលខ្ញុំសួរ គឺខ្ញុំសូមស្នើសុំលោកប្រធាន ឬក៏អង្គជំនុំជម្រះ ចំពោះការជំទាស់នៅពេលណាមួយនៅថ្ងៃអនាគតរបស់មេធាវីការពារក្តី ឬក៏ភាគីណាមួយនោះ គឺយើងគួរតែមានសិទ្ធិក្នុងស្តាប់សាក្សី ហើយគឺខ្ញុំនឹងមិនធ្វើការឆ្លើយតបណាមួយចំពោះមេធាវីការពាក្តីនោះទៀតទេ ។ ហើយខ្ញុំសូមបញ្ជាក់ថា នៅក្នុងការបកប្រែបារាំង គឺពាក្យថា "*ឡាស*" គឺជាពាក្យដែលប្រើប្រាស់ដោយជនជាប់ចោទ ។

នៅពេលនេះ គឺខ្ញុំសូមបង្ហាញនូវរូបថតរបស់កូនក្តីរបស់ខ្ញុំ ហើយកូនក្តីគាត់អាចពន្យល់អំពីរូបថតរបស់ប្អូនគាត់ ហើយនិងប្អូនថ្លៃស្រីរបស់គាត់ផងដែរ ។ ហើយខ្ញុំសូមស្នើលោកប្រធានឲ្យបង្គាប់មន្ត្រីតុលាការដាក់រូបថតនោះនៅលើអេក្រង់ ដើម្បីឲ្យកូនក្តីរបស់ខ្ញុំអាចពន្យល់ និងបរិយាយទៅលើរូបថតទាំងនោះ ។ សូមអរគុណ ។

[១១:៥៩:៤៣]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការរៀបចំដាក់រូបថតបញ្ចាំងនៅម៉ាស៊ីនស្លាយ ដើម្បីបង្ហាញរូបភាពនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

លោកប្រធាន! ខ្ញុំចង់អនុញ្ញាតឲ្យផ្តល់វេទិកាទៅដល់កូនក្តីរបស់ខ្ញុំ ដើម្បីឲ្យគាត់ធ្វើការផ្តល់យោបល់ទៅលើរូបថតនេះ។ ថាតើរូបថតនេះយកមកពីណា? ហើយថតនៅឯណា? ហើយគឺខ្ញុំសូមកុំឲ្យកាត់គាត់ នៅពេលដែលគាត់ធ្វើការបរិយាយនិយាយអំពីរូបថតនេះ ។ សូមអរគុណ ។

[១១:០១:៣៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ជុំ ស៊ីវ៉ាត់ ។

**លោក ជុំ ស៊ីវ៉ាត់៖**

នេះ គឺរូបថតប្អូនខ្ញុំ ប្អូនពៅឈ្មោះ ជុំ ស៊ីណារ៉េត និស្សិតពេទ្យឆ្នាំទី២ រូបថតនេះមានមិត្តភក្តិម្នាក់បានយកពីទួលស្លែងឲ្យមកខ្ញុំ ។ នេះ គឺ ជុំ ស៊ីណារ៉េត ដែលមិនទាន់បានចូលក្នុងកណ្តាប់ដៃរបស់ពួកធ្វើ

ទារុណកម្មរបស់លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ។

នេះ គឺរូបថត ស៊ីណារ៉េត ហើយនិង ណារិត ខាងស្តាំនៃកញ្ចក់ គឺ ស៊ីណារ៉េត ហើយខាងឆ្វេង គឺ ជុំ ណារិត នៅពេលដែលធ្វើបុណ្យបូជាសពរបស់ម្តាយយើង ១៧ថ្ងៃមុននឹង ណារិត ចូលទៅក្នុងម៉ាគី ។ ដូចដែលខ្ញុំបាននិយាយរៀបរាប់ពីលើពីរនាក់ហ្នឹងត្រូវរ៉ូវគ្នាណាស់ ។

[១១:០៥:០៥]

នេះ គឺ គឹម សុវណ្ណារី ហៅ ដន ខ្ញុំមិនបានស្គាល់ទេ ប្អូនថ្លៃខ្ញុំនេះ។ ហើយខ្ញុំឆ្លៀតឱកាស សូមអនុញ្ញាតពីអង្គជំនុំជម្រះអំពាវនាវដល់បងប្អូនណាដែលស្គាល់ គឹម សុវណ្ណារី ហៅ ដន ប្រពន្ធ ជុំ ណារិត ចូលគុកទួលស្លែងជាមួយ ជុំ ណារិត ហើយមានទារកមួយ ។ សូមមេត្តាទាក់ទងជាមួយនឹងខ្ញុំតាមរយៈអង្គភាពជនរងគ្រោះនៃតុលាការនេះ ។

**ប្រធានអង្គជំនុំ៖**

ឈប់ៗៗបញ្ចាំងឯកសារអំមិញឲ្យបាន-- បញ្ចាំងឯកសារអំមិញ-- អក្សរៗឲ្យឃើញអក្សរតូចបានហើយ ឲ្យតូចៗទៅ ។ បានហើយ ហើយដាក់មកក្រោម ឡើងលើ រុញឡើងឲ្យផុតទៅ ។ បានហើយៗ ដកចេញចុះ ។

**ការតាំងសំណួរដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

**លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្គី៖**

សូមអរគុណ ។ ខ្ញុំចង់សួរកូនក្តីរបស់ខ្ញុំ ជុំ ស៊ីរ៉ាត់ គឺចង់សួរសំណួរមួយ គឺសំណួរដូចតទៅនេះ៖

**ស៖** ខ្ញុំចង់ដឹង លោកបានពន្យល់ហើយនៅក្នុងបន្ទប់សវនាការរបស់យើង តើលោកគិតយ៉ាងម៉េច? ហើយ តើលោកបានធ្វើការប្រឈមទៅនឹងការសូមទោសរបស់លោកយ៉ាងម៉េច? ថាលោកយល់យ៉ាងម៉េចដែរ ចំពោះការសូមទោសរបស់ជនជាប់ចោទ? ហើយតើវាមានន័យយ៉ាងម៉េចចំពោះលោក?

**ឆ៖** មុនដំបូង ពេលដែលខ្ញុំឮជនជាប់ចោទ សូមទោសខ្ញុំថា ខ្ញុំអរណាស់ យ៉ាងហោចណាស់ក្នុងអ្នកដែលដឹកនាំកម្ពុជាប្រជាធិបតេយ្យទាំងប៉ុន្មាន មានមនុស្សម្នាក់ក្លាហានទទួល ។ ខ្ញុំចង់ជឿណាស់នៃការសូមទោសរបស់ជនជាប់ចោទនេះ ។ ក៏ប៉ុន្តែដល់ខ្ញុំមកចូលក្នុងអង្គសវនាការយូរៗទៅៗជាលែងមានជំនឿទៅវិញ ។ ពីព្រោះខ្ញុំឃើញថា ការដែលសូមទោសរបស់ជនជាប់ចោទហ្នឹង អត់មានសុទ្ធចិត្តទេ ។ ម៉េចបានជាខ្ញុំនិយាយអ៊ីចឹង ថ្ងៃដែល-- ទី១ អំ! ៣១ (សូមទោស) ខែមីនា ២០០៩ ជនជាប់ចោទ បានធ្វើសេចក្តីថ្លែងការណ៍ដ៏ឱឡារិកក្នុងនោះខ្ញុំដកសម្តីក្នុងចារិករបស់-- ក្នុងសវនាការរបស់យើង គាត់និយាយ

ថា "បច្ចុប្បន្ននេះ ខ្ញុំមានវិប្បដិសារីសោកស្ដាយយ៉ាងជ្រាលជ្រៅ ព្រមទាំងខ្មាស់អៀន ព្រមទាំងមានសភាពរអៀសក្នុងឋានៈជាអ្នកមានទោស ហើយដឹងថា ខ្លួនជាអ្នកមានទោសចំពោះប្រជាជនកម្ពុជាទាំងមូល ។ ហើយគាត់បន្តទៅទៀត ខ្ញុំបង្កើតវិធីមួយ ដើម្បីលួងអារម្មណ៍ខ្លួនឲ្យបានស្ងប់បន្តិច គឺសែនសូមទោស ។ មុនដំបូងខ្ញុំសូមទោសតែឪពុកម្ដាយខ្ញុំទេ ក្រោយមកខ្ញុំសូមទោសគ្រូបាអាចារ្យខ្ញុំ ហើយដល់យូរទៅខ្ញុំសូម-- ខ្ញុំសែនសូមទោសជាតិ ប្រជាជនទាំងមូលរាល់ថ្ងៃ ១៧ វិច្ឆិកា ដែលជាថ្ងៃកំណើតរបស់ខ្ញុំ ។ ខ្ញុំនឹងធ្វើអ្វីមួយដើម្បីនឹងរំឭកដល់វិប្បដិសារីរបស់ខ្ញុំ ។"

ខ្ញុំឃើញក្នុងសេចក្ដីថ្លែងការណ៍របស់ជនជាប់ចោទនេះ គឺថាគាត់អត់មានសូម-- គាត់បន់ស្រន់ ប៉ុន្តែអត់មានបន់ស្រន់ឲ្យ ដូចថាវិញ្ញាណក្ខន្ធអ្នកដែលស្លាប់ទៅៗកើតបរលោក មានសុខដុមរមនាអីទេ ចូលព្រះនិព្វានអីទេ ។ គាត់បន់ ដើម្បីឲ្យៗគាត់ធូរអារម្មណ៍របស់គាត់ៗ ។ ខ្ញុំរកវិធីមួយ ដើម្បីលួងអារម្មណ៍ខ្ញុំឲ្យបានស្ងប់បន្តិច គឺបន់រាល់តែថ្ងៃ ១៧ វិច្ឆិកា ថ្ងៃខួបកំណើតរបស់គាត់ ។

[១១:១១:០៨]

ខ(២) នៅថ្ងៃ៩ ខែកក្កដា ឆ្នាំ២០០៩ ក្រោយការដឹកនាំសួរដោយលោក គឹម ម៉េងឃី លោកមេធាវី គឹម ម៉េងឃី ។ លោកជាមេធាវីរបស់លោកស្រី ជិន ម៉េត ។ លោក គឹម ម៉េងឃី មានប្រសាសន៍សួរថា តើជនជាប់ចោទនឹងទទួលខុសត្រូវខាងមនោសញ្ចេតនាទៅជនរងគ្រោះ ជិន ម៉េត ឬទេ? ខ្ញុំបានយកចេញអំពីចារឹករបស់តុលាការនេះ និយាយថា "ជម្រាបប្រសាសន៍លោកមេធាវី ចំពោះករណីមិត្ត ម៉េត ខ្ញុំអត់ទទួលខុសត្រូវខាងផ្លូវចិត្តទេ ។ ខ្ញុំទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនេះតាមច្បាប់ ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ សូមចប់" ។

ខ(៣) ប្អូនខ្ញុំ ជនជាប់ចោទស្គាល់ច្បាស់ណាស់ ។ គាត់បានសរសេរមកខ្ញុំ ខ្ញុំឃើញគាត់សរសេរមក អរចង់ស្លាប់ ។ ប៉ុន្តែគាត់ថា អត់ដឹងទេ អត់បានឃើញទេ អត់មានអីទេ ហើយគិតមិនប៉ានជួយទេ បើទុកជាជួយទៅ គាត់ខាងនឹងន័ៃ អង្គការគេយកគាត់ទៅសម្លាប់ ។ រួចដល់អ៊ីចឹងទៅៗ ទៅន៉ៃប្រដូចខ្លួននឹងឆ្កែចចកម៉េចកើត ។ គាត់ថាអត់ដឹង ដូច្នេះខ្ញុំយល់ឃើញថា អាហ្នឹងអត់មានសុទ្ធចិត្តទេ ហើយបើសិនជាអង្គតុលាការ លោកប្រធាន លោកស្រី អស់លោក យល់ថា ខ្ញុំនិយាយនេះ វាលម្អៀងខ្លាំងពេក ដាក់ទម្ងន់ខ្លាំងពេកទៅជនជាប់ចោទ ។ ខ្ញុំសូមឲ្យតុលាការអញ្ជើញមើលរបាយការណ៍របស់វេជ្ជបណ្ឌិតខាងចិត្តសាស្ត្រ ដែលចុះនៅថ្ងៃ០៨ ខែមេសា ឆ្នាំ២០០៨ បណ្ឌិតខាងចិត្តសាស្ត្រនោះឈ្មោះ *សៀវរ៉ូនី ហ្គាលបូ ហ្វ្រង់ស្វ័រ ស៊ាល*។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ចំពោះខ្ញុំ គឺវាសំខាន់ណាស់ ដែលខ្ញុំត្រូវស្តាត់ទៅពេលនេះ ដោយតែលោកដែលលោកគាត់លើកឡើងនោះ គឺជាអ្នកជំនាញដែលយើងស្តាប់ពេលក្រោយ ។ ដូច្នេះហើយនៅក្នុងដំណាក់នេះ គឺយើងមិនអាចលើកឡើងអំពីរបាយការណ៍របស់គាត់នោះទេ ដែលគាត់នឹងមកផ្តល់នូវសក្ខីកម្មចំពោះយើងនៅពេលខាងមុខនេះ ។ ដូច្នេះ យើងមិនអាចលើកឡើងអំពីរបាយការណ៍នោះទេ ។ សូមអរគុណ ។

[១១:១៣:៤៦]

**លោក ជុំ ស៊ីវ៉ាត់៖**

ខ្ញុំមិនបាច់និយាយទេពី ខ ទីបី អ៊ីចឹង ។ ក៏ប៉ុន្តែបី(ខ) ខាងមុខនេះ បង្ហាញឃើញថា គ្មានការសុទ្ធចិត្តទេ នៅក្នុងការសុំទោសនេះ ។

ដូច្នេះ ក្នុងនាមប្អូនខ្ញុំ ជុំ ស៊ីណារ៉េត, ជុំ ណារិត, គឹម សុវណ្ណារី ហៅ ដន និងក្មួយខ្ញុំ ។ ខ្ញុំប្រកាសមុខតុលាការថា ខ្ញុំមិនអើពើជាដាច់ខាតលើពាក្យសូមទោសដែលអត់មានសុទ្ធចិត្តនេះ ។ ខ្ញុំមកតុលាការនេះ ដើម្បីទាមទារយកយុត្តិធម៌ ហើយយុត្តិធម៌នេះ មិនអាចនឹងដាក់ដោយឡែកចេញអំពីការពិតទេ រហូតដល់ពេលនេះសាមសិបប្អូនឆ្នាំហើយ ខ្ញុំអត់បានទទួលការពិតបន្តិចសោះ ។ សូមអរគុណ ។

**លោកស្រី ស៊ីលយី ស្ទួតហ្សីនស្គី៖**

ខ្ញុំពុំមានសំណួរបន្ថែមទៀត ចង់សួរលោក ជុំ ស៊ីវ៉ាត់ នោះទេ ប៉ុន្តែខ្ញុំសូមថ្លែងអំណរគុណលោកយ៉ាងជ្រាលជ្រៅ ដែលលោកបានអញ្ជើញចូលមុខក្នុងអង្គសវនាការរបស់យើង ហើយបានចូលរួមធ្វើសេចក្តីថ្លែងដោយប្រឹងប្រែងយ៉ាងខ្លាំងក្លា ហើយព្យាយាមរំឭកដល់វិញ្ញាណក្ខន្ធប្អូនៗរបស់លោក ហើយលោកបានសម្តែងអាកប្បកិរិយាយ៉ាងត្រឹមត្រូវ ហើយលោកបានចូលរួមយ៉ាងច្រើននៅក្នុងសវនាការរបស់យើងនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្តល់វេទិកាទៅ តំណាងសហព្រះរាជអាជ្ញា ប្រសិនបើមានសំណួរអ្វីត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ សូមអញ្ជើញ ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា៖**

**សួរដោយលោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន ។

**ស៖** សូមអរគុណលោកនូវការផ្តល់នូវសេចក្តីថ្លែងដ៏មានភាពក្លាហាន ។ នៅក្នុងចម្លើយរបស់លោក លោកបានផ្តល់យ៉ាងច្រើនអំពីព័ត៌មានផ្សេងៗ ហើយលោកបានប្រមូល និងធ្វើការស្រាវជ្រាវចំពោះលោក ណារ៉េត និងប្រពន្ធរបស់គាត់ ។ ហើយចំពោះលោក-- ប្អូនរបស់លោកឈ្មោះ ស៊ីណារ៉េត ថាតើលោកអាចផ្តល់ជូនយើងខ្ញុំនូវព័ត៌មានផ្សេងទៀត អំពីព័ត៌មានពិស្តារទាក់ទងទៅនឹងការចាប់ខ្លួនរបស់ប្អូនរបស់លោក ជុំ ស៊ីណារ៉េត ថាចាប់នៅពេលណា? នរណាគេជាអ្នកចាប់? ហើយថាការចាប់ខ្លួននោះវាពាក់ព័ន្ធទៅនឹងប្អូនរបស់លោកឈ្មោះ ណារិត ដែរឬទេ? ហើយខ្ញុំចង់ដឹងថា តើក្នុងការស្រាវជ្រាវរបស់លោក លោកបានទទួលព័ត៌មានយ៉ាងម៉េចទាក់ទងទៅនឹង ជុំ ស៊ីណារ៉េត? ហើយខ្ញុំដឹងថា ការទទួលព័ត៌មាននោះ ពិតជាមានការលំបាកណាស់ចំពោះលោក ប៉ុន្តែ ខ្ញុំចង់ឲ្យលោកជម្រាបបន្តិចទៅចំណុចនេះ ។

[១១:១៧:៥១]

**ឆ៖** សូមជម្រាបលោកសហព្រះរាជអាជ្ញា ។ ចំពោះប្អូនខ្ញុំ ជុំ ស៊ីណារ៉េត នេះ ខ្ញុំមិនសូវ-- ថ្វីដ្បិតតែមានការស្រាវជ្រាវយ៉ាងម៉េចក៏ដោយ ក៏មិនសូវបានព័ត៌មានអីដែរ ។ មានតែរូបថតមួយហ្នឹងដែលជាមិត្តភក្តិម្នាក់បានយកពីមន្ទីរស-២១ យកមកឲ្យខ្ញុំ ។ អត់-- កាលដែលខ្ញុំទៅ ស-២១ ខែតុលា ឆ្នាំ១៩៩៣ ខ្ញុំឃើញតែឈ្មោះ ខ្ញុំអត់ឃើញថ្ងៃចូល ខ្ញុំអត់ឃើញថ្ងៃស្លាប់ ហើយ គឹម សុវណ្ណារី ក៏អ៊ីចឹងដែរ ។ ហើយដល់ខ្ញុំជម្រាបតុលាការអំមិញនេះ ដែលថាខ្ញុំប្រហែលៗផង សង្ឃឹមផងមែនទែន ថាថ្ងៃដែលចូល ថ្ងៃដែលភ្នំពេញយើងធ្លាក់ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ហ្នឹង ខ្ញុំដឹងថា ស៊ីណារ៉េត នៅភ្នំពេញ ពីព្រោះខ្ញុំបានទទួលសំបុត្រមួយពីគាត់ ពេលដែលបារាំងនាំគ្នាចេញទៅ ។ ដូច្នេះ ពេលបារាំងចេញទៅពេលដាច់មេសា ហ្នឹងគាត់នៅភ្នំពេញ ។ រួចគេជម្លៀសប្រជាជនភ្នំពេញហ្នឹងថ្ងៃ១៧ រួចទៅហើយ ។ ដូច្នេះ គាត់នៅភ្នំពេញ ។

ហើយដល់ពេល ណារិត ចូលមក តាមខ្ញុំបានដំណឹងនេះតាម ពេជ លឹមឃួនៗ ជាអ្នកទម្លាក់គ្រាប់បែកលើវិមានសេនាប្រមុខ លន់ នល់ ថ្ងៃ១៧ ខែមីនា ឆ្នាំ១៩៧៣ ។ រួចហើយទម្លាក់គ្រាប់បែកទៅគាត់រត់ទៅចូលខាង-- ពេលនុ៎ងគេហៅ តំបន់រំដោះ នៅខាងក្រចេះ ។ រួចដល់បានឈ្មោះអីហើយ ពេលថ្ងៃ

១៧ មេសា ឆ្នាំ១៩៧៥ ហើយ គាត់ចូលមកវិញ ហើយគាត់អ្នកដើរបើក*អេលីកូទែរ* ឧទ្ធម្ភាគចក្រនៃកម្ពុជាប្រជាធិបតេយ្យ ។ ហើយគាត់បាន-- ក្រោយមកគាត់បានលួចអេលីកូទែរហ្នឹង ឧទ្ធម្ភាគចក្រហ្នឹងរត់ចេញទៅទៀត ទៅដល់អ៊ូតាប៉ាវ នៅប្រទេសសៀម ។ រួចហើយគាត់បានសិទ្ធិច្រកកោននៅប្រទេសបារាំង ខ្ញុំបានជួបគាត់នៅឆ្នាំ១៩៧៨ ។ ពេលនោះនៅ*អូស្លូ* គេមានធ្វើរៀបចំ គេហៅថា *កាំបូដ្យាហៀវីង* គេចង់ហៅអ្នកដែលភៀសខ្លួនទាំងប៉ុន្មានទៅស្តាប់ ថាតើស្ថានការណ៍នៅប្រទេសកម្ពុជាយ៉ាងម៉េចខ្លះ? កាលនុ៎ង គឺខែមេសា ឆ្នាំ១៩៧៨ ។ ហើយពេលនោះ មានជនភៀសខ្លួនប្រហែលជាម្ភៃនាក់ ហើយមានអ្នកខាងថា*អ៊ិចស្ព៊ែរ* គេហៅថា *អ៊ិចស្ព៊ែរ* នោះ អ្នកជំនាញ ។ មាន *ស្សង់ឡាគុទារ* អ្នកកាសែតដ៏ល្បីល្បាញមួយ មាន*ហ្វ្រង់ស្វ័រប៉ុងហ្សូ* ដែលបានសរសេរសៀវភៅ នៃ *"កាំបូដ្យអាន់នេសហ្សេរ្វូ"* មាន *ប៉ែកណាហាម៉ែល (និយាយភាសាបារាំង)* ហើយមានខ្លួនខ្ញុំដែរ ។

ខ្លួនខ្ញុំនេះជាអ្នកបកប្រែភាសា មិនមែនជា នៃជំនាញអីគេទេ ។ ហើយពេលនុ៎ងមាន ពេជ លឹមឃួន គេហៅដែរ ហើយ ពេជ លឹមឃួន ពេលនុ៎ង ឆ្លៀតប្រាប់ខ្ញុំថា ប្អូន ធ្លាប់ស្គាល់ប្អូននៅជាមួយ ហ៊ូ នឹម ។ ព្រោះ ពេជ លឹមឃួន ចូលទៅព្រៃហ្នឹ ចូលទៅម៉ាគីហ្នឹង នៅជាមួយ ហ៊ូ នឹម ដែរ ។ ហើយថា ប្អូនហ្នឹងនៅជាមួយ ហ៊ូ នឹម ហើយអ៊ីចឹងហើយបានជាខ្ញុំដឹងថាប្អូនខ្ញុំចូលមកភ្នំពេញ ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ។

[១១:២១:២៦]

ដល់ចូលមកហើយនេះ ដល់ខ្ញុំស្រាវជ្រាវទៅឃើញថា ទៅជាប់គុកស-២១ ថ្ងៃ២៩ តុលា ឆ្នាំ ១៩៧៦ ។ ហើយខ្ញុំសន្និដ្ឋានទេ អានេះជាប្រហែលរបស់ទេ អាហ្នឹងជាការកាត់ស្មានរបស់ខ្ញុំថា ណារិត ហើយនិង ស៊ីណារ៉េត ហ្នឹងប្រហែលជាបានជួបគ្នាពេលហ្នឹង ។ ហើយអរណាស់ថា បួងសួងឲ្យបានជួបគ្នាមុននឹងស្លាប់ទៅនេះ ។ សូមលោកជ្រាប ។ អញ្ជើញ ។

**ស៖** ដូច្នេះអាចនិយាយថា មូលហេតុនៃការចាប់ខ្លួនរបស់ប្អូនរបស់លោក ជុំ ស៊ីណារ៉េត នោះ គឺរកមិនឃើញទេ ។ ដូច្នេះហើយ ការដែលថាមិនបានដឹងអំពីការចាប់ខ្លួនរបស់ប្អូនប្រុសរបស់លោក ជុំ ស៊ីណារ៉េត នោះ ដែលជាទុក្ខបន្ថែមចំពោះលោក ។ តើអ៊ីចឹងមែនទេ?

**ឆ៖** អាហ្នឹង គឺហួសពីការនឹកមមៃៗ ។ ស៊ីណារ៉េត ហ្នឹងទីមួយ ជាយុវជន និស្សិត គ្មានធ្វើនយោបាយទេ ។ រួចថាបើចាប់ហ្នឹង ខ្ញុំច្បាស់ជាចាប់ដោយសារ ស៊ីណារ៉េត ហ្នឹងជាប្អូន ណារិត តែប៉ុណ្ណឹងទេ ដូចជាគ្នា គឹម សុវណ្ណារី ហៅ ដន ហ្នឹង គ្រាន់តែជាប្រពន្ធរបស់ ណារិត ប៉ុណ្ណឹងទេ ។

ដូច្នេះហើយៗមួយទៀតដូចខ្ញុំជម្រាបអង្គជំនុំជម្រះអម្បាញ់មិញហ្នឹង ។ ខ្ញុំដូចជាមានវិប្បដិសារីផ្ទាល់ខ្លួន ព្រោះខ្ញុំត្រូវចង់យកប្អូនហ្នឹងចេញទៅប្រទេសស្វីស ក្រុងហ្សឺណែវ ពេលដែលខ្ញុំចេញទៅធ្វើនៅក្រុងហ្សឺណែវ ។ ហើយដោយសារខ្វះសុភវិនិច្ឆ័យ នឹកថាមិនអី ខ្មែរយើងទាំងអស់ ពេលនុ៎ង នឹកថាមិនអីអ្នកណាចូលមក ក៏យើងបម្រើគេទៅ កសាងជាតិទៅ វាដូចគ្នាទេ ខ្មែរដូចតែគ្នាទេ ពេលនុ៎ងគិតអ៊ីចឹងទាំងអស់គ្នា ។

[១១:២៣:៤២]

អ៊ីចឹងហើយបានស្តាប់បញ្ញវន្ត ស្តាប់អ្នកចេះ អ្នកដឹង ស្តាប់វេជ្ជបណ្ឌិត ស្តាប់សាស្ត្រាចារ្យ ស្តាប់វិស្វករច្រើនណាស់ ហើយទម្រាំតែស្តារឡើងវិញនោះ ប្រទេសយើងគឺវាអ៊ីចឹង ។ សូមទោសវែងឆ្ងាយបន្តិច សូមលោកសហព្រះរាជអាជ្ញាជ្រាប ។

**លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯលះ**

ខ្ញុំពុំមានសំណួរបន្ថែមទៀតនោះទេ ។ សូមអរគុណច្រើន លោក ជុំ ស៊ីរ៉ាត់ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីការពារក្តី ប្រសិនបើមានសំណួរត្រូវសួរដល់ដើមបណ្តឹងរដ្ឋ-ប្បវេណីរូបនេះ សូមអញ្ជើញ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

លោកប្រធាន មេធាវីការពារក្តី ពុំមានសំណួរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ យើងខ្ញុំគ្រាន់តែចង់ដាក់សេចក្តីសង្ខេតមួយចំពោះលោក ភឹង តុន តាមសំណើរបស់លោក ភឹង ហ្គុតស៊ុនថារី ។ ហើយលោកជនជាប់ចោទ បានធ្វើការដាក់យោបល់របស់គាត់ជាលាយលក្ខណ៍អក្សរចំពោះសំណួររបស់លោកស្រី ហ្គុនស៊ុនថារី ដែលបានស្តាប់នៅស-២១ ។ ឯកសារដែលគាត់សរសេរនោះ គឺបានដាក់នៅក្នុងសំណុំរឿងហើយ ដែលមាននៅក្នុងឯកសារលេខ E3/13 ERN ខ្មែរគឺ 00243010 00243013 បារាំងវិញ 00243014 ដល់លេខ 00243022 អង់គ្លេសគឺ 00228786 ហើយមួយទៀតគឺលេខ 00228788 ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី ចង់មានយោបល់អីទៅ?

**លោក ជុំ ស៊ីរ៉ាត់៖**

សូមអរគុណលោកប្រធាន ។ លោកស្រីមេធាវីអំមិញមានប្រសាសន៍ថា សំបុត្រដែលលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច បានឆ្លើយនឹងសំណួររបស់ខ្ញុំ ខ្ញុំបានទទួលមែន ។ ហើយក៏ខ្ញុំបានជម្រាបអង្គសវនាការអំមិញដែរ ក្នុងសំបុត្រនោះគាត់និយាយថា គាត់ស្គាល់ប្អូនខ្ញុំទាំងពីរនាក់ ទាំងអស់ ។ ប៉ុន្តែ ខ្ញុំចង់ដឹង មិនមែនថាគាត់ស្គាល់ មិនស្គាល់ ពីណាក៏ដឹងថាគាត់ស្គាល់ដែរ ។ ខ្ញុំចង់ដឹងថា ប្អូនខ្ញុំស្លាប់នៅក្នុងកាលៈទេសៈយ៉ាងម៉េច? នៅកន្លែងណា? តាមខ្ញុំដឹង ណារិត ច្បាស់ជានៅទួលស្លែងហើយ ព្រោះស្លាប់នៅថ្ងៃទី១ ខែ១ ឆ្នាំ១៩៧៧ កាលនោះជើងឯកមិនទាន់មានទេ ខ្ញុំដឹង ប៉ុន្តែប្អូនខ្ញុំពីរនាក់ទៀត តើនៅប៉ុន្មានខែនៅក្នុងទួលស្លែង? នៅដូចបង ភឹង តុន ប្រាំមួយខែ ឬមួយក៏នៅមួយខែ ឬក៏នៅដប់ខែ ។ នេះខ្ញុំចង់ដឹងអាហ្នឹង ខ្ញុំមិនមែនចង់ដឹងថា គាត់ស្គាល់ប្អូនខ្ញុំ ពីណាក៏ដឹងថាគាត់ស្គាល់ដែរ ខ្ញុំក៏ដឹងថា គាត់ស្គាល់ដែរ ។ រួចចង់ឲ្យគាត់ថាគាត់សុំទោស ពីណាក៏ដឹងសុំទោសដែរ ប៉ុន្តែខ្ញុំនិយាយអំមិញហើយ សុំទោសនេះអត់មានសុចិត្តទេ ។ ខ្ញុំមិនមែនចង់ដឹងអ៊ីចឹងទេ ខ្ញុំចង់ដឹងកាលៈទេសៈនៃការស្លាប់របស់ប្អូនខ្ញុំទាំងបីនាក់ ហើយនិងក្មួយខ្ញុំ ។ ដូច្នេះហើយ មិនបាច់យកអាណែ ហៅថាឯកសារមិនបានការ និយាយអ៊ីចឹងចុះ សូមទោសណ៎ាលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អំមិញនេះ ឯកសារដែលគាត់ឆ្លើយតប គឺកាលពីម្សិលមិញ ខាងកូនស្រីច្បងរបស់លោកគ្រូ ភឹង តុន ហ្នឹង គាត់សុំឲ្យមានការបង្ហាញ ហើយជនជាប់ចោទបាននិយាយ គាត់នឹងប្រឹងប្រែង ដើម្បីបង្ហាញអំពីអ្វីដែលគាត់បានស្រាវជ្រាវឃើញ ហើយនិងឆ្លើយតបទៅនឹងសំណូមពររបស់កូនស្រីរបស់ ភឹង តុន ហើយឥឡូវនេះ គាត់ថាបានទទួលឯកសារនេះហើយ បានន័យថា ជនជាប់ចោទបានរៀបរៀង បានឆ្លើយតបទៅ ហើយដាក់ទេ ។ ចំណែកឯលោក គឺអង្គជំនុំជម្រះនឹងផ្តល់ឱកាសដោយឡែក ។ រឿងអំមិញរឿងដោយឡែកទេ មិនមែនរឿងនេះទេ រឿងនេះ យើងនឹងឲ្យ--

[១១:២៨:៥៩]

**លោក ជុំ ស៊ីរ៉ាត់៖**

សូមទោសលោកប្រធាន ។ បើសិនជារឿងណែ លោកស្រី ស៊ុនថារី ភឹង តុន ទេ ម៉េចគាត់និយាយពេលដែលខ្ញុំនិយាយ ខ្ញុំមិនយល់ទេ ។

**ប្រធានអង្គជំនុំ៖**

នេះគ្រាន់តែជាការ គាត់ឆ្លើយថា មិនមានឆ្លើយតបជាមួយនឹង អត់មានសំណួរអីសួរលោកទេ ប៉ុន្តែគាត់ផ្តល់ព័ត៌មាន ។ ដូចអំមិញ ពីព្រឹកមិញអ៊ីចឹង គឺការស្តាប់សេចក្តីថ្លែងការណ៍របស់លោកទេ ប៉ុន្តែមានមេធាវីជាច្រើន គេផ្តល់ព័ត៌មានមកដល់អង្គជំនុំជម្រះ អំពីបញ្ហាផ្សេងៗ ដែលកើតឡើងនៅក្នុងអំឡុងពេលដំណើរការ នេះជាការអនុវត្តនៅទីនេះ ។

ជាកិច្ចបន្តអង្គជំនុំជម្រះ ផ្តល់ឱកាសដល់ជនជាប់ចោទអាចឡើងធ្វើការកត់សម្គាល់ ចំពោះសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ ហើយអង្គជំនុំជម្រះ សូមជម្រាបថា នេះជាសិទ្ធិជនជាប់ចោទ អាចធ្វើសេចក្តីថ្លែងការណ៍កត់សម្គាល់ទៅលើសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក៏បាន ឬក៏មិនធ្វើក៏បានដែរ ។ ប៉ុន្តែនេះឱកាស ដើម្បីអង្គជំនុំជម្រះនៅតែផ្តល់ដល់ជនជាប់ចោទ ។

សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ខ្ញុំសូមបញ្ជាក់សាជាថ្មីឡើងវិញថា ទីមួយមិត្តភក្តិ មិត្តភក្តិចាស់ដែលធ្លាក់ទៅស-២១ច្រើនណាស់ ។ ម្នាក់នោះមិនមែនជាមិត្តភក្តិផង គាត់អាយុច្រើនជាងខ្ញុំ ប្រហែលជាលោក ជុំ ស៊ីរ៉ាត់ ស្គាល់ដែរ សាស្ត្រាចារ្យប្រវត្តិវិទ្យានៅលីសេស្គន់ គិន អួន ធ្លាក់ទៅមុនគេហើយខ្ញុំអត់ដឹងទេ ទាល់តែឃើញសេចក្តីសារភាពមក បានខ្ញុំដឹងថា អំ! គិន អួន មកហើយ ។ ដូច្នេះ ចំពោះបញ្ហាមិត្តភក្តិដែលខ្ញុំធ្លាប់ស្គាល់ ធ្លាប់គោរព ធ្លាប់ស្រឡាញ់ ខ្ញុំគេចមុខយកតែរួចខ្លួនទេ អត់បានទៅអើតទេ នេះជម្រាបដោយត្រង់ ។ នេះហើយដែលខ្ញុំហៅថា ក្បត់មិត្ត ក្បត់ភក្តិ ។ ដូច្នេះ ជុំ ណារិត ក៏ចូលក្នុងជំពូកហ្នឹងដែរ គឺអ្នកណាមកប៉ុន្មាននាក់ក៏ខ្ញុំខំបំភ្លេច ខំគេច ខំធ្វើមិនដឹង នេះចំពោះមិត្តភក្តិ ខ្ញុំអត់មានលទ្ធភាពអីហ្នឹងជួយទេ ដូចលោកជម្រាបហើយគោលការណ៍អ្នកណាដែលគេចាប់បញ្ជូនមកហើយ ចាត់ទុកជាខ្មាំង នេះជាបញ្ហាមួយ ។ ឯចំណែកបញ្ហាមួយទៀត លោកមានបញ្ហាអំមិញអំពីភ្នែកបីម៉ឺនជាង ខ្ញុំទទួលស្គាល់បញ្ហានេះដោយសារបញ្ហានេះបានប៉ុន្មានថ្ងៃនេះ ខ្ញុំនិយាយថាទទួលទាំងអស់សូមដើមបណ្តឹងរដ្ឋប្បវេណី លោកចង្អុលមុខខ្ញុំចុះ លោកថ្កោលទោសខ្ញុំចុះ លោកស្តីបន្ទោសយ៉ាងម៉េចក៏បានដែរ ខ្ញុំទទួល។ ផ្ទាល់ខ្លួនលោក លោកឃើញហើយអំមិញ លោកចង្អុលមុខខ្ញុំយ៉ាងម៉េច លោកថ្កោលទោសខ្ញុំយ៉ាងម៉េច ខ្ញុំទទួលដោយញញឹម ខ្ញុំអត់ប្រកែក ហើយអត់តថ្លៃអីនឹងលោកមួយម៉ាត់ទេ ។ នេះជាសុទ្ធចិត្ត ដែលខ្ញុំបើកជូនបងប្អូនជនរងគ្រោះទាំងអស់ ដែលបាត់បង់ឪពុកម្តាយ ដែលបាត់បង់បងប្អូន ។

រួចខ្ញុំរហូតដល់និយាយប៉ុន្មានថ្ងៃនេះ វាជ្រុលថែមទៀត ខ្ញុំសូមមិនរំឭកបញ្ហានេះទេ ជាតិប្រជាជនកម្ពុជាលោកឮហើយ ។ ដូច្នេះ សូមលោកបញ្ជាក់ ខ្ញុំសូមបញ្ជាក់ជូនលោកដោយស្មោះត្រង់ ខ្ញុំអត់មានទឹកចិត្តគំនុំសងសឹកនឹងលោក គ្មានចិត្តចង់តបតនឹងលោក គ្មានចិត្តប្រកែកអីនឹងលោកទេ លោកស្តីបន្ទោសខ្ញុំអញ្ជើញ ខ្ញុំអត់ប្រកែកទេ ទទួលដោយស្មោះ អត់មានពន្យុះប្រសោក ទទួលហ្នឹង ទទួលដោយស្មោះ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះដោយស្មោះ ។ ដោយឡែក ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្លះខ្ញុំចង់និយាយជម្រាបបញ្ជាក់បន្តិចដែរ ។ លោកមានប្រសាសន៍ថា ណារិត ទៅជនបទ ខ្ញុំប្រើពាក្យជនបទចុះ ក្រោយដំណាលគ្នាជាមួយ ពេជ លឹមយុន បើតាមខ្ញុំចាំផ្សេង ។ ព្រោះអី?

**លោក ជុំ ស៊ីវ៉ាត់៖**

លោកប្រធាន ខ្ញុំមិនដែលនិយាយអ៊ីចឹងទេ ។

**ប្រធានអង្គជំនុំ៖**

ត្រឹមហ្នឹងបានហើយ ជនជាប់ចោទ ឥឡូវកុំឲ្យមានបញ្ហា ។ បញ្ឈប់នូវការកត់សម្គាល់របស់ជនជាប់ចោទត្រឹមនេះ ។ ឥឡូវនេះ ការស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ ស៊ីវ៉ាត់ ឃើញថាដល់ទីបញ្ចប់ហើយ ។ លោក ជុំ ស៊ីវ៉ាត់ អាចសម្រាកបានហើយ លោកអាចទៅសម្រាកនៅកន្លែងរៀបចំទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ហើយអង្គជំនុំជម្រះនឹងស្តាប់នូវដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត ។ អញ្ជើញ ។

មន្ត្រីតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី ជុំ នៅ មកកាន់ទីកន្លែងដែលបានរៀបចំទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះ ។ អញ្ជើញ ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលកាន់បន្ទប់សវនាការ)*

[១១:៣៥:១២]

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

លោកប្រធាន! ខ្ញុំសូមនិយាយនៅពេលនេះ ដោយសារតែជនជាប់ចោទ មានសេចក្តីសង្កេតចង់លើកឡើងក្រៅពីអ្វីដែលគាត់លើកឡើងអម្បាញ់មិញនេះ ។ ដូច្នេះហើយ គឺខ្ញុំសូមអនុញ្ញាត សូមឲ្យគាត់និយាយម្តងទៀតឲ្យគាត់លើកឡើងទៅលើបញ្ហានេះ ហើយយើងដឹងហើយថា នៅក្នុងនីតិវិធីនេះយើងដឹងទៅលើអ្វីដែលជនជាប់ចោទ គាត់ចង់លើកឡើង សូមអនុញ្ញាតពីលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ឃើញថា អម្បាញ់មិញនេះ គឺមានប្រតិកម្មពីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងអំឡុងពេលដែលជនជាប់ចោទធ្វើការកត់សម្គាល់ ។ ហើយការកត់សម្គាល់នោះទៀតសោត គឺនិយាយវាចេញឆ្ងាយអំពីអង្គហេតុដែលកើតមានឡើងនៅក្នុងស-២១ នៅក្នុងអំឡុងពេលបង្កើត និងប្រតិបត្តិការស-២១ ១៧ មេសា ៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩ ។ បើសិនជាការកត់សម្គាល់ឯណា ដែលអាចតបទៅនឹងសំណើសុំ ឬបំណងប្រាថ្នារបស់ដើមបណ្ដឹងប្បវេណី ដែលចង់ដឹងពីកាលបរិច្ឆេទនៃការទទួលមរណភាពរបស់ប្អូនរបស់គាត់ជាក់លាក់នោះសូមធ្វើ ដើម្បីឆ្លើយតបទៅនឹងអ្វីដែលគាត់ចង់បាន ។

ផ្ទុយទៅវិញ និយាយពីកត្តាប្រវត្តិសាស្ត្រនៅមុនឆ្នាំ៧០ឯណោះ វាធ្វើឱ្យខាតពេលវេលា ពីព្រោះពេលវេលាដែលសម្រាប់ធ្វើ ស្ដាប់សក្ខីកម្មសាក្សីដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ កំណត់ពីរម៉ោងប៉ុណ្ណោះ។ នេះជាការគណនាពេលវេលា ។ ឥឡូវ ជនជាប់ចោទមានបំណងចង់ធ្វើការសង្កេតទៀតដែរឬទេ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! អម្បាញ់មិញដែលខ្ញុំនិយាយនេះ គ្រាន់តែជាសេចក្ដីផ្ដើម ។ បញ្ជាជនដែលរត់ទៅជនបទជំនាន់នោះ មានប្រាំមួយនាក់ នៅពេលដែលធ្វើបាតុកម្មប្រឆាំង លន់ នល់ ។ ប្រាំមួយនាក់នេះ ខ្ញុំរាប់ឈ្មោះដូចតទៅ ទីមួយគឺ ម៉ម ណៃ ឆ្នាំ១៩៧៣, ទីពីរគឺ ជុំ ណារិត, ទីបីគឺ នួន ឃឿន, ទីបួនគឺ ព្រំ សំអារ, ទីប្រាំ គឺ គង់ សុឃុន ហើយទីមួយគឺ ទួន សុកផល្លា ។ នេះខ្ញុំនៅចាំទាំងអស់ ខ្ញុំតាមដានបញ្ហានេះទាំងអស់ ។

ដោយឡែកនៅពេលដែលខ្ញុំស្រាវជ្រាវក្នុងបញ្ជីនេះ ខ្ញុំឃើញឈ្មោះដូចតទៅ៖ ខ្ញុំឃើញឈ្មោះ នួន ឃឿន ហើយនិង ទួន សុផល្លា តែបាត់ឈ្មោះ ព្រំ សំអារ មិនឃើញ ហើយបាត់ឈ្មោះ ជុំ ណារិត ។ ដោយឡែកឈ្មោះ គង់ សុឃុន ខ្ញុំដឹងយូរហើយ មេប្រាប់ខ្ញុំ លោកគ្រូ សុន សេន ប្រាប់ខ្ញុំ ធ្វើអត្តឃាតនៅក្រសួងអប់រំ ដែលអ្នកបង យន់ យ៉ាត កាន់កាប់ ។ ក្នុងបញ្ជីរបស់ខ្ញុំនេះ អត់មានឃើញឈ្មោះ ជុំ ណារិត ទេ ក៏ប៉ុន្តែវាមានសលាកប័ត្រមួយនិយាយអំពី គឹម សុវណ្ណារី ។ ខ្ញុំថាបើគឹម សុវណ្ណារី ទៅដល់នោះហើយ ពិតជា ជុំ ណារិត ទៅហើយ ។ ដូច្នេះហើយ បានខ្ញុំសរសេរក្នុងនោះថា ខ្ញុំជឿការស្រាវជ្រាវរបស់លោក ជុំ ស៊ីរ៉ាត់ អំពីមរណភាពរបស់ប្អូនគាត់ ប្អូនថ្លៃគាត់ និងក្មួយគាត់នៅស-២១ ។

ឯចំណែក ជុំ ស៊ីរ៉េត នៅក្នុងបញ្ជីនេះសរសេរថា ពេទ្យមកពីសហករណ៍ ។ ដូច្នេះ ខ្ញុំគិតថាមនុស្សពីរនាក់ចាប់ដោយមូលហេតុផ្សេងគ្នា ឯចំណែក ជុំ ណារិត គឺចាប់ដោយចម្លើយអ្នកផ្សេងទៀត

រួមទាំងចម្លើយ ហ៊ូ នម ផង ។ ឯចំណែក ជុំ ស៊ីវ៉ាត់ (ស៊ិក) ប្រហែលជាចាប់មក ដោយចម្លើយអ្នកឯណាផ្សេងទៀតទេ មិនមែនមកជាមួយគ្នាទេ ។

អានេះជាការវិភាគរបស់ខ្ញុំជូន តាមឯកសារដែលនៅសល់មាន ជូនលោក ជុំ ស៊ីវ៉ាត់ តែប៉ុណ្ណឹងទេ ។ ខ្ញុំចង់បញ្ជាក់ប៉ុណ្ណឹង ដូច្នេះអត់មានចង់ប្រកែកប្រណាំងអីទេ បញ្ហាជនដែលទៅជនបទប្រាំមួយនាក់ហ្នឹង ខ្ញុំទៅដេកជាមួយមួយយប់ ។ ខ្ញុំសរសេរក្នុងហ្នឹងហើយ នេះសូមបញ្ជាក់សូមបញ្ជាក់ជូនលោក ជុំ ស៊ីវ៉ាត់ ប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

លោកអាចឆ្លើយតបនឹងបំណងរបស់គាត់ទេ? គាត់ចង់បំណងជាក់លាក់របស់គាត់ គឺគាត់ចង់ដឹងកាលប្បវត្តិនៃការចាប់ខ្លួនប្អូនរបស់គាត់ ហើយនិងកាលពីពេលដែលឃុំខ្លួន រហូតដល់ពេលយកទៅកម្ទេច ឬក៏យកទៅសម្លាប់នោះ ។ នេះជាបំណងដែលគាត់ប៉ង ចង់ដឹងជាក់លាក់ ។ ហើយបើអាចឆ្លើយថា ទីណាបានទៀតក៏ច្បាស់ដែរ ពីព្រោះដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនចង់ដឹងថា សាច់ញាតិលោហិតរបស់គាត់ហ្នឹងទៅកម្ទេចនៅទីកន្លែងណា? ក្នុងគោលបំណងដើម្បីធ្វើបុណ្យតាមប្រពៃណី តាមជំនឿសាសនា ព្រះពុទ្ធសាសនា ដែលគេប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា គេគោរពនៅក្នុងប្រទេសកម្ពុជានេះ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ថ្ងៃខែដែល ណារិត ចូលទៅ ហើយនិង គឹម សុវណ្ណារី ចូលទៅហ្នឹង ខ្ញុំអត់មាននៅក្នុងបញ្ជីនេះទេ ឃើញតែក្នុងសលាកប័ត្រមួយប៉ុណ្ណោះ ដូច្នេះខ្ញុំជឿថា ទាំងពីរនាក់ប្តីប្រពន្ធ ចូលទៅនៅទីនោះជាមួយគ្នា ។ ឯចំណែកថ្ងៃស្លាប់ ខ្ញុំជឿតាមលោក ស៊ីវ៉ាត់ ស្រាវជ្រាវវិញ ។ ឯចំណែក ស្លាប់នៅទីណា ខ្ញុំជាក់ស្តែងធ្វើមេគេមែន តែក្តាប់រឿងច្បាស់លាស់បែបនេះមិនបាន ។

នេះគឺសូមបញ្ជាក់ជូនដោយស្មោះ ។

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ ។

[១១:៤២:១០]

**ការតាំងសំណួរដោយចៅក្រម៖**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះ ជុំ នៅ អ៊ីចឹងពិតមែនដែរឬទេ?

**ឆ៖** តុលាការជាទីគោរព ។ នាងខ្ញុំឈ្មោះ ជុំ នៅ ពិតមែន ។

**ស៖** លោកស្រី ជុំ នៅ តើលោកស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មកដល់ឆ្នាំនេះ ខ្ញុំអាយុ៦០ឆ្នាំ ។

**ស៖** លោកស្រីកើតនៅទីកន្លែងណាដែរ?

**ឆ៖** និយាយអំពីស្រុកកំណើតហ្នឹង ត្រង់ហ្នឹងខ្ញុំសូមបញ្ជាក់ជូនលោកប្រធានឲ្យច្បាស់ថា ខ្ញុំមានស្រុកកំណើតពីរគឺ ស្រុកកំណើតទីមួយគឺ ខាងម្ដាយ គឺនៅឯភូមិ ព្រៃឫស្សី ឃុំជាខ្លាង ស្រុកព្រៃវែង ខេត្តព្រៃវែង ។ ហើយស្រុកកំណើតខាងឪពុកខ្ញុំ នៅឯភូមិវាល ឃុំកំពង់លាវ នៅទីក្រុងនៃខេត្តព្រៃវែង ។ អ៊ីចឹងចង់បញ្ជាក់ជូនលោកប្រធានឲ្យច្បាស់ កុំឲ្យថាខ្ញុំមានអត្តសញ្ញាណមិនច្បាស់ ព្រោះខ្ញុំអត្តសញ្ញាណប័ណ្ណរបស់ខ្ញុំ ខ្ញុំដាក់ភូមិកំណើតនៅភូមិកំណើតនៅភូមិវាល គឺនៅខាងឪពុក ហើយនិងប្រវត្តិរូបសង្ខេប ស-២១ ខ្ញុំដាក់នៅខាងម្ដាយ ។

**ស៖** សព្វថ្ងៃនេះលោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** ចាស, ជម្រាបប្រសាសន៍ ។ សព្វថ្ងៃខ្ញុំរស់នៅភូមិ ឯករាម ឃុំជើងទឹក ស្រុកកំពង់លាវ ខេត្តព្រៃវែង ។

**ស៖** លោកស្រីប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** ចា៎ ជម្រាបប្រសាសន៍ ខ្ញុំនៅផ្ទះដាំដំណាំ លក់។

**ស៖** ក្នុងអំឡុងពេលចន្លោះពីឆ្នាំ ពីថ្ងៃទី១៧ ខែមេសា ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ តើលោកស្រីរស់នៅទីកន្លែងណា? ហើយលោកស្រីធ្វើអ្វី?

**ឆ៖** ក្នុងចន្លោះឆ្នាំ១៩៧៥ មកដល់ ០៦ មករា ឆ្នាំ១៩៧៩ គឺក្នុងហ្នឹង ខ្ញុំចង់លម្អិតបន្តិចពីដើមបន្តិចព្រោះនៅឆ្នាំបែក៧៥ ១៧ មេសា ឆ្នាំ១៩៧៥ ហ្នឹងគឺខ្ញុំរស់នៅក្នុងអង្គភាពយោធានារីភូមិភាគបូព៌ា។ ហើយដល់ពេលយើងបែកភ្នំពេញថ្ងៃ១៧ មេសា ហ្នឹងបានត្រូវអង្គការឲ្យមករស់នៅទីក្រុងភ្នំពេញ ក្នុងក្រសួងភស្តុភារសេនាធិការ ហើយនៅថ្ងៃទី១២ ខែ០៨ ឆ្នាំ១៩៧៧ បានត្រូវចាប់ខ្លួនមកមន្ទីរស-២១ ។

**ស៖** ឪពុកបង្កើតរបស់លោកស្រីឈ្មោះ គាត់ឈ្មោះអ្វី?

**ឆ៖** ចាស, ជម្រាបប្រសាសន៍ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ មាឃ ជុំ ។

**ស៖** ចុះម្ដាយរបស់លោកស្រីគាត់ឈ្មោះអ្វី?

[១១:៤៥:៤៧]

**ឆ៖** ចាស ជម្រាបប្រសាសន៍គាត់ឈ្មោះ ខ្វែក សុខ ។

**ស៖** ស្ថានភាពគ្រួសាររបស់លោកស្រី តើសព្វថ្ងៃលោកស្រីមានប្តី ឬក៏លោកស្រីជាស្ត្រីមេម៉ាយ?

**ឆ៖** សព្វថ្ងៃខ្ញុំជាស្ត្រីមេម៉ាយ ដោយក្រោយពីឆ្នាំ៧៩មក គឺខ្ញុំបានយកគ្រួសារថ្មីមួយទៀត ក៏បានកូនមួយ ហើយគ្រួសារហ្នឹងក៏បានលែងលះបែកបាក់គ្នា ហើយឥឡូវហ្នឹងគាត់ក៏ស្លាប់ទៅទៀត ហើយសព្វថ្ងៃនៅកូនប្រុសមួយ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន ដើម្បីឡើងធ្វើសេចក្តីថ្លែងការណ៍សង្ខេបបង្ហាញ អំពីអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ នៅ ហេតុដែលនាំឱ្យឈ្មោះ ជុំ នៅ បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះ ។ ទំនាក់ទំនងនៃការប្តឹងទាមទារសំណងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ នៅ ទៅនឹងអង្គហេតុបទឧក្រិដ្ឋដែលចោទប្រកាន់ចំពោះជនជាប់ចោទ ពាក់ព័ន្ធទៅនឹងអង្គហេតុដែលកើតឡើងនៅក្នុងមន្ទីរសន្តិសុខស-២១ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៧ ខែមេសា ៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ៧៩ ។ ភស្តុតាងនានាដែលមានដើម្បីគាំទ្រដល់ការប្តឹងទាមទារសំណាង របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ នៅ ។ សូមអញ្ជើញ ។

**លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្ក៏៖**

សូមគោរពលោកប្រធាន! ហើយខ្ញុំសូមបញ្ជាក់ថា អត្ថបទបកប្រែក្នុងភាសាអង់គ្លេសនៅពេលដែលលោកស្រី ជុំ នៅ និយាយនោះ គឺថាគាត់បានបញ្ជូនទៅគេចាប់គាត់ទៅស-២១ ប៉ុន្តែការបកប្រែថាទៅជាស-២៤ ។ ខ្ញុំគិតថា ប្រហែលជានៅក្នុងការបក ទៅជាភាសាបារាំងក៏ប្រហែជាស-២១ ដែរ ។ ដើម្បីបញ្ជាក់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឱ្យគាត់បញ្ជាក់ឱ្យបានច្បាស់ចំណុចនេះ តើបានទេ?

**សួរដោយប្រធានអង្គជំនុំ៖**

ជាភាសាខ្មែរ គាត់និយាយថា ស-២១ ។

**ស៖** លោកស្រី ជុំ នៅ តើពួកខ្មែរក្រហមចាប់លោកស្រីទៅឃុំខ្លួននៅទីកន្លែងណា? នៅស-២១ ឬស-២៤?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ពាក្យដែលខ្ញុំនិយាយថាស-២១ នេះគឺខ្ញុំនិយាយតាមឯកសារទេ តាមពិតគឺខ្ញុំមិនបានទៅនៅកន្លែងទួលស្លែងទេ ។ ប៉ុន្តែ កន្លែងដែលខ្ញុំនៅហ្នឹងវាជាសាខារបស់ស-២១ ។ ដំបូងគឺគេចាប់ខ្ញុំទៅហ្នឹង នៅមន្ទីរព្រៃកត្នោតតាខ្មៅហ្នឹង ដែលពីសង្គមជាមន្ទីរពេទ្យ

ឆ្អួត។ គឺមិនដល់រយៈពេលមួយថ្ងៃទេ ដល់ថ្ងៃរសៀលបានគេបញ្ជូនខ្ញុំទៅស្ទឹងជ្រៅ ។ ស្ទឹងជ្រៅហ្នឹងគេឲ្យដើរពីមន្ទីរព្រៃកន្ទោតហ្នឹងទៅ ។

[១១:៤៩:២៣]

អ៊ីចឹងនៅពេលដែលដល់ស្ទឹងជ្រៅហ្នឹង គឺកាលដែលខ្ញុំទៅហ្នឹង គឺខ្ញុំមានផ្ទៃពោះផង ដោយខ្ញុំបានរៀបការនៅឆ្នាំ១៩៧៦ ដែលត្រូវអង្គការរៀបការ ។ ហើយនៅពេលហ្នឹង ខ្ញុំនៅស្ទឹងជ្រៅហ្នឹង ទាល់តែខ្ញុំឆ្លងទន្លេរួច ហើយបានគេបញ្ជូនខ្ញុំទៅព្រៃស។ ព្រៃសហ្នឹងកាលហ្នឹងគេហៅស-២៤។ ហើយដល់ពេល--

**ប្រធានអង្គជំនុំ៖**

ប៉ុណ្ណឹងសិនហើយ ព្រោះយើងសួរតែអត្តសញ្ញាណ ពាក់ព័ន្ធនឹងអត្តសញ្ញាណមួយចំនួនប៉ុណ្ណោះ ចំណែកឯសេចក្តីថ្លែងការណ៍ គឺលោកស្រីនឹងមានឱកាសថ្លែងការណ៍ បន្ទាប់ពីលោកមេធាវីរបស់លោកស្រីធ្វើការបញ្ជាក់ដោយសង្ខេបនូវបញ្ហាមួយចំនួន ដែលយើងបានកំណត់ទៅមេធាវីតំណាងរបស់លោកស្រីក្នុងការឡើងធ្វើសេចក្តីថ្លែងការណ៍ដំបូងនេះ ។ សូមអញ្ជើញ ។

**លោក ហុង គីមសួន៖**

សូមអរគុណ ។ ខ្ញុំបាទ មេធាវី ហុង គីមសួន ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមទីពីរផង និងក្រុមទីបួននោះផង ។ សូមគោរពលោកប្រធាន លោក លោកស្រីក្រុមប្រឹក្សានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាទីគោរព និងអង្គសវនាការទាំងមូល ។

នៅក្នុងរឿងក្តីនេះ កូនក្តីខ្ញុំបាទអ្នកស្រី ជុំ នៅ ជាជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនដាក់ចូលទៅក្នុងសំណុំរឿងរួច ហើយត្រូវបានអង្គជំនុំជម្រះផ្នែកសហចៅក្រមស៊ើបអង្កេតទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨ ។ ហើយដែលមានឯកសារស្តីអំពីភស្តុតាងបញ្ជាក់ថា គាត់ជាជនរងគ្រោះនៅក្នុងមន្ទីរស-២១ ដែលគ្របដណ្តប់ទៅលើមន្ទីរស-២៤ ដែលគាត់បានរៀបរាប់ជូនអង្គសវនាការអម្បាញ់មិញនេះ នៅក្នុងឯកសារ ERN D25/16/2 ជាភាសាខ្មែរ (សុំទោស) លេខ ERN 00211380 និងឯកសារលេខ D25/16/2 ជាភស្តុតាងបញ្ជាក់អំពីការរស់នៅក្នុងមន្ទីរឃុំឃាំងនៃស-២៤ ដែលជាសាខារបស់មន្ទីរស-២១ ។

[១១:៥២:៣៩]

សូមជម្រាបលោកប្រធានផងដែរ អ្នកស្រី ជុំ នៅ មិនមែនជាជនរងគ្រោះតែម្នាក់ឯងនៅក្នុងពេលនោះទេ ។ គឺក្នុងអំឡុងនោះដែរ ស្វាមីរបស់អ្នកស្រីម្នាក់ទៀតឈ្មោះ នូ មឿន ដែលត្រូវបានពួកខ្មែរ

ក្រហមចាប់ខ្លួនគាត់យកទៅធ្វើទារុណកម្មនៅមន្ទីរស-២១ ដែលសព្វថ្ងៃហៅថា សារមន្ទីរទួលស្លែង និងត្រូវបានសម្លាប់ចោលនៅទីនោះផងដែរ និងមួយទៀតគឺទាក់ទងនឹងកូនបង្កើតរបស់អ្នកស្រី ជុំ នៅ ផងដែរដែលបានប្រសូត្រ នៅពេលដែលបញ្ជូនគាត់ទៅដល់មន្ទីរស-២១ និងបានដាច់ដោះស្គមមានជំងឺរហូតដល់ស្លាប់ទៅទៀត ។

អ៊ីចឹងនៅក្នុងរឿងនេះ គឺគាត់ជាជនរងគ្រោះមួយ ស្វាមីរបស់គាត់មួយ និងកូនបង្កើតរបស់គាត់មួយ ដែលរងទារុណកម្មយ៉ាងធ្ងន់ធ្ងរទាំងផ្លូវកាយផ្លូវចិត្ត រហូតបាត់បង់ជីវិត ។ ហើយនៅរស់តែអ្នកស្រី ជុំ នៅ ម្នាក់ប៉ុណ្ណោះ ។

ឯកសារដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ទាក់ទងនឹងប្តីគាត់ ស្វាមីរបស់គាត់ឈ្មោះ នូ មឿន ហៅ សែម មាននៅក្នុងបញ្ជីឈ្មោះអ្នកទោស នៃមន្ទីរស-២១ យើងហៅ គុកទួលស្លែងសព្វថ្ងៃនេះ ដែលក្នុងបញ្ជីអ្នកទោស ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ក្នុងលេខរៀង៦៧០៨ នៃលេខ ERN 0171 629 និងបញ្ជីអ្នកទោស លេខ៦១ ក្នុងមន្ទីរស-២១ ដដែល ERN លេខ 00181657 និងឯកសារបញ្ជីអ្នកទោសនៅក្នុងមន្ទីរស-២១ ផងដែរ មានលេខ៣០៣០ លេខ ERN 00331375 និងឯកសារបន្តទៀតនៅក្នុងមន្ទីរស-២១ ផងដែរ ដែលមានលេខអ្នកទោស ១៨២៧ មានលេខ ERN 00331803 ។

បញ្ជីមួយទៀតនៃមន្ទីរស-២១ បញ្ជីអ្នកទោសផងដែរ មានលេខ ៣២១០ ដែលមាន ERN 003 31076 នេះជាឯកសារ ជាភស្តុតាងបញ្ជាក់អំពីស្វាមីអ្នកស្រី ជុំ នៅ ដែលមានឈ្មោះថា ជុំ មឿន ហៅ សែម ។ ហើយឯកសារអត្តសញ្ញាណប័ណ្ណ ប្រជាពលរដ្ឋកម្ពុជាសព្វថ្ងៃរបស់អ្នកស្រី ជុំ នៅ ដែលដាក់ទៅក្នុងឯកសារហើយនោះ មានលេខ ERN 00211379 ។ ហើយឯកសារប្រវត្តិរូបអម្បាញ់មិញខ្ញុំបាទបានជម្រាបរួចហើយ ដែលធ្វើនៅមន្ទីរស-២១ តែការពិតនៅមន្ទីរស-២៤ ដូចគាត់បានជម្រាបលោកប្រធានអម្បាញ់មិញ គឺមានលេខ ERN 00211380 ។

នៅក្នុងរឿងនេះ អ្នកស្រី ជុំ នៅ គឺជាជនរងគ្រោះទាមទារប្តឹងទាមទារឲ្យរកយុត្តិធម៌ឲ្យគាត់ ដោយសារ ពួកដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើទុក្ខបុកម្នេញ ទាំងរូបកាយទាំងផ្លូវចិត្ត និងសម្លាប់ស្វាមីគាត់ និងកូនបង្កើតរបស់គាត់មួយទៀត ។

[១១:៥៧:១៨]

ហើយគាត់នឹងទាមទារសំណងជំងឺចិត្ត អំពីការស្វែងរកយុត្តិធម៌របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បើឃើញថា ជនជាប់ចោទមានទោសនៅក្នុងបទចោទទាំងឡាយនេះ គឺអ្នកស្រីនឹងធ្វើ

ការទាមទារសំណងជំងឺចិត្ត និងសំណងជាសមូហភាពនៅពេលជិតចុងបញ្ចប់នៃសវនាការលើកទីមួយនេះ ។

ហើយបន្តទៅទៀតនេះ ខ្ញុំបាទក៏សូមជម្រាបលោកប្រធាន និងអង្គសវនាការផងដែរថា អ្នកស្រី ជុំ នៅ គឺជាជនរងគ្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលចេញអំពីការបោសសម្អាត ឬការកម្ទេចដែលជនជាប់ចោទ តែងតែលើកថា ការសម្អាត ឬការកម្ទេចខ្មាំងផ្ទៃក្នុងរបស់ក្រុមកម្ពុជាប្រជាធិប-តេយ្យនោះ ។ ហើយប្រវត្តិនៃរឿងរ៉ាវទាំងឡាយទាក់ទិនជាមួយនឹងការចូលធ្វើបដិវត្ត ជាមួយក្រុមកម្ពុជាប្រជាធិបតេយ្យមុនឆ្នាំ១៩៧៥ និងចាប់ពីថ្ងៃទី១៧ មេសា ១៩៧៥ រហូតដល់ពេលត្រូវបានអង្គការពួកខ្មែរក្រហមចាប់គាត់ទៅធ្វើទារុណកម្ម និងធ្វើទុក្ខធ្វើទោសនោះជាវគ្គទីពីរ និងវគ្គទីបី ក្រោយពេលដែលវៀតណាមបានវាយចូលរំដោះប្រទេសកម្ពុជាថ្ងៃ០៧ មករា ឆ្នាំ១៩៧៩មក អ្នកស្រីត្រូវបានរងទុក្ខមួយសាទៀត ទៅជាមួយនឹងជនជាប់ចោទតែម្តង រហូតទៅដល់ទឹកដីនៃខេត្តពោធិសាត់ បាត់ដំបងតទៅទៀត ។

ខ្ញុំបាទសូមសង្ខេបត្រឹមនេះ និងសូមឲ្យលោកប្រធានអនុញ្ញាតឲ្យអ្នកស្រីរៀបរាប់អំពីដំណើររឿងដូចតទៅទៀតបាទ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ អ៊ីចឹង អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់។ ហើយដំណើរការសវនាការចាប់បន្តនៅវេលាម៉ោងមួយសាមសិបនាទីរសៀលនេះ ។

លោកស្រី ជុំ នៅ អាចសម្រាកបាន ហើយអញ្ជើញលោកស្រីមកកាន់ទីនេះ នៅម៉ោងមួយសាមសិបនាទីរសៀលនេះ ដើម្បីធ្វើសេចក្តីថ្លែងការណ៍ អំពីការប្តឹងទាមទាររបស់លោកស្រី អំពីទុក្ខលំបាករបស់លោកស្រីដែលលោកស្រីជួបប្រទះ នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ។ អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំជនជាប់ចោទមកកាន់សាលសវនាការវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី ។

*[សវនាការសម្រាកពីម៉ោង ១២:០០នាទី ដល់ម៉ោង ១៣:៣៦នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយតាមកាលវិភាគដែលបានធ្វើព្រឹកមិញ គឺយើងបន្តនូវការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំនៅ ប៉ុន្តែដោយមានការប្រែប្រួលបន្តិច ដោយព័ត៌មានថ្មីដែលផ្តល់ដោយអ្នកបច្ចេកទេសខាងសោតទស្សន៍បានបង្ហាញថា លទ្ធភាពក្នុងការស្តាប់សេចក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អ៊ូ សាវរិត ដែលធ្វើសេចក្តីថ្លែងការណ៍ពីចម្ងាយពីប្រទេសបារាំងតាមប្រព័ន្ធវីដេអូខនហ្វើរិនហ្នឹងគឺអាចធ្វើបាន ។ ដូច្នេះ ការដែលព្រឹកមិញថា យើងកម្មវិធីដំណើរការសវនាការបន្តត្រូវស្តាប់សេចក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ នៅ នោះ គឺយើងធ្វើការពន្យារពេល គឺត្រូវធ្វើក្រោយស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អ៊ូ សាវរិត ដែលត្រូវធ្វើពីចម្ងាយតាមម៉ោងកំណត់ គឺយើងចាប់ផ្តើមពេលម៉ោងមួយកន្លះនេះ ។

ឥឡូវនេះ យើងចាប់ផ្តើមធ្វើការស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ សាវរិត តាមប្រព័ន្ធវីដេអូខនហ្វើរិន ។ ហើយផ្នែកខាងបច្ចេកទេស សូមធ្វើការរៀបចំប្រព័ន្ធនេះ ដើម្បីឲ្យដំណើរការ ។ ហើយវំពូកឡើងវិញ អ៊ូ សាវរិត នេះ មានមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន ។

**ការតាំងសំណួរដោយចៅក្រម៖**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោក អ៊ូ សាវរិត ។

**ឆ៖** ជម្រាបសួរលោកប្រធាន ។

**ស៖** តើលោកឈ្មោះ អ៊ូ សាវរិត អីចឹងពិតមែនដែរឬទេ?

**ឆ៖** បាទ ។

**ស៖** លោក អ៊ូ សាវរិត តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំអាយុ ៥៣ឆ្នាំ ហើយនិងមានអាយុ ៥៤ឆ្នាំនៅខែតុលាឆ្នាំនេះ ។

**ស៖** តើលោកមានសញ្ជាតិអ្វីដែរ?

**ឆ៖** ខ្ញុំសញ្ជាតិ--

**ស៖** លោក អ៊ូ សាវរិត តើលោកមានសញ្ជាតិអ្វី?

[១៣:៤១:០៣]

**ផ៖** លោកប្រធាន! ខ្ញុំមានសញ្ជាតិបារាំង ។

**ស៖** តើទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណា?

**ផ៖** លោកប្រធាន! ខ្ញុំកើតនៅខេត្តកំពង់ចាម ។

**ស៖** តើទីលំនៅដ្ឋានបច្ចុប្បន្ននៅទីកន្លែងណា? ហើយលោកប្រកបមុខរបររកស៊ីអ្វីសព្វថ្ងៃនេះ?

**ផ៖** ខ្ញុំរស់នៅផ្ទះលេខ៥០ ផ្លូវរ៉ាំងសង់ រ៉ាំងហ្គាស លេខកូដ ៧៨៣៧០ សង្កាត់ភ្លឺសៀរ ប្រទេសបារាំង ។ មុខរបររបស់ខ្ញុំ ខ្ញុំជាប្រធាន ជានាយកប្រធាននៃបណ្តាញខាងអចលវត្ថុមួយ ។

**ស៖** នៅចន្លោះឆ្នាំខែមេសា ១៩៧៥ រហូតដល់ថ្ងៃទី៧ មករា ៧៩ តើលោករស់នៅទីកន្លែងណា?

**ផ៖** ខ្ញុំបានរស់នៅប្រទេសបារាំង ។

**ស៖** ឪពុកបង្កើតរបស់លោក គាត់ឈ្មោះអ្វី? ហើយសព្វថ្ងៃនេះ គាត់នៅរស់ ឬក៏គាត់ទទួលមរណភាពហើយ?

**ផ៖** ឪពុកឈ្មោះ អ៊ូ គឹមសាន គាត់បានទទួលមរណភាពនៅឆ្នាំ១៩៧២ ។

**ស៖** ចុះម្តាយរបស់លោក គាត់ឈ្មោះអ្វី? ហើយសព្វថ្ងៃនេះ គាត់នៅរស់ ឬក៏គាត់ទទួលមរណភាពហើយ?

**ផ៖** ម្តាយរបស់ខ្ញុំ ណៃ ស៊ីដូនី ហើយគាត់ស្លាប់នៅប្រទេសខ្មែរ ។ ខ្ញុំមិនដឹងថាគាត់ស្លាប់នៅកន្លែងណា ហើយដឹងថា មិនដឹងស្លាប់នៅឆ្នាំណាដែរ ។

**ស៖** លោក អ៊ូ សាវរិត តើលោកមានបងប្អូនបង្កើតប៉ុន្មាននាក់?

**ផ៖** ខ្ញុំមានបងប្អូនប្រុសពីរ ហើយនិងបងប្អូនស្រីពីរនាក់ ។ បងប្អូនប្រុសទាំងពីររបស់ខ្ញុំបានស្លាប់នៅប្រទេសកម្ពុជា ។ បងប្រុសរបស់ខ្ញុំ-- បងទីពីរ គឺបងស្រី គាត់ឈ្មោះ អ៊ូ ជុំម៉ាក់ ហើយគាត់រស់នៅក្នុងប្រទេសបារាំង ។ ប្អូនប្រុសទីបី ក៏បានស្លាប់នៅប្រទេសកម្ពុជាដែរ ក្នុងចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩ ។ ប្អូនស្រីមួយឈ្មោះ អ៊ូ ណាក់ប៉េត ក៏រស់នៅប្រទេសបារាំង ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន ដើម្បីមេធាវីឡើងធ្វើសេចក្តីថ្លែងការណ៍ដោយសង្ខេបបង្ហាញពីអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ សាវរិត ហេតុដែលនាំឲ្យ អ៊ូ សាវរិត បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះ ទំនាក់ទំនងនៃ

ការប្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ូ សាវរិត ទៅនឹងបទឧក្រិដ្ឋដែលចោទប្រកាន់ទៅលើជនជាប់ចោទ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ពាក់ព័ន្ធទៅនឹងអង្គហេតុនៃមន្ទីរសន្តិសុខ ស-២១ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃពី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នឹងភស្តុតាងនានា ដែលមានដើម្បីគាំទ្រដល់ការប្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អ៊ូ សាវរិត ។ សូមអញ្ជើញ ។

[១៣:៤៦:៣៨]

**លោក ហុង គីមសួន៖**

ខ្ញុំសូមអរគុណ និងខ្ញុំបាទសូមគោរពលោកប្រធានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លោក លោកស្រីចៅក្រមនៃក្រុមប្រឹក្សាអង្គជំនុំជម្រះជាទីគោរព និងសូមគោរពអង្គសវនាការជាទីគោរព! នៅក្នុងរឿងក្តីនេះ គឺកូនក្តីខ្ញុំបាទនាពេលនេះ ឈ្មោះលោក អ៊ូ សាវរិត ដែលបានថ្លែងតាម ប្រព័ន្ធវីដេអូលីងពីប្រទេសបារាំងជូនលោកប្រធានអម្បាញ់មិញ ខ្ញុំបាទគ្រាន់តែលើកឡើងថា និងកញ្ញាមួយដែលអង្គុយជាប់នៅនឹងគាត់ឈ្មោះ ចេស្ស៊ីកា ដែលលោកប្រធានក៏បានទទួលស្គាល់ទៅតាមផ្លូវច្បាប់នៅក្នុងការចូលស្តាប់ និងអមកូនក្តីខ្ញុំបាទរួចហើយ ដែលជាបងបង្កើតរបស់លោក អ៊ូ វិនឌី ។ ខ្ញុំបាទសូមអនុញ្ញាតលោកប្រធានជូនឯកសារជារូបភាពចំនួនបួនទំព័រ និងជូនទៅភាគីសហព្រះរាជអាជ្ញាផង និងខាងលោកមេធាវីខាងការពារផង ។ ដោយក្នុងនេះ រូបទីមួយ គឺជារូបថតរបស់ វិនឌី ដែលជាជនរងគ្រោះ ដែលបានទទួលមរណភាពនៅមន្ទីរស-២១ ឬគុកទួលស្លែង ។ ហើយសូមអនុញ្ញាតដាក់បញ្ចាំងជារូបភាពតែម្តង ។ សូមអនុញ្ញាតលោកប្រធាន ដើម្បីបញ្ជាក់ជូន ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយមន្ត្រីតុលាការរៀបចំដាក់បញ្ចាំងនូវម៉ាស៊ីនស្លាយ ដើម្បីបង្ហាញរូបភាពនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**លោក ហុង គីមសួន៖**

ខ្ញុំបាទសូមឆ្លៀតឱកាសនេះផងដែរ សូមជម្រាបជូនលោកប្រធាន និងលោក លោកស្រីចៅក្រមជ្រាបថា ឯកសារបួនទំព័រនេះ ដែលខ្ញុំបាទដាក់ជម្រាបលោកប្រធាននិងភាគីផងដែរនេះ មិនទាន់មានចុះលេខ ERN នោះទេ ដោយសារនៅក្នុងសំណុំរឿងដើម ខ្ញុំបាទរកមិនបានឃើញ ។ ដូច្នេះ ខ្ញុំបាទសូមអនុញ្ញាតលោកប្រធានទទួលយកឯកសារនេះដាក់បញ្ចូលទៅក្នុងសំណុំរឿងតែម្តងផង ទាំងបួនទំព័រនេះ

គឺទីមួយ រូបភាពលោក អ៊ូ វិនឌី ដែលបានទទួលមរណភាព ហើយនេះទីមួយ ។ សូមដាក់ទីពីរ ។ រូបទីពីរនេះ គឺរូបថតកូនក្ដីខ្ញុំកំពុងតែនិយាយនៅក្នុងទូរទស្សន៍វីដេអូជូនលោកប្រធាន ឈ្មោះលោក អ៊ូ សាវរិត ដែលនៅក្នុងនេះអត្តសញ្ញាណរបស់គាត់សរសេរជាភាសាបារាំង ដាក់ឈ្មោះ អ៊ូ សាវរិត កើតនៅថ្ងៃទី១ ខែ១០ ឆ្នាំ១៩៥៥ ដូចមាននៅក្នុងរូបភាពនេះស្រាប់ ។

[១៣:៥០:០០]

ហើយរូបទីបី ទំព័រទីបី គឺជាបញ្ជីកំណើត ឬយើងហៅថា សំបុត្រកំណើតដែលសរសេរជាភាសាបារាំងផងដែររបស់លោក អ៊ូ សាវរិត ហើយក្នុងនេះជាភាសាបារាំង ។ ខ្ញុំបាទក៏សូមឲ្យលោកប្រធានទទួលស្គាល់ផងដែរ ដែលមានឪពុកឈ្មោះ អ៊ូ គឹមសាន ម្ដាយឈ្មោះ ណៃ ស៊ីដូនី ដែលមានប្រថាប់ត្រាជាភាសាបារាំងនៅលើទំព័រនេះស្រាប់ ។

សូមអនុញ្ញាតបន្តទំព័រទីបួនៗ នេះដោយជាភាសាបារាំងខ្ញុំបាទគ្រាន់តែយល់ថា ជាការរៀបរាប់ពន្យល់អំពីឯកសារដូចជម្រាបអម្បាញ់មិញនេះ ។ អ៊ីចឹង ខ្ញុំបាទសូមអនុញ្ញាតលោកប្រធានទទួលយកឯកសារទាំងអស់នេះ ដាក់ទៅក្នុងសំណុំរឿង ។ ហើយបន្តទៅទៀតខ្ញុំបាទសូមរៀបរាប់ដោយសង្ខេបទាក់ទិនជាមួយនឹងកូនក្ដីខ្ញុំបាទឈ្មោះ អ៊ូ សាវរិត ដែលគាត់បានប្ដឹង--

[១៣:៥១:១៩]

**ប្រធានអង្គជំនុំ៖**

ឈប់ៗមេធាវី តើមានការមតិយោបល់យ៉ាងម៉េច អំពីការស្នើសុំដាក់ឯកសាររូបថត ហើយនិងឯកសារសរុបបួនទំព័ររបស់មេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីនេះ?

**លោកស្រី ម៉ារីប៉ូល កានីហ្សរេស៖**

លោកប្រធាន យើងទើបតែបានឃើញរូបថតលោកមេធាវីបានលើកបង្ហាញហ្នឹង គឺសូមឲ្យបង្ហាញអំពីភាពដែលអាចជឿជាក់នៅលើរូបថតដែលបង្ហាញនេះ ។

**ប្រធានអង្គជំនុំ៖**

មេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី សូមបង្ហាញពាក់ព័ន្ធជាមួយនឹងរូបថត និងពាក់ព័ន្ធទៅនឹងសំណុំរឿងទំនាក់ទំនងរវាងភាគីដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងរូបថតដែលអះអាងថា ជនរងគ្រោះនេះ ។ និយាយឲ្យបានលម្អិត ដើម្បីមានមេធាវីតំណាងឲ្យ-- មេធាវីការពារក្ដីលោកមានការគិតគូរពិចារណា ហើយនឹងសម្រេចធ្វើការកត់សម្គាល់នៅក្នុងបញ្ហាឯកសារដែលលោកស្នើសុំដាក់ចំពោះមុខ

អង្គជំនុំជម្រះនៅពេលនេះ ។

[១៣:៥២:៤៧]

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ។ តាមពិតទៅរូបថតនេះ មិនមែនជារូបថតដែលខ្ញុំបាទផ្ទាល់បានទៅរកឃើញនោះទេ គឺជាឯកសារដែលកូនក្តីខ្ញុំបាទ អ៊ូ សាវរិត ដែលគាត់អះអាងថា ជាបងបង្កើតនិងគាត់ស្វែងរកបានដោយខ្លួនគាត់និងដាក់បញ្ជូនមកតែប៉ុណ្ណោះ ។ ដូច្នេះ បើនិយាយអំពីភាពជាក់លាក់ថា តើរូបនេះពិតទេ ថាមានទំនាក់ទំនងត្រូវជាសាច់ញាតិ ជាបង ជាប្អូនជាមួយជាមួយលោក អ៊ូ សាវរិត? ខ្ញុំបាទសូមអនុញ្ញាតនៅពេលក្រោយ ដែលលោក អ៊ូ សាវរិត នឹងមានឱកាសនឹងជម្រាបជូន ដើម្បីឲ្យគាត់ជម្រាបជូនលោកប្រធាន ។ ហើយខ្ញុំបាទក៏សូមឆ្លៀតឱកាសផងដែរថា បើសិនជាការទាមទាររកភស្តុតាងពិតប្រាកដថា តើរូបថតណា ឈ្មោះណាពិតជាជនរងគ្រោះនៅក្នុងមន្ទីរស-២១ ឬគុកទួលស្លែងជាប់ពាក់ព័ន្ធមែននោះ? ដូច្នេះទាល់តែទាំងអស់ជនរងគ្រោះដែលបានស្លាប់មានរូបថត និងអ្នកដែលរស់អះអាងនោះបង្ហាញដូចគ្នា ហើយក៏ដូចជាជនជាប់ចោទដូចគ្នាដែរ បង្ហាញទៅវិញទៅមកថាភាពទាក់ទិននោះមានដូចគ្នា ឬអត់? ជឿយ៉ាងម៉េច ធ្វើ-- (សូមទោស) ធ្វើ DNA ដែរឬទេ? ដើម្បីឲ្យដឹងថា អ្នកដែលស្លាប់ជាបងជាប្អូនឬមិនមែននោះ? សូមឲ្យលោកប្រធានក៏ពិចារណានូវចំណុចនេះផងដែរ ។

[១៣:៥៤:០៤]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅមេធាវីការពារក្តី តើមានអ្វីកត់សម្គាល់អំពីឯកសារចំនួនបួនទំព័រ ទាំងរូបថតផងនេះ ដែលមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដេញដោលនៅពេលនេះ?

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

មេធាវីការពារមិនមានជំទាស់អ្វីទេ លោកប្រធានអំពីការបង្ហាញការផលិតឯកសារនេះ។ សំណួររបស់ខ្ញុំគឺចង់សួរថា យើងធ្លាប់ៗ-- យើងគ្រាន់តែបញ្ជាក់ថា យើងទើបតែបានទទួលឯកសារទាំងអស់នេះ ហើយយើចង់បានព័ត៌មានបន្ថែមទាក់ទងទៅនឹងភាពដែលជឿជាក់បាននៃទំព័រទីមួយអំពីប្រភពរបស់ឯកសារនោះ រូបថតនោះ ។

[១៣:៥៥:០២]

**ប្រធានអង្គជំនុំ៖**

ឥឡូវយើងជំនុំជម្រះសម្រេចទទួលយកឯកសារនេះដាក់នៅក្នុងសំណុំរឿង ហើយមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី សូមបន្តនូវសេចក្ដីថ្លែងការណ៍ក្នុងការបញ្ជាក់ហេតុផលផ្សេងៗពាក់ព័ន្ធទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាកូនក្ដីរបស់លោកនៅក្នុងសំណុំរឿងករណីនេះ ។

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទសូមបន្ថែមបន្តិចទៀត នូវការសង្ខេបស្ដីអំពីប្រវត្តិទាក់ទិនរវាងកូនក្ដីខ្ញុំបាទ អ៊ូ សាវរិត និងឈ្មោះ អ៊ូ វិនឌី ដែលត្រូវជាប្អូនបង្កើតរបស់គាត់ ។

នៅក្នុងសំណុំរឿងដែលមានស្រេចរួចមកហើយមានលេខឯកសារ លេខ ERN ជាភាសាខ្មែរ 00274308 ឬឯកសារលេខ E2/31.4 និយាយអំពីប្រវត្តិរូបសង្ខេបរបស់ អ៊ូ វិនឌី ដែលត្រូវបានធ្វើទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានន័យថា នៅពេលដែលចាប់ខ្លួនអង្គការរបស់ខ្មែរក្រហម ឬយើងហៅថា ពួកកម្ពុជាប្រជាធិបតេយ្យនោះ ។ នេះជាឯកសារគាំទ្របង្ហាញអំពីឈ្មោះ អ៊ូ វិនឌី ដែលត្រូវបានចាប់ខ្លួនមុននឹងយកទៅធ្វើឃាត ហើយក៏មានឯកសារភ្ជាប់ដែលដាក់ក្នុងសំណុំរឿងរួចហើយ ។ ក្នុងបណ្ដុំឯកសារនេះ ខ្ញុំបាទសូមមិនរាយច្រើនពេកទេ ខ្ញុំបាទលើកយកចំតែឈ្មោះ អ៊ូ វិនឌី មួយអម្បាញ់មិញនេះ ។ ប៉ុន្តែ ក្នុងបណ្ដុំឯកសារមានចាប់ពីលេខ 00274265 ទៅទល់នឹងលេខ 00274314 ឯកសារទាំងអស់នេះ គឺស្ថិតនៅក្នុងឯកសារ E2/31.4 ដែលមានការស៊ើចង្វាក់គ្នាជាមួយនិងឈ្មោះ អ៊ូ វិនឌី ។ មានន័យថា ក្នុងនេះមានជាប់សាច់ញាតិទាំងសាចឈាមបង្កើត និងសាច់ឈាមជាសាច់ថ្លៃរបស់ក្រុមគ្រួសាររបស់លោក អ៊ូ សាវរិត ផងដែរ ។

[១៣:៥៧:៥៥]

សូមលោកប្រធាន អនុញ្ញាតពិចារណាតាមក្រោយទៀត ដែលឯកសារនេះបានដាក់ចូលរួមទៅហើយ ។ ហើយបន្តទៅទៀតនេះ ខ្ញុំបាទសូមជម្រាបថា នៅក្នុងឯកសារដែលរាយការណ៍របស់ឈ្មោះ អ៊ូ វិនឌី ផងដែរ ខ្ញុំបាទសូមអនុញ្ញាតមិនមានលេខ ERN នៅចំពោះរបស់ខ្ញុំទេ ព្រោះខ្ញុំបាទទទួលផ្ទាល់មកប៉ុន្តែមាននៅក្នុងសំណុំរឿងដែលខ្ញុំបាទរកមិនឃើញទាន់ឃើញ ERN ព្រោះដាក់ដំណាលគ្នា តែខ្ញុំបាទរកបើកវាមិនចេញនៅក្នុងវេបសាយ ឬក៏ក្នុងមែលអាខោន (Mail Account) នោះ ។

អ៊ីចឹងបន្តទៅទៀតនេះ គឺខ្ញុំបាទសូមជម្រាបលោកប្រធាន និងអង្គសវនាការជ្រាបថា ទុក្ខលំបាកឬការធ្វើទារុណកម្មទាំងឡាយទៅលើឈ្មោះ អ៊ូ វិនឌី ដែលជាប្អូនបង្កើតរបស់លោក អ៊ូ សាវរិត កូនក្ដីខ្ញុំ

បាទនេះ ទម្រាំនឹងទទួលមរណភាព ឬត្រូវបានធ្វើឃាត ក្រោមការគ្រប់គ្រងរបស់លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច នៃមន្ទីរស-២១ ក្នុងជំនាន់របបកម្ពុជាប្រជាធិបតេយ្យនោះ គឺមានទុក្ខលំបាកវេទនារកថ្លែងមិនបាន ឬមិនអាចកាត់ថ្លៃបានថា ទុក្ខវេទនាប៉ុនណានោះទេ ។

[១៣:៥៩:១៣]

ដូច្នេះ អ្នកដែលនៅរស់ជាសាច់ញាតិ ជាបងជាប្អូន គឺលោក អ៊ូ សាវរិត នេះគាត់សូមឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជួយរកយុត្តិធម៌ គឺជួយស្វែងរកការពិតអំពីរឿងបងប្អូនបង្កើតរបស់គាត់ត្រូវបានអ្នកដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ដែលក្នុងនោះដែលមានលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាប្រធានមន្ទីរស-២១ ជាអ្នកទទួលខុសត្រូវផងនោះ សូមឲ្យលោកប្រធានស្វែងរកយុត្តិធម៌ និងការពិតអំពីមូលហេតុនៃការសម្លាប់ អ៊ូ វិនឌី និងសាច់ឈាមរបស់លោក អ៊ូ សាវរិត ក្នុងពេលបន្តទៅទៀតនេះ ។

ហេតុនេះខ្ញុំបាទ បន្តទៅទៀតនឹងសូមឲ្យលោកប្រធានអនុញ្ញាតឲ្យលោក អ៊ូ សាវរិត ធ្វើសេចក្តីថ្លែងការណ៍រៀបរាប់អំពីប្រវត្តិរឿងនេះតទៅ ។ សូមអរគុណ ។

[១៤:០០:០៦]

**ប្រធានអង្គជំនុំ៖**

លោក អ៊ូ សាវរិត ចូលលោកធ្វើសេចក្តីថ្លែងរៀបរាប់ជូនដល់អង្គសវនាការអំពីរឿងហេតុ អំពីទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលបានធ្វើឲ្យប៉ះពាល់ចំពោះរូបលោក ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យក៏ដូចជា ក្នុងអំឡុងពេលនៃការបង្កើត និងប្រតិបត្តិការនៃមន្ទីរសន្តិសុខស-២១ ទីក្រុងភ្នំពេញចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ៧៩ ដែលនាំឲ្យលោកសម្រេចចិត្ត តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណង និងរៀបរាប់អំពីស្ថានភាពព្យសនកម្មដែលមានចំពោះលោកដូចជា ការខូចខាត ផ្នែកខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និងជាផលវិបាកដោយផ្ទាល់ចំពោះខ្លួនលោក ហើយនិងកើតមានពិតប្រាកដរហូតដល់ពេលបច្ចុប្បន្ន ។ សូមអញ្ជើញ ។

**លោក អ៊ូ សាវរិត៖**

លោកប្រធានជាទីគោរព! អង្គជំនុំជម្រះនៅក្នុងសវនាការនេះទាំងមូល។ ខ្ញុំសូមនិយាយជាភាសាបារាំង ដោយសារតែខ្ញុំនៅឆ្ងាយពីប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៧៣ នៅពេលដែលខ្ញុំចាកចេញទៅអាយុ

១៨ឆ្នាំ ហើយខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនអាចនិយាយសម្តែងខ្លួនខ្ញុំឲ្យអស់ទេជាភាសាខ្មែរ ហើយដាក់ពាក្យឲ្យត្រឹមត្រូវនោះ ។ តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំរៀបរាប់ជាភាសាបារាំងដែរឬទេ?

[១៤:០២:២៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ។

**លោក អ៊ូ សាវរិត៖**

សូមអរគុណលោកប្រធាន ។ យើងអាចគិតថា ដោយសារតែវាជាជីវៈការងាររបស់ខ្ញុំ ដែលនាំឲ្យខ្ញុំអាចនិយាយជាសាធារណៈ ដូច្នេះហើយខ្ញុំមិនមានបញ្ហាសម្តែងនៅចំពោះមុខលោក លោកស្រីនោះទេ ។ ប៉ុន្តែខ្ញុំមានការសង្ឃឹមជាមុនយ៉ាងច្រើន ទាក់ទងទៅនឹងសវនាការយើងនេះ ហើយខ្ញុំមានអារម្មណ៍រំជើបរំជួលណាស់នៅក្នុងថ្ងៃនេះ ។

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! តើនរណាគេទៅជាប្អូនរបស់ខ្ញុំនោះ? ថាតើគាត់តំណាងឲ្យខ្ញុំយ៉ាងម៉េច? ថាតើយើងមានទំនាក់ទំនងយ៉ាងម៉េចជាមួយគ្នា? ហេតុអ្វីបានជាខ្ញុំនឹកគាត់? តើនរណាគេជាប្អូនរបស់ខ្ញុំ? ខ្ញុំសូមបញ្ជាក់នៅក្នុងនេះ ។

ប្អូនរបស់ខ្ញុំ គឺជានិស្សិតបញ្ចប់ការសិក្សា ENA គឺមហាវិទ្យាល័យ នៅសាកលវិទ្យាល័យភ្នំពេញ ហើយគាត់បំពេញកម្មសិក្សាទៅលើការងារនៅថ្ងៃទី៣១ ឆ្នាំ១៩៧៥ ។ គាត់ជាមន្ត្រីនៅក្នុងក្រសួងការបរទេស ហើយគាត់ធ្វើការនៅខុទ្ទកាល័យលោក អ៊ុក បូរិត ។ ប្អូនខ្ញុំរៀបអាពាហ៍ពិពាហ៍មានកូនបីរូប ។ ការបាត់ខ្លួនប្អូនរបស់ខ្ញុំ គឺមានការឈឺចាប់ណាស់នៅពេលដែលខ្ញុំជួបសម្តេចនរោត្តមស៊ីហនុ ។ នៅពេលដែលខ្ញុំជួបទ្រង់នៅប៉ារីស ដែលខ្ញុំបានតែងតែពិភាក្សារឿងប្អូនរបស់ខ្ញុំ ។ ដោយសារតែទ្រង់រៀននៅសាលារួមគ្នា ដែលទ្រង់ជួបគ្នាជាញឹកញាប់ដែរជាមួយប្អូនរបស់ខ្ញុំ ។

[១៤:០៥:១០]

ដូច្នេះ តើប្អូនខ្ញុំនោះតំណាងនៅក្នុងចិត្តខ្ញុំយ៉ាងម៉េច? លោកប្រធានជាទីគោរព! ប្អូនរបស់ខ្ញុំ គឺជាប្អូនមួយរូបដែលបងទាំងឡាយចង់បាន គាត់ឆ្លាត មានភាពវៃឆ្លាត ហើយគាត់មានការស្រឡាញ់ ហើយនិងគាត់ស្រឡាញ់រាប់អានមិត្តរបស់គាត់ ហើយគាត់ជាគំរូសម្រាប់ខ្ញុំ ។ ខ្ញុំចង់ធ្វើដូចខ្ញុំអ៊ីចឹង ហើយខ្ញុំមានមោទនភាពណាស់ដែលបានកើតបានកើតជាបងរបស់ប្អូនខ្ញុំនោះ ។ តើយើងមានទំនាក់ទំនងជាក់ស្តែងនិងពិសេសយ៉ាងម៉េច?

ដូចដែលខ្ញុំបានជម្រាបអង្គសវនាការមុននឹងបន្តិច អម្បាញ់មិញនេះ យើងជាកូនប្រាំរូបនៅក្នុងគ្រួសារ ហើយគាត់គឺជាបងគេបំផុត ហើយខ្ញុំគឺជាប្អូន ។ បានន័យថា យើងខ្ញុំមានអាយុឆ្ងាយពីគ្នាដប់មួយឆ្នាំ ហើយអាយុនេះ គឺវាបងប្អូនគ្នាច្រើនណាស់ ប៉ុន្តែគាត់មានភាពជិតស្និទ្ធជាមួយខ្ញុំ ។ យើងមានសម្ព័ន្ធនឹងញាតិទំនាក់ទំនងគ្នា ហើយធ្វើឲ្យយើងយល់គ្នាទៅវិញទៅមក ។ ខ្ញុំមានភាពរីករាយណាស់ដែលរស់នៅជាមួយបងរបស់ខ្ញុំ ។ ហេតុអ្វីបានជាខ្ញុំនឹកបងរបស់ខ្ញុំ?

នៅក្នុងឆ្នាំ១៩៧៣ នៅអាយុ១៨ ខ្ញុំត្រូវទៅប្រទេសបារាំង ដើម្បីបន្តការសិក្សារបស់ខ្ញុំ ហើយនៅក្នុងវ័យនោះ គឺជាវ័យដែលមានទំនាក់ទំនងនឹងញាតិលោកហិត ដែលយើងចង់កើតមានឡើង ហើយទំនាក់ទំនងនៅពេលនោះមានភាពជិតស្និទ្ធណាស់ ។ ហើយនៅក្នុងជីវិតរបស់ខ្ញុំរហូតមក ខ្ញុំតែងតែនឹកគាត់ជានិច្ច ។ ហើយនៅថ្ងៃនេះផងដែរ ខ្ញុំនៅតែនឹកឃើញ ហើយនិងនឹកគាត់គ្រប់ពេលវេលា គ្រប់វិនាទីទាំងអស់ ។

ហើយមកដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំរស់នៅក្នុងភាពតក់ស្លុតអំពីជោគវាសនាដែលអាចកើតមានចំពោះបងខ្ញុំ ។ នៅចុងឆ្នាំ១៩៧៩ ខ្ញុំបានឃើញឈ្មោះរបស់គាត់ ដែលមានសរសេរនៅក្នុងបញ្ជីអ្នកទោស ដែលត្រូវបានគេចាប់ខ្លួនចូលស-២១ ។

តាំងពីពេលនោះមក មកទល់បច្ចុប្បន្ន គឺខ្ញុំមានការចាប់អារម្មណ៍ និងចងចាំទៅលើថ្ងៃខែនោះ គឺថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយវានៅចងចាំក្នុងអារម្មណ៍របស់ខ្ញុំជានិច្ច ។ ហើយខ្ញុំមានការចោទសួរទៅលើសំណួរទាំងឡាយដែលពាក់ព័ន្ធទៅនឹងគាត់ គឺថ្ងៃនោះហើយដែលជាថ្ងៃដែលគាត់ត្រូវបានគេចុះឈ្មោះចូលទៅក្នុងមន្ទីរស-២១ គឺខែមករា ឆ្នាំ១៩៧៦ ដែលគាត់ត្រូវបានគេកម្ទេចចោល ។

[១៤:០៨:៤៣]

ដូច្នេះតាំងពីពេលនោះមករយៈពេលសាមសិបឆ្នាំហើយ ខ្ញុំបានគិតនិងនឹកឃើញរូបគាត់ជារៀងរាល់ថ្ងៃ។ សាមសិបឆ្នាំ មួយពាន់ម្ភៃថ្ងៃយប់ហើយ ដែលខ្ញុំគិតថា តើមានអ្វីកើតឡើងនៅក្នុងរបងជញ្ជាំងមន្ទីរស-២១ ចំពោះរូបគាត់ ។

ការឈឺចាប់ទុក្ខសោករបស់ខ្ញុំនៅក្នុងថ្ងៃនេះ គឺពិតជាពាក់ព័ន្ធ ហើយកើតឡើងចេញអំពីការសម្លាប់ប្រពន្ធរបស់ខ្ញុំផងដែរនិងកូនស្រីរបស់គាត់ ។ បងប្អូនស្រីខ្ញុំពីររូបរស់នៅក្នុងប្រទេសបារាំង ហើយខ្ញុំមិនអាចជម្រាបអង្គសវនាការអំពីអារម្មណ៍របស់បងខ្ញុំទាំងពីរនោះទេ ។

លោកប្រធាន លោក លោកស្រីចៅក្រម ជាទីគោរព! ខ្ញុំចង់អាននូវប្រយោគពីរប្រយោគ បី

ប្រយោគ ដែលសរសេរឡើងដោយក្មួយស្រីរបស់ខ្ញុំ ហើយក្មួយស្រីរបស់ខ្ញុំមានបំណងក្នុងការជម្រាបអង្គសវនាការ ។ ខ្ញុំសូមដកស្រង់សម្តីនោះ៖

“ឈ្មោះរបស់ខ្ញុំ អ៊ុក កាមេឡា។ ឪពុករបស់ខ្ញុំ អ៊ូ វ៉ាន់ឌី គឺជាជនរងគ្រោះមួយរូបនៅក្នុងចំណោមជនរងគ្រោះនៅមន្ទីរស-២១ ។ ខ្ញុំមានអាយុបួនឆ្នាំ នៅពេលដែលឪពុករបស់ខ្ញុំត្រូវបានគេចាប់ខ្លួន ធ្វើទារុណកម្ម ហើយក្រោយមកសម្លាប់ចោល ។ នៅវ័យបួនឆ្នាំនោះ គឺខ្ញុំនៅក្មេងណាស់ដែលដឹងអំពីភាពសាហាវយង់ឃ្នង ដែលឪពុករបស់ខ្ញុំប្រហែលជាត្រូវបានរងគ្រោះ ។ នៅពេលដែលខ្ញុំមានអាយុបួនឆ្នាំ ខ្ញុំពិតជាក្មេងមែនទែនក្នុងការយល់ដឹងថា គាត់បានចាកចេញឆ្ងាយពីរូបខ្ញុំ ។ នៅពេលដែលខ្ញុំមានអាយុបួនឆ្នាំ ក៏នៅកុមារភាព ហើយមានភាពវ័យក្មេងក្នុងការយល់ និងដឹងអំពីវិសាលភាពនៃការពុំមានឪពុកក្នុងជីវិតអនាគតរបស់ខ្ញុំ ។ អវត្តមានរបស់គាត់ធ្វើឲ្យមានសញ្ញាសួរនៅក្នុងខួរក្បាលខ្ញុំជានិច្ច ហើយធ្វើឲ្យខ្ញុំបាត់បង់ចំណុចនេះនៅក្នុងយុវភាពរបស់ខ្ញុំ ។ ហើយខ្ញុំគ្មានឪពុកនៅឈរក្បែរខ្ញុំ នៅក្នុងហេតុការណ៍ធំដែលកើតមានចំពោះខ្ញុំ គឺវាបានធ្វើឲ្យខ្ញុំចុកចាប់ ។

ខ្ញុំចង់ឲ្យរូបគាត់មកនៅកៀកខ្ញុំ ការពារខ្ញុំ នៅពេលដែលខ្ញុំត្រូវការការពាររបស់គាត់ ។ ខ្ញុំចង់ផ្តល់អ្វីៗគ្រប់បែបយ៉ាងដើម្បីឲ្យគាត់យល់ ហើយនិងចង់ឃើញវាសនារបស់គាត់ ។ នៅពេលដែលខ្ញុំបញ្ចប់ថ្នាក់វិទ្យាល័យរបស់ខ្ញុំ ហើយនៅពេលដែលខ្ញុំទទួលជោគជ័យនៅក្នុងការសិក្សា និងទទួលបានការងារលើកដំបូង ខ្ញុំពិតជាចង់ជម្រាបទៅដល់រូបលោកឪពុក អំពីបរិញ្ញាបត្រ ឬក៏វិសាលភាពដែលកូនស្រីរបស់គាត់ និងកូនប្រុសរបស់គាត់នៅជាមួយ ។

ខ្ញុំពិតជាចង់ថ្លែងអំណរគុណទៅឪពុករបស់ខ្ញុំ ដែលគាត់បានបង្កើតខ្ញុំជាស្ត្រីមួយរូបមកទាល់សព្វថ្ងៃ ។ យោងតាមសម្តីរបស់ពូមីងរបស់ខ្ញុំ ឪពុករបស់ខ្ញុំ គឺជាបុគ្គលមួយរូបដ៏ប្រពៃ ហើយខ្ញុំមិនយល់ឃើញថានរណាម្នាក់ គាត់មានភាពយ៉ាងសាហាវយង់ឃ្នងបានឆក់យកជីវិតរបស់បុគ្គលដ៏ល្អរូបនោះទេ។

[១៤:១៣:៣៣]

និយាយឲ្យងាយទៅ ថាតើបុគ្គលណាដែលគាត់បានឆក់យកជីវិតរបស់ឪពុករបស់ខ្ញុំ ដោយមិនមានការសោកស្តាយ និងវិប្បដិសារីចំពោះការប្រព្រឹត្តិបែបនោះ ។ ខ្ញុំជាកូនស្រីរបស់ជនរងគ្រោះមួយរូប ខ្ញុំសូមស្នើឲ្យការដាក់ទោសហ្នឹងសមល្មមទៅនឹងឧក្រិដ្ឋកម្មដែលបានកើតឡើងចំពោះការឈឺចាប់ ទុក្ខសោកទាំងឡាយ ហើយឲ្យវាត្រូវ និងស៊ីគ្នាទៅនឹងជីវិតរបស់ជនរងគ្រោះ ដែលត្រូវបានជនជាប់ចោទដកយកទៅ ។

ក្នុងនាមឪពុករបស់ខ្ញុំ ខ្ញុំសូមបដិសេធមិនអនុគ្រោះដល់បុគ្គលណាឡើយ ដោយសារតែការផ្តល់ការអនុគ្រោះចំពោះរូបបុគ្គលណាម្នាក់នោះ គឺវាទាក់ទងទៅនឹងថាមិនមានឧក្រិដ្ឋកម្មណាកើតឡើងចំពោះបុគ្គលជនរងគ្រោះឡើយ។ ដើម្បីឲ្យការអត់ឱនទោសនោះ គឺទាល់តែមានការសារភាពចំពោះការប្រព្រឹត្តិអំពើសាហាវយង់ឃ្នង ហើយវាមិនប៉ះពាល់ដល់យើងរូបខ្ញុំ និងយើងខ្ញុំទាំងអស់យ៉ាងធំធេងដូច្នេះ ។

ការផ្តល់ការអត់ឱនទោស បានន័យថាវាជាការអាណិតអាសូរ ប៉ុន្តែតើបុគ្គលណាអាចអាណិតទៅបុគ្គលមួយរូបដែលបានឆក់យក និប្លន់យកជីវិតអ្នកទាំងអស់គ្នាយ៉ាងច្រើន? ថាតើបុគ្គលនោះ គាត់បានអាណិតអាសូរចំពោះស្ត្រីមួយរូប កូនៗទាំងឡាយ និងបុរស ដែលគាត់បានបណ្តាលឲ្យមានការស្លាប់ទៅបុរសរូបនោះ? ក្នុងឪពុករបស់ខ្ញុំ ខ្ញុំសូមបដិសេធមិនធ្វើការសម្តែងចេញនូវការអាណិតអាសូរទាំងឡាយ សូម្បីបន្តិចទាល់តែសោះ ។ ខ្ញុំសូមឲ្យយុត្តិធម៌ធ្វើការរកឲ្យបានត្រឹមត្រូវ ។”

នេះ គឺជាការបញ្ចប់លិខិតរបស់មួយក្មួយស្រីរបស់ខ្ញុំ លោកប្រធាន ។

នៅពេលនេះ ខ្ញុំសូមថ្លែងក្នុងនាមប្អូនបងថ្លៃរបស់ខ្ញុំ ក្មួយៗស្រីរបស់ខ្ញុំ ហើយនិងបងប្អូនទាំងឡាយដែលគាត់នៅរស់រានមានជីវិត ។ ខ្ញុំមិនទាមទារសំណងថវិកា និងសំណងសម្ភារៈណាមួយនោះទេ ខ្ញុំគ្រាន់តែចង់តែដឹងថា តើវាពិតជាមានអ្វីកើតឡើងក្នុងអំឡុងពេលចំនួនកៅសិប្រាំពីរថ្ងៃ? ហើយតើវាមានអ្វីកើតឡើងចំពោះចម្លើយសារភាពហាសិបទំព័រនោះ?

[១៤:១៦:៤៨]

នេះហើយជាមូលហេតុ ដែលខ្ញុំបានសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃនេះ ។ ជាការពិតណាស់ការមកនៅចំពោះមុខតុលាការនេះ គឺខ្ញុំទាមទារនូវសំណងខាងផ្លូវសីលធម៌ ។ បុគ្គលតែមួយរូបដែលភរិយារបស់ខ្ញុំ គាត់បានដឹងអំពីទុក្ខសោករបស់ខ្ញុំនៅក្នុងជាងមួយម៉ឺនថ្ងៃនេះ ដែលខ្ញុំភ្ញាក់ឡើងនៅយប់ហើយស្រែកទ្រហោ ។ ហើយខ្ញុំមិនអាចបង្ហាញការឈឺចាប់របស់ខ្ញុំ ក្រៅពីអ្វីដែលខ្ញុំបានធ្វើដូច្នោះ។

លោក លោកស្រីចៅក្រម លោកប្រធានជាទីគោរព! ដូចជាប្រជាជនកម្ពុជាដែលមានភាពស្លូតបូត បុគ្គលទាំងឡាយ គាត់មានអារម្មណ៍កប់ក្នុងចិត្ត ។ កិច្ចប្រឹងប្រែងដែលខ្ញុំមកចំពោះអង្គសវនាការនៅថ្ងៃនេះ គឺពិតជាឱកាសដ៏ល្អបំផុត ប៉ុន្តែ ខ្ញុំពិតជាប្រឹងប្រែងអង្គុយនៅទីនេះ ។ ហើយចំពោះខ្ញុំ តាមរយៈការថ្លែងនូវសេចក្តីរបស់ខ្ញុំនេះហើយ ដែលវាជាទម្រង់នៃការទាមទារសំណងដែលវាគ្រោងនឹងកើត។

ខ្ញុំកត់សម្គាល់ថា នៅថ្ងៃនេះ ជនជាប់ចោទ ហើយនិងសហគមន៍អន្តរជាតិទាំងអស់ដឹងអំពីភាពគួរឲ្យភ័យខ្លាច ដែលខ្ញុំបានឆ្លងកាត់ ។ វាដូចទៅនឹងគ្រួសាររាប់ពាន់នាក់ទៀត ដែលជាប់ឃុំនៅស-២១។

ខ្ញុំបានទៅលេងស-២១ លើកទីមួយនៅក្នុងឆ្នាំ១៩៩២ ។ ភាពតក់ស្លុត និងភ័យខ្លាច វាកើតមានឡើងចំពោះខ្ញុំ ។ នៅពេលមួយនោះនៅក្នុងបន្ទប់ខ្ញុំបានមើលទៅលើ ខ្ញុំមើលចេញទៅក្រៅ មើលផ្ទៃមេឃពណ៌ខៀវ ហើយមានត្រចៀកកាំកំពុងតែហោះហើរច្រៀងលើវេហា ហើយយើងកំពុងនៅលើកោះដ៏សាហាវមួយដែលនៅដាច់ពីគេ ។ ថាតើការសាហាវយង់ឃ្នង និងការសម្លាប់រង្គាលអាចកើតឡើងយ៉ាងម៉េចទៅលើកោះនេះ?

គឺវានៅឆ្ងាយ កោះដែលនៅឆ្ងាយដាច់ពីគេ ដែលវាបង្កការរងគ្រោះទៅដល់ជនរងគ្រោះ មិនអាចសុំហៅឲ្យគេជួយបាន ហើយគឺការសម្លាប់ដោយជនដែលគ្មានអាណិតអាសូរ ។ នៅថ្ងៃនោះហើយ ដែលខ្ញុំបានស្រែកទ្រហោយំនៅភាពអយុត្តិធម៌ ។ ហេតុអ្វីបានជាសហគមន៍អន្តរជាតិបានបំភ្លេចយើងទាំងស្រុង ទុកឲ្យយើងនៅសោកសៅ? ហេតុអ្វីបានជាសហគមន៍អន្តរជាតិទាំងអស់ មិនបានជឿពីដំបូងថាវាមានការផ្តល់ចម្លើយសារភាពរួចទៅហើយ? ហេតុអ្វីបានជាសហគមន៍អន្តរជាតិមិនអនុវត្តសិទ្ធិចូលអន្តរាគមន៍? ក្នុងមានដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្ញុំនៅចំពោះមុខនៅពេលនេះ លោកប្រធាន ខ្ញុំចង់ដឹងថា តើវាពិតជាមានអ្វីកើតឡើងនៅក្នុងជញ្ជាំងមន្ទីរស-២១ ។

ការជំនុំជម្រះនេះ បានបំភ្លឺជាចង្កៀងមួយសម្រាប់ខ្ញុំ ហើយនៅពេលនេះ គឺយើងបានពិតជាដឹងអំពីភាពពិស្តារនូវអ្វីដែលបានកើតឡើង ហើយខ្ញុំមានការគិតទៅលើជាលក្ខណៈជាអរូបិយទៅលើបន្ទប់ឃុំឃាំង ឧបករណ៍ខ្នោះឃ្នាង ដំបង ខ្ញុំបានឃើញរូបថតពូថៅ ដំបងផ្សេងៗ ហើយនៅពេលនេះនៅពេលដែលខ្ញុំកំពុងតែតាមដាន និងនៅក្នុងបន្ទប់សវនាការនេះខ្ញុំពិតជាចង់ដាក់ខ្លួនខ្ញុំឆ្លងកាត់នូវបទពិសោធន៍ដែលបងរបស់ខ្ញុំបានជួបប្រទះនោះ ដើម្បីឲ្យដឹងអំពីការឈឺចាប់ទុក្ខសោកទាំងឡាយដែលគាត់បានរងគ្រោះ ។ ការដែលគាត់ចប់អារម្មណ៍ ខ្ញុំចង់គិតនិងប្រមើមើលអំពីការឈឺចាប់របស់បុគ្គលម្នាក់ដែលគាត់ទទួលរងគ្រោះនៅពេលដែលគាត់ត្រូវបានគេវាយដំនៅពេលក្រចកទាំងឡាយត្រូវបានដកចេញ ហើយនៅពេលដែលបុគ្គលម្នាក់ គាត់ត្រូវបានគេឆក់នឹងខ្សែភ្លើងហើយនៅពេលដែលយើងជាប់ខ្នោះឃ្នាង ។

នៅគ្រប់វិនាទីនៅក្នុងជីវិតរបស់យើងនៅក្នុងប្រទេសកម្ពុជាខ្ញុំតែងតែគិតអំពីបងរបស់ខ្ញុំ ។ ប៉ុន្តែជាអកុសល ខ្ញុំមិនអាចជួយគាត់ពីសម្រែកហៅរបស់គាត់នោះទេ ។ នៅពេលដែលខ្ញុំត្រូវបានមូសខាំនៅក្នុងប្រទេសកម្ពុជា ខ្ញុំគិតស្រមើស្រម៉ៃអំពីបងរបស់ខ្ញុំ អំពីជនជាប់ឃុំដែលត្រូវបានមូសខាំ ហើយមិនអាចធ្វើការតតាំង និងប្រតិកម្មអ្វីទាំងអស់ ។ គិតអំពីរឿងរ៉ាវទាំងឡាយដែលពួកគាត់ធ្លាប់បានរងគ្រោះនោះ ខ្ញុំហើយក៏គិតអំពីចង្វាក់រណ្តំនៃការធ្វើទារុណកម្ម ការគ្មានអនាម័យ និងការវាយតប់ ហើយនិងការ

បន្ទោសបន្ទោកខាងផ្នែកស្មារតី និងផ្លូវកាយ គឺបានកើតឡើងចំពោះគាត់ ។ ការងារទាំងឡាយ ដែលមានលក្ខណៈថោកទាបប្រព្រឹត្តចំពោះគាត់ ។

លោកប្រធានជាទីគោរព! ខ្ញុំបានគិតថា ខ្ញុំគ្មានអ្វីសល់ទៀតទេចំពោះខ្ញុំ ។ ខ្ញុំបានគិត ខ្ញុំមិនអាចស្រក់ទឹកភ្នែកនៅពេលនេះ ប៉ុន្តែខ្ញុំនៅតែមានទឹកភ្នែកនោះទុកក្នុងចិត្តនៅឡើយ ។ ខ្ញុំបន្តគិតនឹកឃើញដល់បងរបស់ខ្ញុំជានិច្ច ។ ការឈឺចាប់របស់គាត់ក្នុងរយៈពេលកៅសិបប្រាំពីរថ្ងៃ ហើយនៅពេលនោះប្រហែលជាគាត់បានគិតអំពី តើមានអ្វីកើតឡើងចំពោះប្រពន្ធ និងកូនរបស់គាត់ ថាតើពួកគេពិតជាបានហូបចុកគ្រប់គ្រាន់បរិបូរណ៍ដែរឬទេ? ថាតើប្រពន្ធ កូនចៅរបស់គាត់ទទួលរងគ្រោះដែរឬទេ? ដោយសារតែនៅពេលដែលបងរបស់ខ្ញុំត្រូវបានគេចាប់ខ្លួននោះ គាត់បានសួរប្អូនស្រីរបស់គាត់ឲ្យធ្វើការថែរក្សាកូនរបស់គាត់នោះហើយជាពាក្យចុងក្រោយដែលគាត់បាននិយាយ ដោយសារតែពេលនោះ ប្រហែលជាគាត់ដឹងហើយថា គាត់នឹងគ្មានថ្ងៃវិលវិញឡើយ ។

[១៤:២៥:០៥]

មុនពេលដែលសួរសំណួរមួយចំនួន ខ្ញុំមានសំណួរពីរដែលខ្ញុំចង់សួរ មុនពេលខ្ញុំសួរ ខ្ញុំមិនអាចប៉ុន្តែនៅពេលនេះ ខ្ញុំសូមរៀបរាប់អំពីខ្សែជីវិតដោយសង្ខេបដែលបានកើតឡើងនៅពេលដែលខ្ញុំត្រឡប់មកប្រទេសកម្ពុជាលើកទីមួយ ឆ្នាំ១៩៩២ ។

នៅល្ងាចមួយនោះ មានស្ត្រីក្មេងមួយរូបដែលគាត់មានលទ្ធភាពអាចខាបព្រលឹង ហើយខ្ញុំបាននិយាយទៅកាន់ស្ត្រីក្មេងនោះអំពីបងរបស់ខ្ញុំ ហើយគាត់ក៏បានធ្វើការខាបព្រលឹង និងទាក់ទងជាមួយបងរបស់ខ្ញុំ ហើយក្នុងនាមប្រជាជនកម្ពុជា យើងជឿទៅលើអបិយជំនឿបែបនេះ ប៉ុន្តែ ខ្ញុំមិនអាចពន្យល់ថាតើខ្ញុំជឿយ៉ាងម៉េចនោះទេ ។ ស្ត្រីក្មេងនោះ គាត់បានប្រាប់ខ្ញុំថា គឺស្ត្រីនោះ គាត់កំពុងតែនិយាយជាមួយនិងព្រលឹងរបស់បងរបស់ខ្ញុំ បងខ្ញុំប្រាប់ថា គាត់មានការតក់ស្លុត និងមានការក្រៀមក្រំក្នុងអារម្មណ៍គាត់ទទួលឈឺចាប់យ៉ាងធ្ងន់ធ្ងរ ។ គាត់ឈឺចាប់នៅក្នុងជីវិតរបស់គាត់នៅលើពិភពលោកនេះ ហើយគាត់ពិតជាមិនចង់ចាប់កំណើតឡើងវិញនោះទេ ។ គាត់បាននិយាយថា គាត់ពិតជាមានការភ័យខ្លាច ហើយគឺគាត់ទៅសុំជ្រកកោននៅក្នុងវត្ត ហើយគឺគាត់សុំឲ្យព្រះសង្ឃជួយការពារគាត់ ។ ស្ត្រីក្មេងរូបនោះ បានប្រាប់ខ្ញុំអំពីឈ្មោះវត្តដែលគាត់ទៅសុំជ្រកកោន ។ ខ្ញុំពិតជាក្រៀមក្រំយ៉ាងខ្លាំង នៅពេលដែលខ្ញុំបានឮសម្តីនោះ នៅរសៀលល្ងាចនោះ ដែលវានៅតែប៉ះទង្គិចអារម្មណ៍របស់ខ្ញុំ ។

ថ្ងៃបន្ទាប់មក គឺខ្ញុំបានទៅវត្តនោះជាមួយនឹងបងស្រីរបស់ខ្ញុំ ។ យើងបានរៀបចំពិធីបុណ្យ ។ អ្វី

ដែលចម្លែកនៅក្នុងវត្តនោះ ខ្ញុំបន្តធ្វើការសម្លឹងមើល ហើយខ្ញុំអាចឃើញពីដើមដែលវាហាក់ដូចជាព្រលឹងរបស់បងខ្ញុំនៅទីនោះ ។ ខ្ញុំប្រាប់ខ្ញុំនៅពេលដែលខ្ញុំចូលទៅដល់វត្តនោះថា ខ្ញុំនឹងមើលពិដានវត្តដោយសារតែបងរបស់ខ្ញុំ មិនមែនតែជាបុគ្គលមួយរូបដែលគាត់ទៅសុំជ្រកនៅក្រោមវត្តនោះទេ ហើយគាត់បដិសេធមិនចាប់កំណើតតែម្នាក់ទេ គឺគាត់បែរទៅសុំឱ្យព្រះពុទ្ធការពារគាត់ ។ ហើយក្មួយរបស់ខ្ញុំគាត់នៅពេលនេះ គឺមានផ្ទះពោះ ។ នៅពេលដែលកូននោះប្រសូត្រចេញមក យើងទាំងអស់គ្នានឹងទៅលេងវត្តនោះ ហើយនឹងបង្ហាញគាត់នូវចៅរបស់គាត់ ដែលចាប់កំណើត ។

ខ្ញុំចង់សួរសំណួរទៅកាន់ជនជាប់ចោទ លោកប្រធាន ។ សំណួរទីមួយ ចំពោះបញ្ជីរបស់អ្នកទោសនៅមន្ទីរស-២១ នៅអំឡុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ឯកសារ ERN00171639 ខ្ញុំសូមនិយាយឡើងវិញ 639 នៅចុងកន្ទុយ ។

ថ្ងៃចូលស-២១ គឺបានសរសេរនៅថ្ងៃនោះ ថ្ងៃ១៣ កុម្ភៈ ឆ្នាំ១៩៧៦ ប៉ុន្តែ នៅក្នុងចម្លើយសារភាពរបស់បងខ្ញុំ គឺមានកំណត់សម្គាល់អំពីប្រវត្តិរបស់បងខ្ញុំ គឺបានលើកឡើងជាសមាជិករបស់ សេអ៊ីអា គឺចុះនៅថ្ងៃទី២៣ មករា ១៩៧៦ ឯកសារដែលមានលេខ ERN00274282 ។ ដូច្នេះ វាមានចន្លោះម្ភៃថ្ងៃចំពោះថ្ងៃដើមចូលនិងថ្ងៃក្រោយមក ។ ថាតើថ្ងៃមួយណាដែលយើងថាជាថ្ងៃពិតប្រាកដ ហើយតើជនជាប់ចោទអាចពន្យល់អំពីភាពខុសគ្នារវាងថ្ងៃទាំងពីរ ដែលចុះនៅក្នុងនោះយ៉ាងម៉េច?

សំណួរទីពីរ លោកប្រធាន ជនជាប់ចោទពីមុននោះបានឆ្លើយសំណួរបែបនេះ ហើយបានបញ្ជាក់ថាអ្នកទោសទាំងឡាយត្រូវបានទទួលរងទារុណកម្មមុនពេលផ្តល់សេចក្តីសារភាព ។ ប៉ុន្តែ ពេលដែលខ្ញុំអានចម្លើយសារភាពបងរបស់ខ្ញុំ ការសរសេរផ្ទាល់ដៃរបស់គាត់នោះ គឺមានន័យច្បាស់លាស់ណាស់ ហើយគឺច្បាស់ៗ ហើយដែលខ្ញុំនឹងមិនជឿជាក់ថា គាត់អាចនឹងមានលទ្ធភាពសរសេរបែបនេះបានទេ ដោយមិនមានអំពើទារុណកម្មនោះ ។ តើជនជាប់ចោទមានសេចក្តីពន្យល់អ្វីដែរឬទេ ទាក់ទងទៅនឹងសេចក្តីសង្កេតរបស់ខ្ញុំនេះ? សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះទទួលយកនូវសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយសូមផ្ទេរនូវសំណួរនេះទៅជនជាប់ចោទ ដើម្បីអាចឆ្លើយតបទៅនឹងសំណួរដែលដើមបណ្តឹងរដ្ឋប្បវេណីបានសួរ ហើយដោយឆ្លើយសំណួរទីមួយមុន ហើយបន្ទាប់មកឆ្លើយសំណួរទីពីរ ។ ហើយក្នុងករណីជនជាប់ចោទស្តាប់មានការមិនច្បាស់លាស់នៅសំណួរណាមួយ គឺអាចសុំសួរបញ្ជាក់ឡើងវិញ ដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់

នូវសំណួររបស់ខ្លួន ប៉ុន្តែប្រហែលជាមិនពិបាកទេ ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! បើខ្ញុំសួរទៅប៉ារីសវែងណាស់ ខ្ញុំចង់សួរលោក គឹមសួន នៅនេះពីរឿងគាត់និយាយហ្នឹង គាត់ថា គាត់ចូលទៅដល់ស-២១ ខែកុម្ភៈ ស្រាប់តែដល់គាត់និយាយថាសេចក្តីសារភាពនៅខែមករា ទៅវិញ ។ ដូច្នេះ ខ្ញុំអត់ទាន់បានឃើញ ។

**ប្រធានអង្គជំនុំ៖**

មិនឮសំឡេង ដោយសារមិនបានបើកមីក្រូហ្វូន ។

អម្បាញ់មិញនេះ អត់មានការបកប្រែទៅជាភាសាបរទេស ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន!

*(មិនឮសំឡេង)*

**លោក អ៊ូ សាវរិត៖**

*(និយាយជាភាសាបារាំង) ម៉ុងស្យ៊ី លើ ប្រេស៊ីដង់ ទួណឺអាតង់ដុង ប៉ា អាបារីស ។*

[១៤:៤៤:២៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតទៀត ហើយជនជាប់ចោទចង់សួរបញ្ជាក់ទៅខាងដើមបណ្តឹងរដ្ឋប្បវេណីឲ្យបានច្បាស់អំពីកាលបរិច្ឆេទនៃការចូលដល់ស-២១ របស់ អ៊ូ វិនឌី ជាជនរងគ្រោះ ហើយនិងថ្ងៃដែលសួរចម្លើយជនរងគ្រោះ ដែលបានធ្វើនៅមន្ទីរស-២១ អ៊ីចឹងមែនទេ?

អញ្ជើញមេធាវីការពារតើមានបញ្ហាអីទៅ?

**លោកស្រី មារីប៉ូល កានីហ្សាវេស៖**

លោកប្រធាន ដើមបណ្តឹងរដ្ឋប្បវេណីនិយាយអំពីចម្លើយសារភាព ដែលកាលបរិច្ឆេទនៅថ្ងៃទី-- ឆ្នាំ៧៦នោះបានកត់ត្រាលើនោះ ហើយថាមិនអាចទៅរួចទេ គឺថាឯកសារនោះ បើអាចធ្វើបានយើងអាចបញ្ចាំងលើទំព័រនោះដែលបញ្ជាក់អំពី-- ដែលបញ្ជាក់ថា ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ នោះមាននៅលើទំព័រនោះ។

**លោក អ៊ូ សាវរិត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតជម្រាបជូនឯកសារនេះ ។

**ប្រធានអង្គជំនុំ៖**

ឯកសារដែលចាប់ខ្លួនឈ្មោះ អ៊ូ វិនឌី ចូលមកកាន់មន្ទីរស-២១ តើនៅថ្ងៃខែឆ្នាំណា? ហើយមានលេខ ERN ឬក៏លេខសំណុំរឿងប៉ុន្មានច្បាស់លាស់? ទីពីរគឺ សុំបញ្ជាក់បន្ថែមទៀតអំពីថ្ងៃ ឬក៏កាលបរិច្ឆេទនៃការសួរចម្លើយ ឬក៏ចម្លើយសារភាពដែលធ្វើចំពោះឈ្មោះ អ៊ូ វិនឌី នៅមន្ទីរស-២១ ដើម្បីឲ្យបានច្បាស់ ។

**លោក អ៊ូ សាវរិត៖**

បាទ,លោកប្រធានទាក់ទងទៅនឹងបញ្ជីអ្នកទោសនៅស-២១ ១៩៧៥ ហ្នឹងរហូតមកដល់ ១៩៧៩ ចំពោះខែកុម្ភៈ ឆ្នាំ១៩៧៦ លេខឯកសារ ERN 00171639 ។ ឥឡូវនេះ ពាក់ព័ន្ធទៅនឹងប្រវត្តិរូបកំណត់ត្រាជីវប្រវត្តិដែលចុះកាលបរិច្ឆេទខែមករា ឆ្នាំ១៩៧៧ ឯកសារ ERN 00274282 ។

**ប្រធានអង្គជំនុំ៖**

សូមបង្ហាញនូវឯកសារចំនួនពីរ។ ឯកសារដែលមានលេខ ERN ជាភាសាខ្មែរ 00171639 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

អ៊ូ វិនឌី លេខរៀង៧៥៩ ក្រសួងការបរទេសល្វាឯម ។

មន្ត្រីតុលាការដកឯកសារនេះចេញ ហើយដាក់ឯកសារមួយទៀត ។ ឯកសារចម្លើយសារភាពលេខ ERN 00274282 ។

មើលថ្ងៃខាងក្រោមថ្ងៃបរិច្ឆេទនៃការសួរចម្លើយ ។

**លោក អ៊ូ សាវរិត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបន្ត ។

**ប្រធានអង្គជំនុំ៖**

រង់ចាំបន្តិចដើម្បីឲ្យជនជាប់ចោទពិនិត្យនូវឯកសារនេះ អំពីកាលប្បវត្តិកាលបរិច្ឆេទនៃថ្ងៃចម្លើយសារភាពរបស់ជនរងគ្រោះ ដើម្បីឆ្លើយតបទៅនឹងសំណួរដែលលោកបានសួរ ។

បង្ហិលរហូតដល់កាលប្បវត្តិនៃការចុះកាលបរិច្ឆេទថ្ងៃសួរចម្លើយ ។

**លោក អ៊ូ សាវរិត៖**

សូមគោរពលោកប្រធាន! កំណត់ហេតុមួយ គឺកាលចម្លើយសារភាពចុះថ្ងៃទីមករា ២៣ ១៩៧៦ នោះគឺកាលបរិច្ឆេទនៃចុងបញ្ចប់នៃទំព័រ ខ្ញុំឃើញអូសទំព័រទៅផុតទៅហើយ។ ប៉ុន្តែ តួលេខនោះខ្ញុំពិនិត្យឃើញថា ដូច្នេះខ្ញុំសូមអនុញ្ញាតថា យើងបង្ហាញឯកសារដែលបកជាភាសាបារាំង នៅក្នុងឧបសម្ព័ន្ធមួយ លេខ ERN 00274241 ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការបង្ហាញឯកសារជាភាសាបារាំង ដែលមានលេខ ERN 00274241 ។

តទៅទំព័រចុងក្រោយ ដើម្បីបានឃើញនៃកាលបរិច្ឆេទនៃកំណត់ហេតុ ។

ជនជាប់ចោទមុននឹងឆ្លើយ តើលោកមានការផ្តល់អ្វីទៀតចង់ដឹងអំពីបញ្ហាអ្វីទៀតទេ ដើម្បីឆ្លើយនឹងសំណួរនេះ? ឬក៏លោកទាមទារថា ឲ្យបង្ហាញនូវឯកសារដែលជាចម្លើយសារភាពជាភាសាខ្មែរ? ព្រោះអំមិញបានឃើញហើយ លោកបានឃើញហើយ គឺថ្ងៃទី២៣ ខែមករា ឆ្នាំ៧៦ នេះជាភាសាបារាំង ដែលមានការបកប្រែចេញពីភាសាខ្មែរ ។

[១៥:00:១0]

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! មុនដំបូងខ្ញុំគិតថាខ្ញុំស្តាប់មិនទាន់ ខ្ញុំកត់នេះត្រឹមត្រូវហើយ ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ថា ថ្ងៃចូលមកដល់ គឺចូលមកដល់ក្នុងខែកុម្ភៈ ឯស្រាប់តែចម្លើយសារភាពនៅមករា ទៅវិញ ដូច្នេះ វាបញ្ច្រាស់ ។ រឿងនេះហើយដែលខ្ញុំតែងតែបញ្ជាក់ថា បញ្ជីស-២១ ថ្ងៃចូលអត់ច្បាស់ទេ ។ បានជាខ្ញុំនិយាយដូច្នេះ ព្រោះអង្គាល់ដែលយកខ្ញុំទៅបង្ហាញនៅទួលស្លែងនោះ លោកចៅក្រមស៊ើបអង្កេត ម៉ាសែល ឡឺម៉ុងដ៍ លោកសួរមិត្ត ធី ។ គាត់ថា "អ្នេះអាហ្នឹង អ្នកសំខាន់ខ្លះ គេទុកគុកពិសេសនោះ គេអត់ប្រាប់មកខ្ញុំទេ ទាំងឈ្មោះ ទាំងថ្ងៃចូល" ។ ដូច្នេះ ថ្ងៃក្រោយបានៗខ្ញុំដឹង ។ យ៉ាងនេះ បានជាខ្ញុំសរសេរនៅក្នុងសេចក្តីសន្និដ្ឋានមួយជូនអ្នកស្រី ភីង ហ្គុតស៊ុនថារី ថាបញ្ជីស-២១ ថ្ងៃខែអត់ច្បាស់ទេ ។ នេះបញ្ជាក់ម្តងទៀតថា ថ្ងៃខែចូលអត់ច្បាស់ទេ ។

ដោយឡែក ករណីលោក អ៊ូ វិនឌី សូមបញ្ជាក់ថា ថ្ងៃខែដែលគាត់សារភាពច្បាស់ជាង គ្រាន់តែជាខ្មែរយើងបោះពុម្ពមិនដិត ។ ឯចំណែកជាបារាំង គឺយើងបោះពុម្ពដិត"ថ្ងៃ២៣ ខែមករា ១៩៧៦" នេះសំណួរទីមួយដែលលោក សាវរិត លោកសួរខ្ញុំ ខ្ញុំសូមឆ្លើយបញ្ជាក់អ៊ីចឹងថា ថ្ងៃខែចូលមិនច្បាស់ទេ បើ

ថ្ងៃខែសារភាពច្បាស់ជាង ។

ទីពីរ លោកសួរខ្ញុំថា ខ្ញុំនិយាយថា កាលណាជនរងគ្រោះចូលទៅដល់មន្ទីរស-២១ ត្រូវតែធ្វើទារុណកម្ម ។ ខ្ញុំនិយាយថា រឿងនេះទារុណកម្មចៀសមិនរួច ដែលខ្ញុំបានធានាអះអាងជូនតុលាការតែម្នាក់ទេដែលខ្ញុំសួរផ្ទាល់ គឺ កុយ ធួន អត់មានធ្វើទារុណកម្មទេ ។ ដូច្នេះ បើករណីលោក វិនឌី ដែលលោក សាវរិត លោកឃើញថា អក្សរនៅស្អាតថែស ។ សឲ្យឃើញថា បងលោកមិនត្រូវធ្វើទារុណកម្មទេ ខ្ញុំជឿថា ប្រហែលជាការសង្កេតនេះត្រឹមត្រូវ ព្រោះវាមិនមែនគ្រប់តែគ្នាទេ ។ នេះខ្ញុំសូមបញ្ជាក់ជូនលោកប្រធានប៉ុណ្ណេះ ដោយគោរព ។

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅលោក អ៊ូ សាវរិត? តើលោកស្តាប់បានទេនូវចម្លើយតបរបស់ជនជាប់ចោទទៅនឹងសំណួររបស់លោក?

**លោក អ៊ូ សាវរិត៖**

សូមគោរពលោកប្រធាន! នឹងខ្ញុំសូមឲ្យប្រាកដថា ខ្ញុំចង់ដឹងថា តើខ្ញុំយល់ចម្លើយរបស់ជនជាប់ចោទឲ្យច្បាស់ដែរ ឲ្យបានច្បាស់ ។ ថាតើលោកចង់បញ្ជាក់ថា បងរបស់ខ្ញុំមិនត្រូវបានគេធ្វើទារុណកម្មនោះឬមែនទេ?

[១៥:០៣:៣៤]

**ប្រធានអង្គជំនុំ៖**

សូមជនជាប់ចោទឆ្លើយបញ្ជាក់ម្តងទៀត នូវសំណួរទីពីរ ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានច្បាស់អំពីចម្លើយរបស់លោក ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ខ្ញុំពិបាកនឹងជម្រាបណាស់ បើខ្ញុំធានាជូនៗលោក សាវរិត ថាស-២១ អត់បានធ្វើទារុណកម្មលោក វិនឌី វាហាក់ដូចជាខ្ញុំឆក់ឱកាសសម្រាប់ប្រដោះខ្លួន ។ មានន័យថា ខ្ញុំឆក់ឱកាសនេះសម្រាប់ដោះខ្លួនឲ្យរួចពីទោសទណ្ឌដែលដើមបណ្តឹងរដ្ឋប្បវេណីលោកចោទខ្ញុំ ។ ដូច្នេះ ដោយខ្ញុំមិនជាប់ជាក់ស្តែងក្នុងបញ្ហាច្បាស់លាស់នីមួយៗបែបនេះ ។

ខ្ញុំសូមបញ្ជាក់ថា ជាគោលការណ៍ទារុណកម្មធ្វើតែកាលណាចៀសមិនរួច ។ ឯចំណែកអ្នកសួរក៏ប្លែកគ្នាដែរ អ្នកខ្លះឆាប់ងាកទៅរកធ្វើទារុណកម្ម អ្នកខ្លះគេមានពិសោធន៍គេមិនងាយធ្វើទារុណកម្ម

ទេ ។ ដូច្នេះ ខ្ញុំសូមគោរពលោក ដើមបណ្ដឹងថា ខ្ញុំមិនធានាឲ្យលោកសប្បាយចិត្តទទេៗទេ។ ខ្ញុំនិយាយដោយរាបសារប៉ុណ្ណេះថា អាចធ្វើតិច ឬក៏អត់មែនក៏មិនដឹងទេ ។ សូមជម្រាបប្រសាសន៍លោកប្រធានប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

--រដ្ឋប្បវេណីដើម្បីមានឱកាសក្នុងការតាំងសំណួរបន្ថែម បញ្ជាក់បន្ថែម ចំពោះកូនក្ដីរបស់លោកដើម្បីប្រយោជន៍នៃការប្ដឹងទាមទាររបស់គាត់ ប្រសិនបើលោកមានសំណួរ ។ សូមអញ្ជើញលោកមេធាវីហុង គឹមសួន ។

[១៥:០៧:២៦]

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។ សួរស្ដីលោក អ៊ូ សាវរិត ខ្ញុំនឹងសួរសំណួរខ្លះបន្ថែមជូនទៅលោកដើម្បីឆ្លើយបំភ្លឺដល់អង្គសវនាការនាពេលនេះ ។

**លោក អ៊ូ សាវរិត៖**

សូមជម្រាបសួរលោកមេធាវី ខ្ញុំត្រៀមចាំស្ដាប់ ។

**ការតាំងសំណួរដោយក្រុមមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី៖**

**សួរដោយលោក ហុង គឹមសួន៖**

សូមអរគុណ ។ នឹងសូមអរគុណដល់កញ្ញា ចេស្សីកា ដែលបានជួយសម្របសម្រួលនៅក្នុងការធ្វើសវនាការផ្ទងកាត់នេះ ។

**ស៖** សំណួរខ្ញុំសួរទៅលើទាក់ទិនជាមួយនឹងលោក អ៊ូ រិនឌី ដដែល អម្បាញ់មិញលោកច្បាស់ហើយអំពីលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច បានជម្រាបលោកថា ពេលវេលានៃការចូលទៅក្នុងមន្ទីរ ស-២១ មិនច្បាស់ទេ ដោយសារឯកសារសរសេរវាខុសគ្នាអំពីការសួរចម្លើយ ។ ខ្ញុំសូមសួរលោកថា លោកបានជ្រាបទេថាមុនពេលបញ្ជូន មានន័យថា មុនពេលអង្គការពួកខ្មែរក្រហមលោក អ៊ូ រិនឌី មកដល់មន្ទីរ ស-២១ នៅក្នុងឯកសារលេខ ERN 00274288 ឬឯកសារលេខ E2/31.4 ជាភាសាខ្មែរ បានសរសេរនៅចុងក្រោយនៃទំព័រនេះថា នៅថ្ងៃទី២៥ ខែ១០ ។ ក្នុងនេះមានន័យថា ខែ១០ ហ្នឹង គឺយោងពីវគ្គមួយៗពីលើមកនៃឆ្នាំ១៩៧៥ ។ អ៊ីចឹងថ្ងៃ២៥ ខែ១០ ឆ្នាំ១៩៧៥ គណៈសង្កាត់បានឃាត់ខ្លួនយើងខ្ញុំទាំងអស់គ្នាបញ្ជូនទៅមន្ទីរស្រុក ។ ហើយក្នុងនេះ មានន័យថា អង្គការហ្នឹងចាប់មនុស្សជាងដប់នាក់ ដំណាល

គ្នានឹងលោក អ៊ូ វិនឌី ។ តើលោកបានដឹងថា ក្នុងចំណោមលោក អ៊ូ វិនឌី តើប្អូនបង្កើត ឬបងបង្កើត ឬសាច់ថ្លៃជាមួយគ្នាហ្នឹងត្រូវបានចាប់បញ្ជូនមកស-២១ ដែរឬទេ? លោកដឹងដែរឬទេ?

[១៥:១០:៤៧]

**ឆ៖** បាទ, ពិតហើយលោកមេធាវី បងរបស់ខ្ញុំបានស្ថិតនៅក្នុងក្រុមនោះឯង ។ ដូចជាមាន ជូឡុង រង្សី ពីព្រោះថា ក្រុមគ្រួសាររបស់យើងស្គាល់គ្នា យើងជាអ្នកជិតខាងនឹងគ្នា ហើយតាមពិតគេបានចាប់ពួកគាត់នោះ ក្នុងរយៈពេលខុសគ្នាតែពីរបីខែប៉ុណ្ណោះទេ ។ ហើយ ជូឡុង រង្សី ក៏នៅក្នុងហ្នឹង លឹម គីម៉ារី, លោក ស៊ុន កាសេត បងរបស់ខ្ញុំ ហើយនិងមនុស្សមួយចំនួនទៀត ។

**ស៖** សូមអរគុណលោក អ៊ូ សាវរិត និងកញ្ញា ចេស្ស៊ីកា ហ្វីណែល ។ លោក អ៊ូ សាវរិត ការចាប់ខ្លួនលោក អ៊ូ វិនឌី និងបងប្អូនរបស់លោកក្នុងការរៀបរាប់អម្បាញ់មិញនេះ ។ លោកបានជ្រាបទេថា ការធ្វើទារុណកម្មលើកទីមួយ មានន័យថាកាលដែលអង្គការខ្មែរក្រហមចាប់ថ្ងៃទី ២៥ ខែ១០ ឆ្នាំ ១៩៧៥ នោះមុនបញ្ជូនមកស-២១ តើត្រូវបានធ្វើទារុណកម្មពីពេលនោះមកដែរទេ?

**ឆ៖** ខ្ញុំមិនអាចឆ្លើយលោកបានទេ ។ ខ្ញុំមិនដឹងថា មានអ្វីកើតឡើងមុនថ្ងៃទី១៣ កុម្ភៈ ឆ្នាំ១៩៧៦ នោះបានទេ ។

**ស៖** សូមអរគុណ ។ សំណួរចុងក្រោយ គឺខ្ញុំសួរទាក់ទិនជាមួយនឹងភាពឈឺចាប់ដែលលោកបានជម្រាបអង្គសវនាការថា ជាងសាមសិបឆ្នាំ ឬជាងមួយម៉ឺនថ្ងៃ ដែលលោកបានជម្រាបអម្បាញ់មិញនោះចំពោះលោកខ្លួនលោកផ្ទាល់ គឺ លោក អ៊ូ សាវរិត ចំពោះភរិយាលោក អ៊ូ វិនឌី និងចំពោះកូនៗរបស់លោក អ៊ូ វិនឌី ក៏ដូចជាក្រុមគ្រួសារលោក ។ តើភាពឈឺចាប់ ឬក៏ភាពចង់បានពីតុលាការមកវិញ អម្បាញ់មិញខ្ញុំឮហើយថា មិនទាមទារទេសំណងក្រៅអំពីការទាមទារឲ្យរកយុត្តិធម៌ ឬរកការពិតជូនអ្នកដែលស្លាប់នេះ តើលោកទទួលបានទេ ការទទួលសារភាពរបស់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច សូមធ្វើការអភ័យទោសនេះ?

សូមអរគុណ ។

[១៥:១៤:១៨]

**ឆ៖** ពាក់ព័ន្ធនឹងការសោកស្ដាយ ឬក៏វិប្បដិសារី ហើយនិងការសូមអភ័យទោសរបស់ជនជាប់ចោទក្នុងនាមក្រុមគ្រួសារខ្ញុំទាំងមូល ខ្ញុំសូមបញ្ជាក់ថា យើងនឹងមិនអត់ឱន លើកលែងទោសទេ ។ ដោយហេតុថា ការលើកលែងទោស គឺវាលើសពីអ្វីជាជំរំមរណៈកាលនោះ ហើយថ្ងៃនេះអ្វីៗដែលស្ថិត

នៅក្នុងជីវិតរបស់យើង គឺក្តីអស់សង្ឃឹម ។

ដូច្នេះ ចម្លើយគឺច្បាស់ យើងនឹងមិនផ្តល់ការអភ័យទោសអ្វីទាល់តែសោះពីក្រុមគ្រួសារយើង ។

**ស៖** សូមអរគុណ ។ ជាចុងក្រោយនេះ ខ្ញុំសូមសួរទៅលោកថា រាល់ការសាកសួររបស់លោកប្រធាន និងអង្គសវនាការ លោកនៅមានអ្វីចង់ដែលចង់សូមឲ្យលោកប្រធានសាកសួរ ឬចង់ឲ្យ ចង់បំភ្លឺអ្វីបន្ថែមទៀតទេ?

[១៥:១៥:៥៦]

**ឆ៖** យើងខ្ញុំមិនមានសំណួរអ្វីថែមទៀតទេ ។

**ស៖** សូមអរគុណ លោក អ៊ូ សាវរិត និងកញ្ញា ចេស្ស៊ីកា ហ្វីណែល ដែលបានចំណាយពេលវេលា និងឲ្យយើងខ្ញុំបានធ្វើការសាកសួរក៏ដូចជាលោកប្រធានផងដែរ ។

**លោក ហុង គឹមសួន៖**

លោកប្រធានខ្ញុំបានអស់ពាក្យសួរហើយបាទ ។ អរគុណបាទ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍ចាត់ចែងប្តូរនូវ ឌីវីឌី ហើយពេលរួច គឺរាយការណ៍ប្រាប់យើង ដើម្បីយើងបន្តសវនាការ ។

[១៥:១៧:១៤]

**លោក អ៊ូ សាវរិត៖**

លោកប្រធាន ខ្ញុំសូមថ្លែងអំណរគុណលោកប្រធាន ហើយខ្ញុំសូមអនុញ្ញាតសុំពេលបីបួនវិនាទីដើម្បី--

**ប្រធានអង្គជំនុំ៖**

មិនទាន់ចប់ទេ លោក អ៊ូ សាវរិត ចាំបន្តិចទៀត សឹមលោកបន្តសម្តីរបស់លោកចុងក្រោយ ។ ឥឡូវមិនទាន់ចប់ទេ ។ នៅភាគីសហព្រះរាជអាជ្ញា មេធាវីការពារក្តី និងការកត់សម្គាល់របស់ជនជាប់ចោទ នៅចំពោះសេចក្តីថ្លែងការណ៍របស់លោក ហើយចុងក្រោយសឹមអង្គជំនុំជម្រះ នឹងទុកឱកាសជូនលោកដើម្បីធ្វើសេចក្តី-- និយាយសម្តីដែលលោកប៉ុនប៉ង់ចង់និយាយអម្បាញ់មិញនេះ ។

ជាបន្តអង្គជំនុំជម្រះសំណួរទៅតំណាងសហព្រះរាជអាជ្ញា តើមានសំណួរអ្វីសួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ សាវរិត ដែរឬទេ?

[១៥:១៨:២០]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា៖**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាងលេះ**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានសំណួរមួយ ឬពីរទើបសួរទៅលោក អ៊ូ សាវរិត ដែលលោកបានជម្រាបយើងពីមុននោះថា គឺថាមានពេលវេលាពី-- មួយចំនួនដែលគាត់មិនបាននិយាយអំពីបងរបស់គាត់ឲ្យបានច្បាស់ ។

**ស៖** លោក អ៊ូ សាវរិត តើលោកបានដឹងច្បាស់ដែរឬទេ ឬក៏ក្រុមគ្រួសាររបស់បានដឹងដែរឬទេ តើបងរបស់លោកនៅឯកណាក្នុងចន្លោះខែមេសា ហើយនិងខែតុលា ឆ្នាំ១៩៧៥ ដែលលោកនិយាយថាគាត់ធ្វើការនៅក្នុងក្រសួងការបរទេស ហើយត្រូវបានដកខ្លួន ហើយបានកាន់កន្លែងមួយនៅជិតនាយករដ្ឋមន្ត្រីរហូតដល់ឆ្នាំ១៩៧៥? ហើយតើមានរឿងអ្វីកើតឡើង? តើគាត់ត្រូវបានគេជម្លៀសទៅក្រៅភ្នំពេញ ឬក៏នៅភ្នំពេញនៅឡើយក្រោយពីពេលជម្លៀសនោះ?

**លោក អ៊ូ សាវរិត៖**

**ឆ៖** សូមជម្រាបសួរលោកសហព្រះរាជអាជ្ញា។ បន្ទាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ បងរបស់ខ្ញុំ ហើយនិងសមាជិកក្រុមគ្រួសារ ១០នាក់ទៀតត្រូវបានជម្លៀសដូចប្រជាជនផ្សេងៗទៀតនោះដែរ ។ គឺអ្នកភ្នំពេញដែលត្រូវបានគេជម្លៀសហ្នឹង គឺដូចគ្នាទាំងអស់ ។

ថាតើខ្ញុំបានដឹងពីការចាប់ខ្លួន ហើយឃុំខ្លួននៅស-២១ ហ្នឹងដែរឬទេ?

[១៥:២០:០០]

ដូចដែលខ្ញុំបានជម្រាបជូននៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្ញុំនោះ ខ្ញុំបានដឹងពីរឿងនេះ នៅពេលដែលប្អូនថ្លៃស្រីរបស់ខ្ញុំបានមកជួបខ្ញុំ មកពីជំរំជនភៀសខ្លួនប្រទេសថៃមកជួបខ្ញុំ ។ ហើយក្នុងខណៈពេលខ្លីបន្ទាប់ពីនោះមក ខ្ញុំបានឃើញបញ្ជីអ្នកទោសទាំងឡាយ ដែលខ្ញុំបានបង្ហាញជូន-- ដែលតុលាការបានបង្ហាញជូននោះ ។

ដូច្នេះក្នុងចន្លោះឆ្នាំ១៩៧៥ ហើយនិង១៩៧៩ ខ្ញុំមិនមានដំណឹងអ្វីទាល់តែសោះពីសមាជិកក្រុមគ្រួសាររបស់ខ្ញុំ ។

**ស៖** ខ្ញុំមានសំណួរមួយទៀត លោកបាននិយាយពីខាងដើមនោះថា បងរបស់លោកនៅពេលដែលគេចាប់ខ្លួនគាត់ ហើយក៏បានបញ្ជូនសំបុត្រមួយ ហើយបានផ្តាំផ្ញើឲ្យមើលក្រុមគ្រួសារផង តើលោក

អាចប្រាប់បន្ថែមបន្តិចទៀតទេ អំពីកាលៈទេសៈ ឬក៏រឿងរ៉ាវជុំវិញនៃការចាប់ខ្លួនហ្នឹង? តើចាប់ខ្លួននៅកន្លែងណា? តើហេតុអីបានជាគេចាប់ខ្លួនគាត់? ថាតើដោយសារតែគាត់ គេបញ្ជាក់ថា គាត់ជាសមាជិកនៃក្រសួងការបរទេសនៅមុនឆ្នាំ១៩៧៥ ឬក៏ចាប់ដោយសារមូលហេតុអ្វី? តើលោកដឹងទេ?

**ឆ៖** ខ្ញុំជឿថាយើងត្រូវតែផ្សាភ្ជាប់ទៅនឹងប្រវត្តិរបស់បងខ្ញុំ ជាមួយនឹងការចាប់ខ្លួនរបស់គាត់ ហើយនិងជាប់ទៅនឹងទំនាក់ទំនងជាមួយនឹង ជូឡុង រង្សុី ដែលថា គាត់នៅក្រុមជាមួយ ហើយនៅក្នុងភូមិជាមួយគ្នា ។ ហើយចាប់ដោយសារថា យើងស្ថិតនៅក្នុងក្រុមគ្រួសារតែមួយ ហើយនិងជាអ្នកជិតខាងជាមួយគ្នា គឺគ្រប់ៗគ្នាត្រូវបានគេសង្ស័យ ។ ប្រហែលជាបន្ទាប់ពីការចាប់ខ្លួន ជូឡុង រង្សុី មកគណៈស្រុកប្រហែលជាចង់បញ្ចប់ការងាររបស់បងខ្ញុំមើលទៅ ។

**លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណ ខ្ញុំមិនមានសំណួរអ្វីទៅលោកទៀតទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសសួរសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ សាវរិត ។ ប្រសិនបើមានសំណួរ សូមអញ្ជើញ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

មេធាវីការពារមិនមានសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីទេ លោកប្រធាន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តនេះ អង្គជំនុំជម្រះផ្តល់ឱកាសដល់ជនជាប់ចោទ ដើម្បីមានលទ្ធភាពធ្វើការកត់សម្គាល់ចំពោះខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ សាវរិត ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ខ្ញុំគ្មានការកត់សម្គាល់អីជាពិសេសថែមទៀតទេ សូមបញ្ចប់ត្រឹមនេះ។ អរគុណ ។

**ប្រធានអង្គជំនុំ៖**

លោក អ៊ូ សាវរិត ដំណើរការនៃស្តាប់សេចក្តីថ្លែងការណ៍របស់លោកក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ដែលយើងបានរៀបចំធ្វើពីចម្ងាយតាមប្រព័ន្ធ*វីដេអូខនហ្វើរិន* ដែលយើងរៀបចំនៅសាលាក្តីនេះលើកទីមួយឃើញថាដល់ទីបញ្ចប់ហើយ ។ ហើយអម្បាញ់មិញនេះ អង្គជំនុំជម្រះបានស្តាប់នូវបំណង

របស់លោក ដែលមានការចង់និយាយសម្ដីខ្លះពីចម្ងាយមកកាន់អង្គជំនុំជម្រះ ។ ឥឡូវនេះ អង្គជំនុំជម្រះផ្ដល់ឱកាសចុងក្រោយនេះដល់លោក ដើម្បីឱ្យលោកបាននិយាយអ្វីដែលលោកមានបំណងចង់និយាយ ។ សូមអញ្ជើញ ។

**លោក អ៊ូ សាវរិត៖**

សូមអរគុណលោកប្រធាន ។ ជាបឋម ខ្ញុំសូមថ្លែងអំណរគុណតុលាការដែលបានអនុញ្ញាតឱ្យខ្ញុំធ្វើសេចក្ដីថ្លែងការណ៍ដ៏ពិស្ដារនេះ ហើយសូមថ្លែងអំណរគុណចំពោះការងាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងមេធាវី ហើយនិងក្រុមការងារ ជាពិសេសដល់សាលាក្ដីផងដែរ ដែលបានរៀបចំឱ្យមានការធ្វើសក្ខីកម្មពីចម្ងាយនេះ ។ ហើយខ្ញុំសូមថ្លែងអំណរគុណជាថ្មីដល់អង្គភាព គឺអរគុណអស់ពីដួងចិត្តពីក្រុមគ្រួសាររបស់ខ្ញុំចំពោះប្រធានគណៈមេធាវីទីក្រុងប៉ារីសដែលបានរៀបចំ-- ការរៀបចំនេះ ដើម្បីអនុញ្ញាតឱ្យខ្ញុំចូលរួមនៅក្នុងការជំនុំជម្រះនេះបាន ដែលថាបានដូចជា មេធាវី ហ្វីណែល ហើយនិងក្រុមប្រឹក្សារបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលខ្ញុំក៏សូមថ្លែងអំណរគុណ ។ ហើយសូមថ្លែងអំណរគុណជាថ្មីម្ដងទៀតចំពោះលោកប្រធាន និងលោក លោកស្រីចៅក្រមទាំងអស់ដែលមានវត្តមាននៅពេលនេះ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ដំណើរការស្ដាប់សេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ អ៊ូ សាវរិត ឃើញថាដល់ទីបញ្ចប់ហើយ ។ ហើយយើងមានដើមបណ្ដឹងរដ្ឋប្បវេណីមួយទៀត ដែលបានធ្វើការផ្ដល់ព័ត៌មានមួយចំនួនហើយ ហើយនៅពេលវេលាសមល្មម ។ អ៊ីចឹង គឺយើងសម្រេចបន្តដំណើរការស្ដាប់នូវសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ជុំ នៅ ។

ជាបន្ត មន្ត្រីតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ជុំ នៅ មកកាន់ទីកន្លែងដែលបានរៀបចំទុកសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះ ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលមកកាន់បន្ទប់សវនាការ)*

**លោក ហុង គីមសួន៖**

សូមអនុញ្ញាតលោកប្រធាន ។ ភាគីលោក អ៊ូ សាវរិត ប្រហែលជាមិនទាន់ដឹងថាបញ្ចប់ទេ ព្រោះនៅឮសូរនិយាយរង់ចាំនៅឡើយ ។ សូមលោកប្រធានជម្រាបឱ្យគេចាកចេញពីកន្លែងនោះក៏បាន។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជម្រាបលោក អ៊ូ សាវរិត ដំណើរការនៃការស្ដាប់សេចក្ដីថ្លែងការណ៍របស់លោកដល់ទីបញ្ចប់ហើយ ។ អ៊ីចឹង សូមលោកអាចចាកចេញពីទីកន្លែងនោះបានហើយ យើងអង្គជំនុំជម្រះសម្រេចមានការផ្ដាច់ការប្រព័ន្ធទាក់ទងក្នុងការឆ្លើយឆ្លងជាមួយនឹងខាងលោកទៀតហើយ ។

លោកស្រី ជុំ នៅ ចូរលោកស្រីធ្វើសេចក្ដីថ្លែងការណ៍រៀបរាប់ជូនដល់អង្គជំនុំជម្រះ ដល់អង្គសវនាការអំពីរឿងហេតុ អំពីទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលនាំឲ្យប៉ះពាល់ចំពោះលោកស្រីក្នុងអំឡុងពេលនៃការបង្កើត និងប្រតិបត្តិការមន្ទីរសន្តិសុខស-២១ ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យកាន់អំណាចនៅកម្ពុជា ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដែលនាំឲ្យលោកស្រីសម្រេចប្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងទាមទារសំណងពីជនជាប់ចោទ និងបញ្ជាក់អំពីស្ថានភាពព្យសនកម្មដែលមានចំពោះលោកស្រីជាអាទិ៍ ការខូចខាតរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និងជាផលវិបាកផ្ទាល់ដែលកើតឡើងពីបទឧក្រិដ្ឋ ហើយមានពិតប្រាកដចំពោះលោកស្រីរហូតដល់ពេលបច្ចុប្បន្ននេះ ។ សូមអញ្ជើញ។

[១៥:២៩:០០]

**លោកស្រី ជុំ នៅ៖**

ចាស, អរគុណ តុលាការជាទីគោរព! នាងខ្ញុំសូមការអនុញ្ញាត តើសេចក្ដីថ្លែងការណ៍របស់នាងខ្ញុំហ្នឹងអាចរៀបរាប់ពីឆ្នាំ៧០ មកទល់នឹង៧៩ក្រោយហ្នឹងបន្តិចបានទេ ចាស?

**ប្រធានអង្គជំនុំ៖**

អាចបាន អង្គជំនុំជម្រះអនុញ្ញាត គ្រាន់តែជាការសង្ខេបបានហើយនៅពេលដើមដំបូង បញ្ហាចម្បងគឺចន្លោះ៧៥-៧៩ ដែលមានការពាក់ព័ន្ធនឹងមន្ទីរ ស-២១ ដែលលោកស្រីមានការពាក់ព័ន្ធជាក្រុមគ្រួសារ ឬក៏រឿងខ្លួនរបស់លោកស្រីផ្ទាល់នៅក្នុងស-២៤ ។ នេះជារឿងចម្បង ។ ចំណែកឯរឿងបន្ទាប់បន្សំជាសេចក្ដីផ្ដើម គឺលោកស្រីអាចនិយាយបានពីដើមរហូតដល់ឲ្យចប់ ។ អាចក្រោយ៧៩ ដែលលោកស្រីបានមានទុក្ខសោកវេទនា នៅអំឡុងពេលនោះ ។ សូមអញ្ជើញ ។

**លោកស្រី ជុំ នៅ៖**

ចាស,អរគុណ។ ជាដំបូងសូមថ្លែងអំណរគុណចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ នាងខ្ញុំសូមរៀបរាប់ នៅក្នុងឆ្នាំ១៩៧០ ក្រុមគ្រួសារនាងខ្ញុំរស់នៅទីក្រុងព្រៃវែង ហើយដែលមានមុខរបប

ជាកសិករ គឺធ្វើប្រាំងនៅខាងលិចព្រៃវែងហ្នឹង ។ ហើយនៅក្នុងឆ្នាំ៧០ហ្នឹងដែរ គឺក្រោយពីព្រឹត្តការណ៍ ១៨ មីនា ឆ្នាំ១៩៧០ គឺជាថ្ងៃរដ្ឋប្រហារសម្តេច សីហនុ ហ្នឹង ហើយនាងខ្ញុំក៏នៅនឹងទីក្រុងព្រៃវែងហ្នឹង ។ ហើយក្រោយមកទៀតនៅក្នុងឆ្នាំ៧០ហ្នឹងដែរ ក៏មានការវ៉ៃគ្នានៅទីក្រុងហ្នឹង ។ គឺក្រោយពីការវ៉ៃគ្នាលើកទីពីរ ក្រុមគ្រួសារនាងខ្ញុំហ្នឹងទាំងអស់ហ្នឹងក៏បានចាកចេញពីទីក្រុងហ្នឹងមករស់នៅតំបន់រំដោះស្រុកកំណើតខាងម្តាយខ្ញុំ គឺភូមិព្រៃឫស្សី ឃុំជាខ្លាង ស្រុក និងខេត្តព្រៃវែង ។

[១៥:៣២:១២]

រហូតមកដល់ឆ្នាំ១៩៧១ នាងខ្ញុំនិងបងប្អូនទាំងអស់ជាបងប្អូនបង្កើតនឹង ក៏បានស្ម័គ្រចិត្តចូលបម្រើសកម្មភាពការងារបដិវត្តន៍ ជាមួយនឹងអង្គការខ្មែរក្រហម ។ ហើយនៅពេលនោះនាងខ្ញុំក៏បានទទួលនាទីជាប្រធាននារីឃុំ ។ ក្រោយមកទៀតនៅឆ្នាំ៧២ ក៏ឡើងមកធ្វើការជាប្រធាននារីឃុំជាក្លាង ។ ហើយនៅក្នុងឆ្នាំ៧៣ នាងខ្ញុំក៏បានត្រូវអង្គការចាត់តាំងមកធ្វើជាកងទ័ពនារីប្រចាំស្រុកព្រៃវែង។ អង្គាល់នុ៎ង គឺមានតែមួយកងអនុសេនាតូចទេ គឺបម្រើការសមរភូមិសម្រាប់ដឹកជញ្ជូនស្បៀងអាហារ គ្រាប់រំសេវអីទៅសមរភូមិនៅខ្សែត្រៀមមុខជាមួយយុទ្ធជន ។ តែមិនមានភារកិច្ចបាញ់ទេ តែគ្រាន់តែជាអ្នកដឹកនាំស្បៀង ។

អ៊ីចឹងនៅក្នុងឆ្នាំ៧៤ ក៏នាងខ្ញុំនឹងក៏ត្រូវអង្គការជម្រើសចាត់តាំងមកធ្វើការជាកងទ័ពយុទ្ធនារីរបស់ភូមិភាគបូព៌ា ។ អ៊ីចឹងនៅពេល អំឡុងពេលដែលនាងខ្ញុំឡើងមកជាកងទ័ពនារីនៅភូមិភាគបូព៌ាហ្នឹង គឺក៏មិនទាន់បានមានសកម្មភាពប្រយុទ្ធ ឬក៏មកសមរភូមិដែរ គឺនាងខ្ញុំនៅហាត់ហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្ររបស់ទ័ពនៅសាលាស-២០០ ។ ហើយសាលាស-២០០ ហ្នឹង គឺជាកន្លែង បើយើងនិយាយពាក្យសាមញ្ញថា “កន្លែងស្តុពល” ។

អ៊ីចឹងនៅពេលដែលយើងហាត់រៀនក្បួនយុទ្ធសាស្ត្រនៅសាលា ស-២០០ ហ្នឹង គឺអស់រយៈពេលបួនខែ គឺដល់ពេលបែក ១៧ មេសា ៧៥ ។ អ៊ីចឹង ក្រោយពេលថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ហ្នឹង ខ្ញុំមិនចាំខែទេ ប៉ុន្តែចាំឆ្នាំហ្នឹង គឺប្រហែលជាពីរបីខែក្រោយមក បានត្រូវអង្គការបញ្ជូនមកភ្នំពេញ ។ បញ្ជូនមកភ្នំពេញហ្នឹង គឺនៅក្នុងក្រសួងព័ស្តុភារសេនាធិការរបស់មជ្ឈិម មានភារកិច្ចយាមឃ្លាំងគ្រាប់ គឺថានៅក្នុងកន្លែងហ្នឹង គឺយើងមានផ្នែកមួយជាផ្នែកអង្គភាពស-៨០ ហើយទីតាំងដែលយើងរស់នៅកន្លែងហ្នឹងគឺម្តុំទួលគោក ជាមានភារកិច្ចដឹកជញ្ជូនយុទ្ធភណ្ឌ គេហៅថាគ្រាប់ជយភណ្ឌ ។ ប្រមូលគ្រាប់ជយភណ្ឌហើយនិងគ្រាប់ល្អក៏មានដែរ ដែលដឹកចូលមកពីក្រៅប្រទេសតាមច្រកផែកំពង់សោម ឬក៏តាមច្រកមក

ពីខាងក្រចេះ មកពីច្រកវៀតណាម ហើយនាងខ្ញុំនៅប្រចាំការនៅឯទីក្រុងភ្នំពេញហ្នឹងសម្រាប់ទទួល និងចាត់ចែងទុកដាក់រៀបចំអាវុធយុទ្ធភណ្ឌគ្រាប់រំសេវហ្នឹងតាមឃ្លាំង ។ ហើយក្នុងការទុកដាក់គ្រាប់គឺភាគច្រើនគឺទុកតាមផ្ទះ ផ្ទះថ្មដែលមានស្រាប់ហើយហ្នឹង គឺចាប់ពីសាលាវិទ្យាល័យឥន្ទ្រទេវី រហូតទៅដល់បង្គោលទូរទស្សន៍អង់ទែនទួលគោកហ្នឹងមួយប្លុកហ្នឹង ហើយនិងប្លុកផ្សេងៗទៀត ពេញទីក្រុងភ្នំពេញហ្នឹង ។ ដូចជាទឹកថ្លា ដូចជាម្តុំពោធិចិនតុង ម្តុំទួលទំពូងអីហ្នឹង សុទ្ធតែកន្លែងទុកគ្រាប់ ។

អ៊ីចឹងនៅក្នុងឆ្នាំ៧៦ ប្រហែលជាពាក់កណ្តាលឆ្នាំ ឬក៏ចុងឆ្នាំបន្តិច ខ្លួនខ្ញុំហ្នឹងក៏ត្រូវអង្គការរៀបចំឲ្យមានគូរស្រករជាលើកដំបូង នៅក្នុងអង្គភាពហ្នឹង ។ ប្តីរបស់នាងខ្ញុំ គឺជាយុទ្ធជននៅក្នុងអង្គភាពហ្នឹងដែរ ប៉ុន្តែមុននឹងគាត់មកនៅអង្គភាពស-៨០ហ្នឹង គឺគាត់នៅកងពល៣១០ ខាងភូមិភាគឧត្តរកំពង់ចាម ។

ដល់មកថ្ងៃទី៩ ខែ៨ ៧៧ គឺគេបាននាំប្តីខ្ញុំមកស-២១ ហើយក្រោយបីថ្ងៃដែលគេចាប់ប្តីខ្ញុំហ្នឹង គឺបានខ្លួនខ្ញុំ គឺថ្ងៃ១២ ខែ៨ ៧៧ ។ ដំបូងខ្ញុំមិនចាំថ្ងៃខែទេ ចាំតែឆ្នាំទេ អានេះខ្ញុំផ្អែកទៅលើឯកសារទេ ដែលខ្ញុំចាំនិយាយបានហ្នឹង គឺផ្អែកទៅលើឯកសារដែលមានយកចេញពីទួលស្លែងមក ។

ខ្ញុំចង់ជម្រាបជូនលោកប្រធានជ្រាបជាព័ត៌មានឲ្យកាន់តែច្បាស់ថា មុននឹងខ្ញុំ និងពីរនាក់ប្តីប្រពន្ធចេញផុតពីអង្គភាពស-៨០ ក្នុងក្រសួងសេនាធិការហ្នឹង គឺដំបូងគេយកប្តីខ្ញុំមកនៅម្តុំវត្តកំសាន្ត ខាងត្បូងច្បារអំពៅដែលយើងជិះឡាន បើកតាមផ្លូវមាត់ទន្លេហ្នឹង ទៅខាងត្បូងច្បារអំពៅហ្នឹង ។ ពេលហ្នឹងខ្ញុំនៅសម្រាកព្យាបាលនៅពេទ្យទេ ដោយខ្ញុំមានផ្ទៃពោះជាងបួនខែ មិនទាន់បាត់ចាញ់ អ៊ីចឹងគេយកប្តីខ្ញុំមកមុន ។ ហើយនៅពេលដែលខ្ញុំជា មិនថាទាន់ជាទេ គ្រាន់តែថាវាមានកម្លាំងបន្តិច ណាមួយអារម្មណ៍នឹកប្តី ។ ហើយសុំគេចេញពីពេទ្យ ប៉ុន្តែនៅពេលដែលខ្ញុំចេញពីពេទ្យហ្នឹង ក៏គេមិនឲ្យខ្ញុំទៅអង្គភាពស-៨០ទេ គឺគេឲ្យខ្ញុំនៅកន្លែងហ្នឹងសិន ព្រោះមានគេយកខោអាវមកឲ្យ ។ អ៊ីចឹងពេលហ្នឹង ក៏ខ្ញុំនៅចាំហ្នឹង ពេលគេយកខោអាវមកឲ្យ បានគេនាំខ្ញុំចេញទៅ គេប្រាប់ថាទៅជុំប្តី ។ ពេលហ្នឹង ខ្ញុំទៅជុំប្តីមែន ឃើញប្តីខ្ញុំនៅកន្លែងបង្កើនផលរបស់ក្រសួង នៅឯម្តុំវត្តកំសាន្ត ខាងត្បូងច្បារអំពៅហ្នឹង គឺដាំដំណាំ ដាំបន្លែបង្ការសម្រាប់ឧបត្ថម្ភអង្គភាព និងក្រសួង ។

អស់រយៈពេលតិចជាងមួយខែ នៅកន្លែងហ្នឹង គឺមិនមានបញ្ហាអីធ្វើបាបទេ ពីព្រោះមិនទាន់ដល់កន្លែងគុក គឺនៅកន្លែងលត់ដំរបស់ក្រសួង ។ ប្រហែលជាជាងមួយខែក្រោយមក ទើបមាន ទើបគេចាប់ប្តីខ្ញុំទៅ។

[១៥:៤១:00]

**លោក ហុង គីមសួន៖**

សូមអនុញ្ញាតលោកប្រធាន សូមអនុញ្ញាតឲ្យខាងអ្នកសម្របសម្រួលផ្លូវចិត្ត ទៅអង្គុយជិតដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ បាទ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ។ សូមអញ្ជើញ បាទ ។

**លោកស្រី ជុំ នៅ៖**

អ៊ីចឹងគឺនៅថ្ងៃទី៩ ខែ៨ ឆ្នាំ៧៧ គឺខ្ញុំបានជូនដំណើរប្ដីខ្ញុំឡើងឡាន ហើយក្នុងឡានហ្នឹងគឺមានប្រហែលជាគ្នាដប់នាក់ យកចេញពីកន្លែងបង្កើនផលហ្នឹង ។ អ៊ីចឹងនៅពេលហ្នឹង ខ្ញុំបានជូនគាត់រៀបខោអាវ គាត់គ្រាន់តែបានផ្ដាំថា គាត់មិនរស់ទេ ប្រហែលជាគាត់ដឹង ដឹងថាទៅកន្លែងណា កន្លែងណា គាត់ថាគាត់មិនរស់ទេ អ៊ីចឹង ។

អ៊ីចឹងក្រោយមកបានតែបីថ្ងៃ ក៏គេចាប់ខ្ញុំមកទៀត តែដំបូងខ្ញុំមិនដឹងថា ប្ដីខ្ញុំមកស-២១ ទេ គឺដឹងតែពាក្យថា លត់ដំ ហើយខ្លួនខ្ញុំហ្នឹងក្រោយបីថ្ងៃក៏គេចាប់មក ។ ហើយពេលដែលគេចាប់មកនេះ គឺមានគ្នាពីរនាក់ ។ ម្នាក់ហ្នឹង ខ្ញុំស្គាល់ច្បាស់ដែរ គាត់ឈ្មោះ ឆាយ ប៊ុនឃឿន នៅស្វាយរៀង ហើយគាត់មិនបានដាក់ពាក្យបណ្ដឹងទេ ហើយខ្ញុំក៏មិនដឹងថា គាត់នៅរស់ ឬស្លាប់ផង ។ គាត់នៅព័ស្ដុភារសេនាធិការជាមួយដែរ តែគាត់នៅខាងផ្នែកយន្តយុទ្ធ កន្លែងជួសជុលកាំភ្លើង ។

នៅពេលដែលគេនាំខ្ញុំមកហ្នឹង គឺឡានតូច តែខ្ញុំមិនចាំបានថា ឡាននោះម៉ាកអីទេ គ្រាន់តែដឹងថាឡានតូច ។ ហើយពេលគេដឹកមកដំបូង គឺគេយកខ្ញុំមកដាក់ត្រង់មន្ទីរពេទ្យព្រែកគ្នោត ជាមន្ទីរពេទ្យឆ្លងពីសង្គមចាស់ហ្នឹង ព្រោះខ្ញុំស្គាល់ៗច្បាស់ ពេលដែលមកដល់ហ្នឹង ព្រោះខ្ញុំធ្លាប់-- មុនពេលចាប់ខ្លួននាងខ្ញុំធ្លាប់ទៅយកគ្រាប់ជយភណ្ឌនៅម្ដុំហ្នឹង ខ្ញុំស្គាល់ច្បាស់ ។ មកដល់ត្រង់ហ្នឹង ខ្ញុំស្គាល់ថាមន្ទីរពេទ្យព្រែកគ្នោត តែខ្ញុំអត់ទាន់ដឹងថា កន្លែងហ្នឹង ជាកន្លែងលត់ដំរបស់ស-២១ ។

អ៊ីចឹងនៅថ្ងៃហ្នឹង ក្រោយពេលដែលថ្ងៃរសៀលបន្តិច ប្រហែលជាម៉ោងបី បានគេនាំខ្ញុំដើរពីមន្ទីរហ្នឹងមកដល់ភូមិស្ទឹងជ្រៅ ដោយឆ្លងកាត់ស្ពានយោលមួយកាត់ភូមិនៅអែបស្ទឹងហ្នឹង ។ ពេលដើរមកហ្នឹង គឺស្គាល់ច្បាស់នៅតាមមុខវត្តក្រពើហា តាមផ្លូវជាតិហ្នឹង ។

[១៥:៤៥:១៩]

ពេលដែលខ្ញុំមកដល់ស្ទឹងជ្រៅ បានខ្ញុំដឹងថាកន្លែងនេះ ជាកន្លែងលត់ដំ ព្រោះខ្ញុំស្គាល់ បងវ៉ាត ម្នាក់ដែលនៅគ-២០ របស់ក្រសួងព័ស្តុភារហ្នឹង ដែលគេប្រកាសថា គាត់ជា *សេរីអា* យកទៅលត់ដំនៅ ស-២១ យកទៅលត់ដំហើយ។ អ៊ីចឹងពេលដែលខ្ញុំស្គាល់ បងវ៉ាត ហ្នឹង បានខ្ញុំដឹងថា អូ! កន្លែងហ្នឹង ស-២១ដែរ ។

ប៉ុន្តែ កាលនៅព្រៃកន្ទោត កាលនៅព្រៃកន្ទោតអត់ដឹងទេ កាលនៅមន្ទីរពេទ្យព្រៃកន្ទោតនោះ ។ ហើយនៅពេលហ្នឹង នៅកន្លែងហ្នឹងគេមិនទាន់ធ្វើស្រែ កន្លែងហ្នឹងគេដាំជាបន្លែ ជាពោត ជាសណ្តែក ហើយមានក្រុមចិញ្ចឹមទា ហើយវាមានក្រុមថែដំណាំនៅប្តុកហ្នឹង ប្តុកភូមិហ្នឹង ហើយពេលហ្នឹងខ្ញុំទៅ ធ្វើការជាមួយគេអត់កើតទេ ។

មូលហេតុដែលខ្ញុំទៅធ្វើការមិនកើត ដោយទីមួយគឺខ្ញុំចាញ់កូន មិនទាន់ជា បានន័យថា ខ្ញុំហូប បាយអត់ទាន់កើត នៅក្អួត ។ ទីពីរ គឺដៃខ្ញុំនៅពិការម្ខាងដែលកាន់ចបអត់ទាន់កើត ។ ហើយអង្កាល់ហ្នឹង បើនិយាយពីរាងកាយរបស់ខ្ញុំហ្នឹង វាស្គម វាស្គមរួចទៅហើយ ដោយខ្ញុំចាប់ចាញ់តាំងមួយខែរហូតដល់ បួនប្រាំខែ នៅអត់ទាន់បានបាត់ចាញ់ ។ សូម្បីតែខ្ញុំផឹកទឹកក៏ក្អួតដែរ ហើយដល់ពេលដែលខ្ញុំទៅឃើញ អាសម្ពខ្ទះត្នោត ធុំក្លិនសម្ពខ្ទះត្នោតនៅស្ទឹងជ្រៅហ្នឹង គឺខ្ញុំក្អួតគ្មានស្វាង ខ្ញុំហូបបាយបានតិចៗ ហើយ ជាមួយតែអំបិល ។ ខ្ញុំថាខ្ញុំហូបមិនកើត ខ្ញុំសុំអំបិលហូបមក អ៊ីចឹងក៏គេអនុញ្ញាតឲ្យហូបអំបិល ។ ផ្ទះបាយ បងវ៉ាត ហ្នឹងដែលខ្ញុំច្បាស់ហ្នឹង គាត់យកមកឲ្យខ្ញុំមួយពេលបានបួនប្រាំគ្រាប់ កាលហ្នឹង យើង នៅហូបអំបិលគ្រាប់នៅឡើយ យើងគ្មានអំបិលល្អិត ។

[១៥:៤៨:១៦]

ហើយក្នុងអំឡុងពេល ក្នុងអំឡុងពេលដែលខ្ញុំនៅក្នុងស្ទឹងជ្រៅហ្នឹង គឺចាប់ពីពោះចូលប្រាំខែរហូត ខ្ញុំឆ្លងទន្លេ ។ អ៊ីចឹងពេលដែលខ្ញុំគ្រប់ខែខ្ញុំមិនដែលនិយាយទេ ទើបតែពេលនេះខ្ញុំត្រូវតែនិយាយ គេនៅតែ ប្រើខ្ញុំទៅកាប់ឧសទៀត ។ ពេលនោះ ខ្ញុំរអិលដួលច្រកកៀរទៅតាមភ្លឺស្រែ រហូតដល់ខ្ញុំធ្លាប់ឈាម ដើរ មិនរួចដែលកូនក្នុងផ្ទៃទាស់ ខ្ញុំនៅតែទឹកភ្នែករហូតដល់សព្វថ្ងៃ ។ ពេលនោះ បានវាឲ្យខ្ញុំឈប់សម្រាក ទៅធ្វើការនៅកន្លែងផ្សេងៗក្បែរៗហ្នឹង ហើយពេទ្យកន្លែងហ្នឹងមានឈ្មោះ បងថាច ជាពេទ្យឆ្មបនៅ ក្បែរហ្នឹងដែរ គឺគាត់ចំណាប់ណាស់ គាត់យកចិត្តទុកដាក់ណាស់ មិនមែនគាត់មិនព្រងើយកន្តើយទេ ។ គ្នាពួកវាដែលនៅកន្លែងហ្នឹង បានសួរថាម៉េចអាចនៅទុកកន្លែងហ្នឹងបានទេ គាត់ថាមិនអីទេ ហើយពេល ហ្នឹងគាត់ក៏ចាក់ថ្នាំឃាត់ឈាមអីទៅក៏ខ្ញុំបានចូលសម្រាករហូតដល់ពេលឆ្លងទន្លេ ។ សូមបញ្ជាក់ជូនថា

នៅពេលដែលខ្ញុំឆ្លងទន្លេហ្នឹង គឺឈ្មោះ ឆាយ ប៊ុនឃឿន ដែលគាត់ពោះធំដូចខ្ញុំដែរ ប៉ុន្តែគាត់មុនខ្ញុំមួយខែ អ៊ីចឹងបានគាត់ហ្នឹងបម្រើខ្ញុំ ហើយពេលដែលកាត់ឆ្លងទន្លេហ្នឹង ខ្ញុំបម្រើគាត់ នៅពេលដែលខ្ញុំឆ្លងទន្លេហើយហ្នឹង គាត់មិនទាន់ចេញហ្នឹង គាត់បម្រើខ្ញុំម្តង ។

អ៊ីចឹងខ្ញុំមិនអាចចាំថ្ងៃខែច្បាស់ទេ ពេលដែលខ្ញុំឆ្លងទន្លេហើយ បានប្រហែលជាមួយខែ ឬក៏ជាងមួយខែមិនដឹង ទើបបានគេបញ្ជូនខ្ញុំទៅព្រៃស។ កាលនោះខ្ញុំដឹងថា ព្រៃស ជាស-២៤ របស់សាខាស-២១ ហ្នឹង ។

[១៥:៥០:១៥]

ហើយគេបញ្ជូនខ្ញុំ ចង់បញ្ជូនខ្ញុំឡើង អ៊ីចឹងនៅពេលខ្ញុំដើរទៅស-២៤ ហ្នឹងវាកាត់វាលពីស្ទឹងជ្រៅ ព្រែកត្នោតមកត្បូងហ្នឹងវាឆ្ងាយដែរ ដៃខ្ញុំម្ខាងពិការមិនអាចបីកូនបាន ខ្ញុំត្រូវចងស្ពាយកូន ឈប់សម្រាកជាញឹកញាប់ ដែលវាវេចបាយកញ្ចប់ឲ្យហូប ដើរគ្មានអីជិះទេ ដើរកាត់វាលថ្នល់ហ្នឹងមក ។ ហើយខ្ញុំមិនចាំថាខ្ញុំនៅព្រៃសបានយូរប៉ុន្មាន ព្រោះកាលហ្នឹងខ្ញុំៗនៅស្នូងអត់ទាន់កើតទេ ព្រោះដៃខ្ញុំនៅស្ពឹក ដៃពិការហ្នឹង។ ក៏បញ្ជូនខ្ញុំមកបាគូ ឬក៏ស្ទឹងជ្រៅខ្ញុំចាំមិនច្បាស់ ប៉ុន្តែបញ្ជូនខ្ញុំចេញពីព្រៃសមកហើយ ។

ពេលដែលបញ្ជូនខ្ញុំចេញពីព្រៃសហ្នឹង ខ្ញុំមកនៅធ្វើស្រែបាគូ ប៉ុន្តែដំបូងខ្ញុំមិនទាន់ ដំបូងខ្ញុំអត់ទាន់ធ្វើស្រែកើតទេ ខ្ញុំនៅមើលកុមារ ។ អ៊ីចឹងនៅពេលដែលខ្ញុំមើលកុមារហ្នឹង ក្នុងម្នាក់ហ្នឹង គឺមើលកុមារប្រហែលជាបួនទៅប្រាំនាក់អីហ្នឹង ហើយធម្មតាយើងកូនយើង យើងយកចិត្តទុកដាក់ជាងគេ យើងបានថ្នាក់ថ្នមជាងគេហើយចំពោះគ្នាអ្នកដែលទៅស្រែ ហើយយកកូនមកទុកដាក់ហ្នឹង គឺពិបាកណាស់ ។ ហើយការពិបាកហ្នឹងគឺវាត្រូវបន្តមកដល់ខ្ញុំម្តង ពេលដែលខ្ញុំស្នូងកើត មិនចាំប្រហែលជាពីរខែ ឬក៏បីខែមិនដឹងទេ ក្រោយពេលដែលខ្ញុំឆ្លងទន្លេហើយហ្នឹង ខ្ញុំមិនចាំខែប៉ុនកាលហ្នឹងខ្ញុំស្នូងកើត ហើយដៃខ្ញុំវានៅស្ពឹកតិចៗ អាចក្តិចសំណាបស្ទូងបាន ។

ខ្ញុំនឹកស្រណោះកូនខ្ញុំបានបៅមួយថ្ងៃតែម្តងគត់ ពេលខ្ញុំសម្រាកថ្ងៃត្រង់លោកគ្រូ ខ្ញុំបានច្របាច់ទឹកដោះចេញ ដើម្បីល្បួចឲ្យកូនមកបានបៅទៀត ។ តែក្រោយមក កូនពួកម៉ាកខ្ញុំដែលឈ្មោះ ឆាយ ប៊ុនឃឿន ដែលគេកើតមុនខ្ញុំមុនខែហ្នឹង ក៏ធ្លាក់ខ្លួនឈឺ ហើយក៏ងាប់ ស្លាប់ទៅកូនហ្នឹង ។ ស្លាប់ហើយយប់ហ្នឹងពួកម៉ាក់ហ្នឹង មិត្តភក្តិខ្ញុំហ្នឹង មិនប៊ានប្រាប់គេទេ ក៏ទុកកូនហ្នឹងទល់ភ្លឺ ហើយកូនខ្ញុំហ្នឹងក៏ដេកឱបជាមួយកូនគាត់ហ្នឹង ដែលស្លាប់ហ្នឹង ខ្ញុំក៏ដេកឱបទាំងអស់គ្នាហ្នឹងទៅ ទាល់តែភ្លឺបានប្រាប់គេថា ឥឡូវកូនខ្ញុំស្លាប់ហើយ ។ អ៊ីចឹងទៅ មិនមែនកូនខ្ញុំទេ កូនមិត្តភក្តិខ្ញុំហ្នឹងឈ្មោះ ឆាយ ប៊ុនឃឿន ហ្នឹងកាល

ហ្នឹងគាត់ដាក់ឈ្មោះកូនគាត់ថា ឆាយ ប៊ុនថា ស្រី គាត់កើតកូនស្រី ខ្ញុំកូនប្រុស ហើយព្រឹកឡើងប្រាប់គេទៅ គេក៏យកកូនហ្នឹងទៅកប់នៅហ្នឹងក្បែរហ្នឹង គុម្ពចេកក្បែរហ្នឹងទៅ ។

មិនយូរប៉ុន្មានប្រហែលជាប្រាំមួយ ប្រាំពីរថ្ងៃកូនខ្ញុំក៏ចាប់ឈឺ ពេលឈឺហ្នឹង ខ្ញុំក៏គ្រាន់តែបានប្រាប់ថា កូនខ្ញុំក្តៅខ្លួនហើយជួយមើលផង ។ ប្រាប់អ្នកមើលកុមារហ្នឹង រួចហើយខ្ញុំក៏ចេញទៅស្ទូងទៅដល់តែពេលល្ងាចមកវិញ គេប្រាប់ខ្ញុំថា កូនយកទៅពេទ្យហើយ ពេទ្យភ្នំពេញ ខ្ញុំថា ខ្ញុំហួសចិត្តត្រង់ថាគេមិនឲ្យខ្ញុំទៅជាមួយ ក្រោយមកបានតែពីរថ្ងៃ បានឃើញឡានមួយមកយកខ្ញុំថាទៅតាមកូន ។ កូនហ្នឹងល្ហួងមិនស្រៀមទេ យំរហូត ។ ពេលនោះខ្ញុំអរណាស់ ហើយក្នុងរយៈពេលពីរថ្ងៃហ្នឹងខ្ញុំច្របាច់ទឹកដោះចោលរហូត ពីព្រោះសង្ឃឹមថា បានកូន បានបៅវិញ ។

[១៥:៥៥:១០]

ហើយអរណាស់ពេលដែលគេយកថាទៅជុំកូន គឺខ្ញុំអរមែនទែន។ តែផ្ទុយទៅវិញ ពេលខ្ញុំដាក់ឲ្យកូនបៅបានតែមួយម៉ោងក្រោយមក កូនខ្ញុំក៏ស្លាប់ ដោយកាលហ្នឹងវាឈឺលាប់កញ្ច្រិល ពេលដែលវាបៅខ្ញុំវាលាប់ វាទៅជាភាក់ៗ ភាកមិនបាត់រហូតស្លាប់នៅហ្នឹងដៃខ្ញុំ ។

ហើយអ៊ីចឹងពេលដែលគេយកយើងទៅលត់ដំនៅស-២៤ និងក្នុងសាខាស-២១ហ្នឹង គឺខ្ញុំមិនមែនថា ពិបាកទ្រាំណាស់ណាអីទេ ប៉ុន្តែ យើងត្រូវបត់បែនទៅតាមទម្លាប់ដែលគេប្រើយើងហ្នឹង។ ក្រោយពេលដែលកូនខ្ញុំស្លាប់ហើយ កាលនុំងពេទ្យហ្នឹងខ្ញុំចាំមិនច្បាស់ ព្រោះថាវាមានការប្រែប្រួលខ្ញុំចាំមិនច្បាស់ថា មិនដឹងជាពេទ្យហ្នឹងឈ្មោះអីទេមកដល់ភ្នំពេញវិញ ។ ក៏សុំគេទៅវិញថា មិនដឹងនៅទេ ក្រោយកូនស្លាប់បានបួនដប់ថ្ងៃហ្នឹង ថាខ្ញុំទៅស្ទូងវិញ ព្រោះខែហ្នឹងវាចំខែស្ទូងផង ព្រោះកាលដែលកូនខ្ញុំឈឺប្រហែលជាអាយុប្រាំពីរ ឬប្រាំបីខែ ចាំមិនច្បាស់ព្រោះខ្ញុំកើតឆ្លងទន្លេនៅខែ០១ ឆ្នាំ៧៨ ។

អ៊ីចឹងនៅពេលស្ទូងហ្នឹងប្រហែលជាខែ០៨ អ៊ីចឹងប្រហែលជាខែ ប្រហែលជាកូនខ្ញុំអាយុប្រាំពីរប្រាំបីខែប៉ុណ្ណឹង ។ ហើយពេលដែលកូនខ្ញុំស្លាប់ហើយ នៅមិនសុខទេៗ សុំគេមកវិញ មកស្ទូងវិញ ។

គឺរឿងមួយដែលអស្ចារ្យទៀត គឺនៅពេលដែលខ្ញុំមកវិញហ្នឹងស្រាប់តែអង្គភាពហ្នឹង អង្គភាពឈ្មោះហៅថា ក-១៤ ខ្ញុំទើបនឹកឃើញអំមិញឈ្មោះ ក-១៤ ហើយកងហ្នឹង គេដាក់សម្រាប់តែអ្នកដែលមានគ្រួសារហើយទេ គឺអ្នកនៅលីវអត់ទេ គឺសុទ្ធអ្នកមានគ្រួសារ ទោះបីគ្មានកូនក៏ដោយ កូនខ្ចីក៏ដោយ គឺនៅចម្រុះគ្នានៅហ្នឹង ។

អ៊ីចឹងពេលដែលខ្ញុំមកវិញហ្នឹង ស្រាប់តែក្នុងកងហ្នឹង គេប្រកាសក្នុងកងហ្នឹងថា ខ្ញុំ *សេអ៊ីអា* អត់

មានពីណាស្តីរកខ្ញុំមកម៉ាត់ នេះដោយសារខ្ញុំខ្សឹបសួរមិត្តភក្តិខ្ញុំទេ ហេតុអ្វីបានជាគេមិនស្តីរក? អ៊ីចឹង ខ្ញុំក៏លត់ដំអារម្មណ៍ខ្ញុំទៅតាមហ្នឹងទៅ ដូចថា យើងចុះញ៉ូមគេ ធ្វើដូចមនុស្សឆ្កួត ចេះតែដូចថា ច្រៀង គឺ ធ្វើកុំឲ្យគេដឹងថា យើងកើតទុក្ខ ដើម្បីឲ្យគេរីករាយ ថាយើងហ្នឹងពេញចិត្តពេញថ្លើមជាមួយគេដែរហ្នឹង ពាក្យថា គេហ្នឹង ខ្ញុំចង់និយាយថា អង្គការខ្មែរក្រហមហ្នឹង អ្នកដែលគ្រប់គ្រងនៅកន្លែងហ្នឹង ។ ខ្ញុំនៅចាំ ឈ្មោះ ។

ហើយអ៊ីចឹងក្រោយ នៅក្នុងឆ្នាំ១៩៧៨ ហ្នឹងគឺជាឆ្នាំទឹកទន្លេធំ នៅក្នុងប្រវត្តិសាស្ត្រប្រទេសយើង គឺខ្ញុំនៅចាំបាន គឺទំនប់នៅបាគូហ្នឹង គឺបាក់លេចអស់ស្រូវ ឃើញតែទឹកល្វឹងល្វើយ ។ ហើយកាលហ្នឹង ខ្ញុំក៏ គេសួររកអ្នកចេះថែរទូក ខ្ញុំក៏ស្ម័គ្រចិត្ត កាលហ្នឹងយើងចេះថែរទូកមែន បើថាវាត្រូវតែទទួលខុសត្រូវ ហើយបានភ្នាល់ដាក់ជីវិតគេទៀតទៅ ថាបើខ្ញុំធ្វើឲ្យខូចលេចទូក ឬក៏ម៉េច សូមដាក់ជីវិត កាលហ្នឹង ។

[១៥:៥៩:២៦]

អ៊ីចឹងក្រោយមក--

*(បញ្ហាបច្ចេកទេសបកប្រែ)*

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការពិនិត្យផ្ទៀងផ្ទាត់នៅ ជាមួយនឹងខាងបកប្រែមើល៍ តើម៉េចបានអត់មានការបកប្រែ ភាសា?

កុំអាលនិយាយឥឡូវ អត់មានការបកប្រែ ។

មន្ត្រីតុលាការសម្របសម្រួលជាមួយនឹងអ្នកបច្ចេកទេស ដើម្បីផ្ទៀងផ្ទាត់អំពីបច្ចេកទេសនៃការ បកប្រែភាសានេះ ។

*(បញ្ហាបច្ចេកទេសបកប្រែ)*

*[សវនាការផ្អាកនៅម៉ោង ១៦:១៣នាទី]*